ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- មនុស្សមួយជំនាន់ដែលទទួលរងការញាំញីសតិអារម្មណ៍ពីសង្គ្រាមវៀតណាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា
- ពិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិដីក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៨៧ ខែវិច្ឆិកា ឆ្នាំ២០២៣

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨៧ ខែវិច្ឆិកា ឆ្នាំ២០២៣

## មាតិកា



កងទ័ព ទ័ព លន់ ទម្លាក់អាវុធ បន្ទាប់ពីកងទ័ពបដិវត្តន៍ខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### សំបុត្រ


- មនុស្សមួយជំនាន់ដែលទទួលរងការញាំញីសតិអារម្មណ៍ពីសង្គ្រាមវៀតណាម និងអំពើ.......... ១


### ផ្នែកឯកសារ


- ថង រ៉ាត់ ៖ អ្នកកាន់ស្ថិតិ និងវាស់ប្រព័ន្ធភ្លឺស្រែ .. ៦


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ពិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ ...១០
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ ស្រុកកំពង់សៀម បន្តទទួលសៀវភៅ ......... ១៣
- ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុ . ១៦
- មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ ......១៩
- ដំណើរទស្សនកិច្ចសិក្សាស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង.. ២២
- មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំកម្មវិធីពិនិត្យសុខភាពបឋម និងវេទិកាពិគ្រោះយោបល់ ... ២៥
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំក្រញូងរៀបរាប់ពីរឿងរ៉ាវជីវិត............. ២៩
- មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀនស្តីអំពី «របបកម្ពុជាប្រជាធិបតេយ្យ .......... ៣៤
- នួន យ៉ាង ៖ កងចល័តនៅឃុំព្រែកណ្តៀង...... ៣៦
- សុខ រី ៖ ប្រធានក្រុមដឹកនាំប្រជាជនក្នុងភូមិ .. ៣៨
- អ៊ុច ហាំ ៖ ប្រជាជនក្នុងភូមិរើសអើង ព្រោះខ្ញុំ.. ៤០


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំវេទិកា «ជួបជុំពិនិត្យ និងពិគ្រោះពីបញ្ហាសុខភាព» .......... ៤៣
- វេទិកាអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម ........................................ ៤៦
- មជ្ឈមណ្ឌលផ្សះផ្សាវាលវែង រៀបចំវេទិកាថ្នាក់រៀនស្តីអំពី «សារសំខាន់នៃការសិក្សា ........ ៤៨
- មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីពី «ប្រវត្តិសាស្ត្រកម្ពុជា ... ៥២
- សិស្សានុសិស្សវិទ្យាល័យ ឈឹន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) .......៥៥


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- សៀង សៀប ៖ កូនពីរនាក់ស្លាប់នៅក្នុងថ្ងៃតែមួយក្នុងរបបខ្មែរក្រហម............................ ៦១


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ ៖** ឆាំង យុ, ដា៉រ៉ាវដ្ឋ មេត្តា, ចាន់ណារិទ្ធិ, លី ដេវីត, មឿន ស្រីណុច, ឡាំ ស្រីនីត, មេក វិន, សាំង ចាន់ធូ, ស៊ាង ចិន្តា, ថុន ស្រីពេជ្រ, សុភក្ត្រ ភាណា, ភា រស្មី, ជឹម សុខគា, ង៉ាន់ វិន, ទូច វណ្ណេត, ឡុង ដានី និងរឹម ស្រីស្រស់
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លឹម អ៊ុភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រ៉ាវដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# មនុស្សមួយជំនាន់ដែលទទួលរងការញាំញីសតិអារម្មណ៍ពីសង្គ្រាមវៀតណាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ឆាំង យុ





ជនពិការដោយសារគ្រាប់មីននៅកម្ពុជា។ (ម៉ូរីន ឡាំប្រាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អនាគតនៃប្រទេសក្រោយជម្លោះ គឺពឹងផ្អែកទៅលើថាតើរដ្ឋាភិបាល និងប្រជាជននៃប្រទេសនោះប្រឈមមុខតទល់, ផ្សះផ្សា និងបន្តដំណើរទៅមុខចេញពីអតីតកាលរបស់ខ្លួនដោយរបៀបណា។ អ្នករស់រានមានជីវិតពីជម្លោះនាអតីតកាល គឺជាភាគីពាក់ព័ន្ធដ៏ចាំបាច់នៅក្នុងដំណើរការនេះ ពីព្រោះថាអ្នកទាំងនេះ មិនមែនត្រឹមតែជាគ្រូបង្រៀន និងជាអ្នករៀបរាប់សាច់រឿង ដែលខ្លួនបានឆ្លងពីអតីតកាល តែប៉ុណ្ណោះទេ ក៏ប៉ុន្តែអ្នកទាំងនេះ គឺជាខ្នាតវាស់វែងអំពីការអភិវឌ្ឍន៍នៃប្រជាជាតិរបស់ខ្លួន និងជោគជ័យនៃការសម្រេចបានអនាគតដ៏ប្រសើរមួយថែមទៀតផង។

នារយៈកាលចុងទសវត្សរ៍ទី៦០ និងដើមទសវត្សរ៍ទី៧០ ប្រទេសកម្ពុជាត្រូវបានញាំញីដោយសារសង្គ្រាមវៀតណាម ហើយនៅរវាងឆ្នាំ១៩៧០និងឆ្នាំ១៩៧៥ ប្រទេសកម្ពុជា ត្រូវទទួលរងភាពខ្ទេចខ្ទាំបង្កឡើងដោយជម្លោះផ្ទៃក្នុង, អន្តរាគមន៍ពីបរទេស

និងការបំផ្លិចបំផ្លាញសង្គមយ៉ាងដំណំ។ នៅក្នុងខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងខ្មែរក្រហម បានកាន់កាប់ប្រទេសកម្ពុជា ទាំងស្រុង និងនៅក្នុងរយៈពេលប្រមាណជាង៤ឆ្នាំបន្ទាប់មក ប្រជាជនកម្ពុជាត្រូវទទួលរងភាពភិតភ័យឥតគណនា ដោយរួមបញ្ចូលនូវអំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភសិទ្ធិមនុស្សដែលយើងនឹកស្មានមិនដល់។ ក្រោយពីការដួលរលំនៃរបបប្រល័យពូជសាសន៍នេះ ប្រជាជនកម្ពុជា នៅតែបន្តរងទុក្ខដោយជម្លោះផ្ទៃក្នុង ដោយត្រូវបានដាក់ឲ្យឯកាពីអន្តរជាតិ ដែលបន្តធ្វើឲ្យ ឬធ្វើឲ្យមានភាពកាន់តែធ្ងន់ធ្ងរបន្ថែមទៀតទៅលើស្ថិរភាព, ទុរភិក្ស និងស្ថានភាពរស់នៅរបស់ប្រជាជន។ មានការប៉ាន់ប្រមាណថា ប្រជាជនកម្ពុជាប្រមាណជាង ៧ លាននាក់ បានរួចរស់ជីវិតពីអំឡុងសង្គ្រាមវៀតណាម ក្នុងនោះប្រជាជនប្រមាណជាង២ លាននាក់ បានបាត់បង់ជីវិតនៅក្នុងអំឡុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ នេះមានន័យថា សព្វថ្ងៃ នៅមានប្រជាជនប្រមាណជាង៥ លាននាក់ទៀត ជាអ្នករស់រានមានជីវិតពីបូនសម័យកាល ដោយបានឆ្លងកាត់នូវសង្គ្រាម, អំពើប្រល័យពូជសាសន៍ និងអំពើអមនុស្សធម៌។

ស្ថិតិនានា ដែលត្រូវបានចងក្រងឡើងដោយល្អិតល្អន់បានបង្ហាញថា របួសផ្លូវចិត្ត កើតចេញពីបទពិសោធន៍ពីអតីតកាលនៅក្នុងសង្គមក្រោយជម្លោះមានស្ថានភាពធ្ងន់ធ្ងរ។ បើទោះបីជាការសិក្សាស្រាវជ្រាវលើបញ្ហានេះ នៅតែបន្តប្រឈមនឹងឧបសគ្គយ៉ាងណាក៏ដោយ ការសិក្សាស្ទាបស្ទង់មតិលើអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានបង្ហាញថា អ្នកទាំងនេះ ទទួលរងបញ្ហាសតិអារម្មណ៍ច្រើនសណ្ឋាន ហើយស្ថានភាពសុខភាពផ្លូវចិត្តបង្កឡើងដោយបទពិសោធន៍ពីអតីតកាលរបស់អ្នកទាំងនេះ នៅតែបន្តកើតមានមកទល់សព្វថ្ងៃ។ អស់រយៈកាលជាងពីរទសវត្សរ៍កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជា បាននិងកំពុងបន្តការងាររបស់ខ្លួនជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីបង្កើតជាការយល់ដឹងឲ្យកាន់តែប្រសើរជាងមុន អំពីតម្រូវការ, អត្ថប្រយោជន៍ និងផ្នត់គំនិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ទោះបីជាយ៉ាងណាក្តី មជ្ឈមណ្ឌលឯកសារកម្ពុជា អនុវត្តសកម្មភាពការងារ ទាំងនេះនៅមានកម្រិតតាមសមត្ថភាពរបស់ខ្លួននៅឡើយ។

គិតត្រឹមខែសីហា ឆ្នាំ២០២២ មជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រមែប្រមូលព័ត៌មានពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួនជាង ៣ ១000 នាក់។ ការសិក្សាស្រាវជ្រាវ និងការវិភាគ សម្រេចបានដោយផ្អែកលើទិន្នន័យដែលប្រមូលបាន ដើម្បីចងក្រងជាសៀវភៅព័ត៌មានមួយ មានចំណងជើងថា «***សៀវភៅព័ត៌មានអំពីការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម***»។ លទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញថា ស្ថានភាពសុខភាពផ្លូវកាយ និងផ្លូវចិត្ត ដែលអ្នករស់រានមានជីវិតកំពុងតែប្រឈមរួមមាន ជំងឺលើសឈាម, ជំងឺក្រពះពោះវៀន, ជំងឺគ្រុនចាញ់, ជំងឺផ្លូវចិត្ត, ជំងឺបេះដូង ជាដើម ដែលសុទ្ធសឹងជាបញ្ហាសុខភាពអាទិភាព និងមានសណ្ឋានធ្ងន់ធ្ងរ សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ បន្ថែមលើសពីនេះទៅទៀត ក្នុងចំណោមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវនេះ មាន៨៧ភាគរយ នៅតែបន្តទទួលរងការរំខានពីការចងចាំក្នុងអំឡុងរបបខ្មែរក្រហម និងមាន២៥ ភាគរយទៀត នៅតែយល់សុបិនអាក្រក់អំពីរបបនេះ ថ្វីត្បិតតែបទពិសោធន៍ទាំងនេះ បានកើតឡើងកាលពីជាង៤០ឆ្នាំកន្លងទៅហើយយ៉ាងណាក្តី។

ប្រសិនបើយើងសំយោគមេរៀនមួយ ចេញពីការតស៊ូរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំពោះបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ខ្លួន ប្រាកដណាស់នោះគឺជារបួសផ្លូវចិត្ត ដែលបន្តរំខានយាយី ទោះបីជារយៈពេលជាច្រើនទសវត្សរ៍កន្លងផុតទៅហើយក្តី ដែលរបួសផ្លូវចិត្តនេះ មិនមែនញាំ

ញ្ញីតែចំពោះសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ក៏ប៉ុន្តែបានជះឥទ្ធិពលលើមនុស្សជំនាន់ក្រោយៗ ដែលបានចាប់កំណើតក្រោយពីប្រទេសកម្ពុជាទទួលបានសុខសន្តិភាពថែមទៀតផង។ របួសផ្លូវចិត្តអាចសាយភាពតាមរយៈទំនាក់ទំនងគ្រួសារ និងទំនាក់ទំនងក្នុងសង្គម បន្តជាផលប៉ះពាល់ដល់កូនៗ និងចៅៗ ព្រមទាំងញាតិសន្តាន និងសហគមន៍ថែមទៀតផង។ រោគវិទ្យាដែលសិក្សាទៅលើឥរិយាបថដូចជា អំពើហិង្សាក្នុងគ្រួសារ និងការសេពគ្រឿងញៀន គឺសុទ្ធសឹងតែជាប់ពាក់ព័ន្ធទៅនឹង របួសផ្លូវចិត្ត និងអារម្មណ៍នៃការបាត់បង់ ឬអារម្មណ៍អៀនខ្មាស់, ភាពសោកស្តាយ ឬកំហឹង ដែលមានឥទ្ធិពលជាប្រព័ន្ធ ដោយគួបផ្សំចំពោះអ្នកដែលពុំមានពាក់ព័ន្ធជាមួយគ្រួសារនៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ឬសហគមន៍នោះក្តី។

ជាការពិតណាស់ លទ្ធផលបន្សល់ពីជម្លោះហិង្សា, អំពើឃោរឃៅ និងភាពអមនុស្សធម៌មិនអាចជាកត្តាកំណត់ឬចាត់ថ្នាក់អំពីសុខុមាលភាពរបស់បុគ្គល ឬក្រុមមនុស្សបានទេ។ សង្គមក្រោយជម្លោះបានទទួលរងឥទ្ធិពលយ៉ាងដំណំ ពីរយៈកាលហិង្សាដែលបន្តជាផលប៉ះពាល់ដល់ស្ថាប័នសង្គម និងរដ្ឋាភិបាលជារួម។ មកទល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅតែបន្តដោះស្រាយសំណល់គ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលបន្សល់ទុកពីអតីតកាល។ យោងតាមអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ប្រជាជនប្រហែល ៦៥០០០នាក់ គឺជាជនរងគ្រោះពីការជាន់មីន ឬការផ្ទុះយុទ្ធភ័ណ្ឌ នៅចន្លោះខែមករា ឆ្នាំ១៩៧៩ និងខែកក្កដា ឆ្នាំ២០២១។ តួលេខនេះ រួមបញ្ចូលនូវចំនួនអ្នកបាត់បង់ជីវិតប្រមាណ២០០០០នាក់។ ក្រឡេកមើលទៅលើស្ថិតិនាពេលថ្មីៗនេះវិញ ស្របពេលដែលចំនួនគ្រោះថ្នាក់ពីការជាន់មីន ឬការផ្ទុះយុទ្ធភ័ណ្ឌបានថយចុះនារយៈកាលចុងក្រោយ នៅក្នុងឆ្នាំ២០២០ មានគ្រោះថ្នាក់បន្តពីគ្រឿងផ្ទុះបង្កប់ក្រោមដីទាំងនេះ ចំនួន៦៥ករណី។

បន្ថែមពីលើឧទាហរណ៍ជាក់ច្បាស់ អំពីផលប៉ះពាល់នៃប្រវត្តិសាស្ត្រហិង្សារបស់កម្ពុជា មកលើបុគ្គល និងសហគមន៍ ក៏នៅមានកេរដំណែលប្រវត្តិសាស្ត្រជាច្រើនផ្សេងទៀត ដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍សង្គមនយោបាយ និងអត្តសញ្ញាណជាតិរបស់កម្ពុជា។ ជាឧទាហរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជា បានសង្កេតឃើញនូវឧទាហរណ៍គួរជាទីកត់សម្គាល់នានា ថាតើរបួសផ្លូវចិត្ត បន្សល់ពីរបបប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា ជះឥទ្ធិពលទៅលើអត្តសញ្ញាណ, ការប្រាស្រ័យទាក់ទងរបស់បុគ្គលនិងជាក្រុម, ការចិញ្ចឹមបីបាច់កូនចៅ, ការងារ, សាលារៀន, និងប្រព័ន្ធជំនឿសាសនាយ៉ាងដូចម្តេច។ ក៏ប៉ុន្តែការសង្កេតទាំងអស់នេះ គឺនៅត្រឹមតែកម្រិតខាងក្រៅតែប៉ុណ្ណោះ។ នៅក្នុងកម្រិតកាន់តែស៊ីជម្រៅជាងនេះ មានការលើកឡើងជាច្រើនរាប់មិនអស់ដទៃទៀត ថាតើរបួសផ្លូវចិត្តបន្សល់ទុកពីសម័យកាលនោះ មានវិសាលភាពនៃឥទ្ធិពលខ្លាំងជាងនេះ ចំពោះផ្នត់គំនិតសង្គម, ក្រមសីលធម៌, និងការគ្រប់គ្រងយ៉ាងដូចម្តេច។ សំណួរជាច្រើនដូចជា តើយុវជន យុវនារី យល់ឃើញយ៉ាងដូចម្តេចចំពោះសេវាកម្មសាធារណៈ? តើអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជឿជាក់លើសេវាថែទាំសុខភាពឯកជន ឬសាធារណៈក្នុងកម្រិតណា? តើសេវាថែទាំសុខភាពសាធារណៈ និងឯកជន ទទួលអ្នកជំងឺរបស់ខ្លួនយ៉ាងដូចម្តេច? និង តើច្បាប់ និងទំនៀមទម្លាប់ដែលត្រូវបានពន្យល់បកស្រាយ, អនុវត្ត និងចងក្រង អាចមានមូលដ្ឋានច្បាស់លាស់, ពុំមានភាពលម្អៀង ដោយសារតែទទួលរងឥទ្ធិពល ឬកើតចេញពីបទពិសោធន៍នៃអ្នករស់រានមានជីវិតក្នុងកម្រិតបុគ្គល និងជារួម ដែលបានក្លាយទៅជាផលប៉ះពាល់បន្តអស់ជាច្រើនជំនាន់នោះ។

ទន្ទឹមនឹងនេះដែរ ស្ថានភាពសង្គមនយោបាយ និងវប្បធម៌នៃការគ្រប់គ្រងរបស់កម្ពុជា នៅតែបន្ត

លាយឡំជាមួយបទពិសោធន៍ពីសម័យកាលនោះ។ តើប្រជាជនមានការទទួលខុសត្រូវអ្វីខ្លះ ចំពោះរដ្ឋាភិបាលរបស់ខ្លួន? ចំណែកឯមន្ត្រីរាជការ ត្រូវបំពេញការទទួលខុសត្រូវអ្វីខ្លះ សម្រាប់ប្រជាជនរបស់ខ្លួន? ចំណុចទាំងអស់ខាងលើ និងចំណុចដទៃជាច្រើនផ្សេងទៀត មិនមែនផ្តោតតែទៅលើឥទ្ធិពលនៃបទពិសោធន៍ពីសម័យកាលនេះតែប៉ុណ្ណោះទេ។ ជារួម រយៈពេលជាង៤០ឆ្នាំនៃប្រវត្តិសាស្ត្ររបស់កម្ពុជា មានឥទ្ធិពលយ៉ាងសំខាន់ចំពោះការដែលប្រជាជនកម្ពុជានឹករំពៃចំពោះអនាគតផ្ទាល់ខ្លួន, ជារួមនិងរបស់ជាតិ។

មជ្ឈមណ្ឌលឯកសារកម្ពុជា គាំទ្រទាំងស្រុងចំពោះយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិ-បាលកម្ពុជាថ្មី ពីព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាយល់ឃើញថា យុទ្ធសាស្ត្រនេះ មិនមែនត្រឹមតែមានគោលដៅបំពេញដល់តម្រូវការចាំបាច់ ដែលបានលើកឡើងខាងលើប៉ុណ្ណោះទេ ក៏ប៉ុន្តែយុទ្ធសាស្ត្រនេះ ថែមទាំងមានទិសដៅស្របគ្នា ជាមួយកិច្ចខិតខំប្រឹងប្រែងដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបំពេញ ក៏ដូចជាគាំពារដល់ប្រជាជនកម្ពុជាថែមទៀតផង។ ប្រជាជនកម្ពុជា គឺជាសមាសធាតុដ៏សំខាន់បំផុតនៅក្នុងយុទ្ធសាស្ត្រនេះ ព្រមទាំងធ្វើការរួមគ្នាឈានទៅសម្រេចបានអនាគតដ៏ប្រសើរមួយសម្រាប់ប្រជាជាតិកម្ពុជា។ ប្រជាជនកម្ពុជា ត្រូវតែជាអាទិភាពចម្បងបង្អស់នៃយុទ្ធសាស្ត្របញ្ចកោណ ហើយជាក់ស្តែងយុទ្ធសាស្ត្រនេះ បានគិតគូរល្អិតល្អន់ដល់ប្រជាជនរួចទៅហើយ។ សេចក្តីសម្រេចនេះ គឺពិតជាចាំបាច់ ក្នុងការធានាថាប្រជាជននឹងមិនត្រូវបានទុកចោលដោយមិនអើពើ ដោយផែនការយុទ្ធ-សាស្ត្រថ្មីសន្ទាងរបស់កម្ពុជានេះឡើយ។

ប្រទេសកម្ពុជា ត្រូវតែធ្វើទំនើបកម្មលើស្ថាប័ននានារបស់ខ្លួន ដើម្បីត្រៀមខ្លួនឲ្យបានសមស្របក្នុងការវិវត្តខ្លួនជាប្រជាជាតិអភិវឌ្ឍន៍មួយ ក៏ប៉ុន្តែទំនើបកម្ម មិនអាចធ្វើឡើងតាមរូបមន្តចាញ់ឈ្នះនោះទេ ពោលគឺមើលរំលងប្រជាជនកម្ពុជា ដើម្បីទទួលបានការរីកចម្រើនផ្នែកបច្ចេកវិទ្យា, ផ្នែកសេដ្ឋកិច្ច ឬផ្នែកឧស្សាហកម្មនោះទេ។ ជាការពិតណាស់ អនាគតរបស់កម្ពុជា ពឹងផ្អែកទៅលើការផ្តល់អាទិភាពដល់ប្រជាជនក្រីក្រ និងងាយរងគ្រោះ។

ទោះបីជាប្រវត្តិសាស្ត្រកម្ពុជា មានអាយុកាលជាងរយសតវត្សយ៉ាងណាក្តី តែប្រទេសកម្ពុជាបែរជាត្រូវកំណត់អត្តសញ្ញាណរបស់ខ្លួនដោយព្រឹត្តិការណ៍ដែលកើតឡើងនៅសតវត្សទី២០ទៅវិញ។ វិធីសាស្ត្រប្រសើរបំផុត ដើម្បីធ្វើឲ្យប្រទេសមួយអាចគម្លាតខ្លួនពីអតីតកាលរបស់ខ្លួន និងកំណត់អត្តសញ្ញាណសាជាថ្មីនោះគឺ ការដែលប្រទេសជាតិនោះ យកចិត្តទុកដាក់ចំពោះប្រជាជន ដែលបានរស់នៅឆ្លងកាត់អតីតកាលកន្លងមក។ អ្នករស់រានមានជីវិតពីអំពើហិង្សាពីអតីតកាលនៅកម្ពុជា គឺជាជំនាន់មនុស្សដ៏អស្ចារ្យរបស់ប្រទេសកម្ពុជា។ ការដែលយើងយកចិត្តទុកដាក់ចំពោះមនុស្សមួយជំនាន់ដែលរស់រានមានជីវិតពីព្រឹត្តិការណ៍កើតមាននៅក្នុងសតវត្សទី២០ គឺជាទឡ្ហីករណ៍ សបញ្ជាក់អំពីការប្តេជ្ញារបស់កម្ពុជា ចំពោះចក្ខុវិស័យរបស់ខ្លួនសម្រាប់សតវត្សទី២១។



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ១៩៩៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**លោក ឆាំង យុ**

លោក ឆាំង យុ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ លោកគឺជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិ-បាលមួយ មានគោលបំណងសិក្សាស្រាវជ្រាវ និងចងក្រងឯកសារអំពីរបបខ្មែរក្រហម នៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីចាប់បដិសន្ធិឡើងក្នុងឆ្នាំ១៩៩៥ មកម្ល៉េះ។

នៅមុនពេលបំពេញតួនាទីជានាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ បានបម្រើការងារនៅវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិសហរដ្ឋអាមេរិក ព្រមទាំងជាសមាជិកអន្តរជាតិនៃអាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់)។ លោក គឺជាសមាជិកនៃក្រុមស្ថាបនិកបង្កើតវិទ្យាស្ថានស៊ើបអង្កេតបទឧក្រិដ្ឋកម្មអន្តរជាតិ នៅទីក្រុងឡាអេ ក្នុងឆ្នាំ២០០៣។ បច្ចុប្បន្ន លោកគឺជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៅមជ្ឈមណ្ឌលសិក្សាពីអំពើប្រល័យពូជសាសន៍ ការដោះស្រាយជម្លោះ និងសិទ្ធិមនុស្ស នៃសាកលវិទ្យាល័យ រ៉ាត់ហ្គើស ក្នុងរដ្ឋញ៉ូវជើស៊ី សហរដ្ឋអាមេរិក។ សព្វថ្ងៃ លោក កំពុងធ្វើការរៃអង្គាសថវិកាដើម្បីសាងសង់ស្ថាប័នអប់រំជាន់ខ្ពស់មួយ ដែលមានឈ្មោះថា ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ។ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ នឹងដើរតួនាទីជាស្ថាប័នអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងជាមជ្ឈមណ្ឌលសិក្សាពីអំពើប្រល័យពូជសាសន៍ចម្បងមួយនៅទ្វីបអាស៊ី។ ក្រៅពីទទួលបាន មេដាយសេរីភាពរបស់ប្រធានាធិបតីសហរដ្ឋអាមេរិក លោកទ្រូមេននិងលោករីហ្គេននៅក្នុងឆ្នាំ២០០០។ លោក ឆាំង យុ ក៏ទទួលបានពានរង្វាន់រ៉ាមុនម៉ាកសៃសៃ ដែលតែងត្រូវស្គាល់ថា ជាពានរង្វាន់ណូបែលអាស៊ី ក្នុងឆ្នាំ២០១៨ ថែមទៀតផង។




ជនពិការដោយសារគ្រាប់មីននៅកម្ពុជា។
(ម៉ូរីន ឡាំប្រាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ថង រ៉ាត់ ៖ អ្នកកាន់ស្ថិតិ និងខាស់ប្រព័ន្ធភ្លឺស្រែ ស្រុក៩២ តំបន់៤ ភូមិភាគពាយ័ព្យ

**ដារ៉ាវដ្ឋ មេត្តា**



ប្រព័ន្ធប្រឡាយក្នុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ថង រ៉ាត់ អាយុ៣៦ឆ្នាំ នៅក្នុងឆ្នាំ១៩៧៧។ មុនខ្មែរក្រហមគ្រប់គ្រងខ្ញុំគឺជាសាស្ត្រាចារ្យបង្រៀននៅវិទ្យាល័យ ស្វាយប៉ោ ក្រុងបាត់ដំបង។ ខ្ញុំមានស្រុកកំណើតនៅភូមិប៉ោយចារ ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង។ ពីឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៥៩ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាមជ្ឈិម ខេត្តបាត់ដំបង។ ចន្លោះពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៦ ខ្ញុំចូលរៀននៅវិទ្យាល័យបាត់ដំបង។ នៅពេលនោះ ខ្ញុំចូលរួមធ្វើសកម្មភាពផ្សេងៗ រួមមាន ៖ នៅចុងឆ្នាំ១៩៦០ ឈ្មោះ ជន ជៀន គឺជាអតីតសាស្ត្រាចារ្យអប់រំខ្ញុំឲ្យធ្វើជាគិញក្នុងវិទ្យាល័យ ដើម្បីតាមដានមើលសិស្សនៅក្នុងថ្នាក់រៀនរបស់ខ្ញុំ ហើយរាយការណ៍ឲ្យនាយកវិទ្យាល័យ ឈ្មោះ ប៉ោង គិមគន និង ឈ្មោះ អ៊ុន រ៉ុន។ ក្នុងឆ្នាំ១៩៦៧ ខ្ញុំមករៀនក្នុងមហាវិទ្យាល័យគរុកោសល្យភ្នំពេញ។ ក្រោយមកនៅឆ្នាំ១៩៦៩ ខ្ញុំធ្វើជាសាស្ត្រាចារ្យបង្រៀននៅវិទ្យាល័យពោធិ៍សាត់។ នៅក្នុងឆ្នាំ១៩៧០ យិន កោ អប់រំខ្ញុំចូលជា សេ-អ៊ី-អា។ ពេលបញ្ចូលខ្ញុំជា សេ-អ៊ី-អា គឺនៅក្នុងបន្ទប់មួយក្នុងវិទ្យាល័យ អ៊ំាបយុគ ដោយមានឈ្មោះ យិន កោ គឺជាអ្នកខ្ទេសនាម

និងឈ្មោះ ផុង ផារប់ គឺជាអ្នកទទួលស្គាល់។ ភារកិច្ចដែលខ្ញុំត្រូវបំពេញ គឺនៅពេលបង្រៀនត្រូវបំផុសឲ្យសិស្សស្អប់របបកុម្មុយនីស្ត ហើយស្រឡាញ់ពេញចិត្តរបបលោកសេរី ព្រមទាំងតាមដានមើលសកម្មភាពសិស្សធ្វើបដិវត្តន៍ និងទប់ទល់បាតុកម្មណាដែលមិនគាំទ្ររបបសាធារណរដ្ឋខ្មែរ។

នៅខែមករា ឆ្នាំ១៩៧១ យិន ភោ ឲ្យខ្ញុំធ្វើការទាក់ទងជាមួយមនុស្សមួយក្រុមទៀតដែលជាខ្សែជាមួយឈ្មោះ អ៊ឹង តុងហ៊ុន អតីតសាស្ត្រាចារ្យ, សូ គិមហុក គឺជាអតីតសាស្ត្រាចារ្យបច្ចុប្បន្នអ្នកបច្ចេកទេសរស់នៅជាមួយ តាស៊ុយ គណៈតំបន់៤, លិម នា, លាត លានហួ បច្ចុប្បន្នគឺជាអ្នកកាន់ស្ថិតិក្នុងស្រុក៤៣ តំបន់៤, យ៉ូវ ឆុំ គឺជាអ្នកកាន់ស្ថិតិ និងរ៉ាស់ប្រព័ន្ធភ្លើស្រែក្នុងស្រុក៤៣ និង នន់ នារ៉ា។ ចាប់តាំងពីពេលនោះមក រាល់ថ្ងៃបង្រៀនខ្ញុំតែងឆ្លៀតបំពាក់នយោបាយប្រឆាំងនឹងបដិវត្តន៍ដល់សិស្សតាមមាគ៌ាប្រឆាំងនឹងរបបកុម្មុយនីស្ត។ នៅក្នុងឆ្នាំសិក្សាឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ ក្នុងវិទ្យាល័យ អ៊ាប យុត ខ្ញុំចូលអប់រំញុឹកញាប់ដល់សិស្សថ្នាក់ទី ២ទំនើបជាតិ។ ថ្នាក់នេះមានសិស្សភាគច្រើនជាកូនអ្នកមានក្នុងក្រុងដែលប្រឆាំងនឹងបដិវត្តន៍។ ការអប់រំសារចុះសារឡើងក្នុងថ្នាក់ ខ្ញុំទទួលបានកម្លាំងស្នូលប្រឆាំងនឹងរបបកុម្មុយនីស្តចំនួន៣នាក់ ដើម្បីយកមកធ្វើជាគិញគឺ តាន់ ថៃ អតីតសិស្សថ្នាក់ទី២វិទ្យាល័យ អ៊ាប យុត, គិម រស្មី អតីតសិស្សថ្នាក់ទី២ វិទ្យាល័យ អ៊ាប យុត និង ភោគ សោភ័ណ អតីតសិស្សថ្នាក់ទី២ វិទ្យាល័យ អ៊ាប យុត។ ក្រោយមក គិញទាំង៣នាក់នេះបានរាយការណ៍ឲ្យខ្ញុំអំពីសកម្មភាពសិស្សធ្វើបដិវត្តន៍ និង ប្រភពដែលធ្វើបាតុកម្មប្រឆាំងនឹងរបបសាធារណរដ្ឋ។

នៅឆ្នាំ១៩៧៣ ក្រុមគិញសម្ងាត់របស់យើងតាមដានសកម្មភាពបាតុកម្មមួយដែលបម្រុងនឹងកើតឡើង។ នៅល្ងាចថ្ងៃមួយ ផុង ផារប់ ទទួលបានការរាយការណ៍ថាបាតុកម្មត្រូវផ្ទុះនៅល្ងាចថ្ងៃស្អែកពេលព្រឹកឆ្នាំ១៩៧៣ ពេលសិស្សកំពុងចូលរៀន។ ភ្លាប់បានសភាពការណ៍យ៉ាងនេះភ្លាម ផុង ផារប់ ក៏ហៅ នារ៉ា, លិមធា យ៉ូវ, តុង ហ៊ុន និងខ្ញុំ មកប្រជុំសម្ងាត់នៅបន្ទប់សិក្សាវិទ្យាល័យ អ៊ាប យុត ដើម្បីរិះរកវិធានការទប់ទល់។ ក្រោយពីការប្តូរមតិគ្នាចុះឡើងអស់រយៈពេលកន្លះម៉ោង អង្គប្រជុំសម្រេចផែនការទប់ទល់មួយគឺ ពេលសិស្សចូលក្នុងថ្នាក់អស់ យើងត្រូវឲ្យគ្រូបង្រៀនថ្នាក់នីមួយៗបិទទ្វារឲ្យជិតកុំឲ្យសិស្សចេញចូលចុះឡើង, ក្រុមគ្រូ សេ-អ៊ី-អា ត្រូវចល័តតាមមុខបន្ទប់រៀនឃ្លាំមើលសកម្មភាពសិស្សក្នុងថ្នាក់ ខ្លាចមានផ្ទុះចេញពីបន្ទប់, ក្រុមយើងម្នាក់ ឬពីរនាក់ ត្រូវទៅបិទទ្វាររបងសាលា។ នៅថ្ងៃបន្ទាប់ ផែនការរបស់យើងត្រូវបរាជ័យ ហើយខ្ញុំគេចចេញពីទីនោះទុកឲ្យបាតុកម្មឆេះតាមកំហឹងបាតុករ។

ក្នុងឆ្នាំ១៩៧៤ បញ្ហាប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ និងកូដកម្មលេចចេញតាមរយៈគ្រូបង្រៀន។ ដោយខ្ញុំពុំបានចូលរួមប្រជុំសម្ងាត់ ផុង ផារប់ បានទាញស្មារខ្ញុំនិយាយខ្សឹបថា «គិញសម្ងាត់យើងប្រាប់ថា ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ គ្រូៗឈប់បង្រៀនហើយ ហើយនិងធ្វើកូដកម្ម ដូច្នេះរាត់ឯងត្រូវធ្វើសកម្មភាពប្រឆាំង ដោយទៅបង្រៀនជាមួយក្រុមគ្រូ សេ-អ៊ី-អា ដើម្បីអូសទាញក្រុមប្រឆាំង។ ព្រឹកនោះ និងនៅថ្ងៃបន្តបន្ទាប់ ខ្ញុំតែងឡើងទៅបង្រៀនតាមកាលកំណត់ហើយអូសទាញគ្រូមួយចំនួនឲ្យធ្វើតាមដោយយកលេសថា «យើងគឺជាអ្នកបង្រៀនសិស្សដែលត្រូវប្រឡងក្នុងឆ្នាំនេះ បើរវល់តែឈប់ខ្លាចមិនចប់កម្មវិធី ហើយកូនយើងកូនគេអស់បានចេះអ្វីហើយ»។ ក្រុមខ្ញុំបានជំរុញគ្រូមួយក្រុមទៀតបង្រៀនសិស្សដោយគ្មានឈប់ ប៉ុន្តែមិនបានពេញលេញទេ។ យើងបានធ្វើសកម្មភាពបង្រៀនបានកន្លះខែ ក្រោយមកអស់ទាំងគ្រូនិងសិស្ស គ្មានអ្នកណាមករៀន គ្មានអ្នកណាមកបង្រៀនទៀតទេ។ គ្រូៗនៅក្នុងក្រុងនាំគ្នាមកថ្លែងការណ៍ថ្កោលទោសរដ្ឋាភិបាល លន់ នល់ ក្នុងសាលាបឋមសិក្សាកុមារីសោ ហ៊ី ជារៀងរាល់ថ្ងៃ។ នៅពេលបាតុកម្មខ្ញុំស្គាល់

សេ-អ៊ី-អា ឈ្មោះ យិន ឈឿម តាមរយៈ សោម សំអ៊ុន គឺជាអតីតនាយកវិទ្យាល័យ ស្វាយប៉ោ។

នៅដើមឆ្នាំ១៩៧៥ យិន ឈឿម ទាក់ទងខ្ញុំឲ្យទៅបង្រៀននៅវិទ្យាល័យ ស្វាយប៉ោ និង ចាត់តាំងខ្ញុំឲ្យចូលរួមបើកសាលាសង្គ្រាមនយោបាយមួយតាមការបង្រៀនចំហដល់សិស្សវិទ្យាល័យ ស្វាយប៉ោ ចំនួនមួយសប្តាហ៍។ កម្មវិធីបង្រៀនពេលព្រឹក គឺសិក្សាអំពីទ្រឹស្តីប្រឆាំងនឹងរបបកុម្មុយនីស្ត, ពេលរសៀល សិក្សាពីរបៀបដោះសោកាំភ្លើងគ្រប់ធន់ និងគ្រាប់បែក ហើយនៅពេលយប់ទស្សនាខ្សែភាពយន្តឯកសារប្រឆាំងរបបកុម្មុយនីស្ត។ ក្រោយបញ្ចប់សាលាសង្គ្រាមនយោបាយនៅក្នុងខែមីនា ឆ្នាំ១៩៧៥ ខ្ញុំចូលរួមប្រជុំសម្ងាត់ម្តងទៀតជាមួយ ផុង ផារប់ រួមសមាជិកចំនួន៦នាក់ទៀត។ ការប្រជុំលើកនេះប្រហែលជាថ្ងៃចុងក្រោយ ព្រោះដឹងថានយោបាយប្រឆាំងរបស់យើងត្រូវរលំរលាយ ហើយបដិវត្តន៍នឹងដណ្តើមបានជ័យជម្នះ។ នៅថ្ងៃទី២០ ខែមេសា គណៈតំបន់៤ឈ្មោះ ស៊ូ ផ្ញើការអំពាវនាវឲ្យគ្រូនៅក្នុងក្រុងបាត់ដំបងស្ម័គ្រចិត្តចូលជួយធ្វើការអង្គការ។ ត្រូវតាមផែនការបង្កប់ខ្លួនស៊ីរូងផ្ទៃក្នុង ខ្ញុំបានទៅរកកន្លែងជួបជុំធ្វើការនៅក្នុងក្រសួងសុរិយោដីបាត់ដំបង។ នៅថ្ងៃទី២៨ សំអ៊ុន បើកអង្គប្រជុំសម្ងាត់មួយក្នុងផ្ទះ ក្រោយប៉ុស្តិ៍ខ្សែលួស ដោយលើកពីផែនការប្រឆាំងនឹងបដិវត្តន៍របស់យើង ដោយសំអ៊ុន គឺជាអ្នកទទួលផ្ទាល់ ហើយ សំអ៊ុន យកមកឲ្យយើងអនុវត្ត។ ផ្នែកយើងត្រូវរង់ចាំយកសំបុត្រខ្ទេសនាមពី បង ស៊ូ ដែលចាត់តាំងយើងទៅបង្កប់តាមមូលដ្ឋាន។ ខ្ញុំទទួលបានសំបុត្រខ្ទេសនាមទិសដៅ ស្រុក៤២ និងមានសមាជិកចំនួន១១នាក់ហើយមាន ឆុំ គឺជាអ្នកទទួលខុសត្រូវ និងឡើងទៅជួប សំអ៊ុន រៀងរាល់ខែនៅភូមិអន្លង់វិល ក្នុងស្រុក៤១។ នៅក្នុងខែមិថុនា យើងទទួលផែនការប្រឆាំងមួយពី សំអ៊ុន គឺធ្វើសកម្មភាពឲ្យប្រជាជនថ្មីស្អប់កម្មាភិបាលបដិវត្តន៍។ យើងបានប្រជុំគ្នារិះរកមធ្យោបាយញុះញង់ឲ្យកម្មាភិបាលដើរប្រមូលនាឡិកា កង់ វិទ្យុ ពីប្រជាជន។ ធ្វើយ៉ាងនេះច្បាស់ជាបណ្តាលឲ្យប្រជាជនក្តៅក្រហាយ ព្រោះប្រជាជននៅស្រឡាញ់របស់ខ្លួន។ មួយសប្តាហ៍ក្រោយមក ខ្ញុំបានជំរុញឲ្យគណៈភូមិក្បាលថ្នល់អនុវត្តផែនការនេះបានសម្រេច និងរាលដាលដល់ភូមិ ឃុំ ក្នុងស្រុក៤២។ ជិតចុងឆ្នាំ១៩៧៥ មុនពេល បង ស៊ូ ត្រូវផ្លាស់ចេញពីតំបន់៤ ទៅក្រសួងការបរទេស សំអ៊ុន បានទទួលផែនការពី បង ស៊ូ ទាក់ទងធ្វើការជាមួយមនុស្សថ្មី ដែលគាត់ទើបបញ្ចេញពីអង្គភាពយោធា ឈ្មោះ សឿន បច្ចុប្បន្នគឺជាប្រធានសង្គមកិច្ច និងវប្បធម៌ស្រុក៤២ តំបន់៤។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ យើងទាំងអស់គ្នាឯកភាពប្រមូលខ្សែចាស់ដែលជាប្រជាជនក្នុងស្រុក៤២ ឲ្យមកជុំគ្នាដើម្បីសម្រួលក្នុងការអនុវត្តបុព្វកាភក្សាផែនការ។ យើងអនុវត្តផែនការតាមសហករណ៍ឲ្យស្របនឹងភារកិច្ចវាស់វែងដីធ្វើប្រព័ន្ធភ្លឺស្រែ និងប្រឡាយ។ វិធានការទាំងនោះ គឺ ១) ប្រព័ន្ធភ្លឺស្រែត្រូវស្ទង់ឲ្យឃើញក្រឡាចតុរង្គតាមមាត្រា ប៉ុន្តែបំភ្លៃធ្វើទំហំស្រែឲ្យខុសហិកតាជាហេតុនាំឲ្យខុសទិន្នផលស្រូវគិតជាតោនក្នុង១ហិកតា ២) ប្រព័ន្ធប្រឡាយត្រូវស្ទង់ឲ្យត្រង់ដូចបន្ទាត់តែត្រូវឲ្យមានទំនាស់ជាមួយភូមិសាស្ត្រធ្វើ ដូចនេះដើម្បីឲ្យបដិវត្តន៍មានប្រឡាយត្រង់ល្អ ប៉ុន្តែប្រើប្រាស់ពុំកើតដោយខ្វះប្រភពទឹក។

នៅចុងខែមករា ឆ្នាំ១៩៧៧ ឆុំ, ខ្ញុំ និង សឿត នាំគ្នាឡើងទៅអន្លង់វិល ស្រុក៤១ ដើម្បីយកស្ថិតិទិន្នផលស្រូវដែលប្រមូលបានពីស្រុក៤២ ទៅដាក់នៅមន្ទីរតំបន់៤។ ឆ្លៀតពេលនោះ យើងទាំង៣នាក់បានទៅជួប សំអ៊ុន នៅលើផ្ទះក្នុងភូមិជិនីកខាងស្តាំផ្លូវជាតិលេខ៥ដើម្បីទទួលផែនការថ្មី។ ចូលដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ ខ្ញុំចាប់ផ្តើមអនុវត្តផែនការពង្រីកកម្លាំងជាបន្តទៀត។ ខ្ញុំពិនិត្យតាមដានសកម្មភាពមនុស្សពីរនាក់ ដែលរួមរស់ជាមួយខ្ញុំក្នុងជំរំលើកអាងទឹកមួយរបស់ស្រុក៤២។ ការរស់នៅស៊ីចុកដេកពួន ជាមួយគ្នារាប់ខែបានស្និទ្ធ

ស្នាលជាមួយខ្ញុំ និង ហ៊ាននិយាយការសម្ងាត់ជាមួយខ្ញុំថា «បើកុំតែខ្ញុំទុកចិត្តបង ខ្ញុំមិនហ៊ាននិយាយទេ។ សព្វថ្ងៃក្នុងមួយរយភាគរយហើយ ខ្ញុំស្អប់បដិវត្តន៍អស់ពី៧០ទៅ៨០ភាគរយ ព្រោះដូចបងឃើញស្រាប់ហើយ ធ្វើការចង់ស្លាប់ គ្មានថ្ងៃឈប់សម្រាក មិនឃើញមានបានទៅណា នៅតែរហេមរហាមអស់អាវស្លៀកពាក់ ស៊ីមិនឆ្អាញ់ ដេកមិនស្រួល»។ និយាយត្រឹមនេះខ្ញុំបានលើកឡើងពីចំណុចខ្វះខាតនៅក្នុងសហករណ៍។ ក្រោយមកខ្ញុំរួមជាមួយហ៊ឹម ក៏បានបញ្ចូលអ្នកទាំងពីរទៅក្នុងក្រុមប្រឆាំងរបស់ខ្ញុំ។ នៅក្នុងខែមីនា ខ្ញុំត្រូវដាច់ខ្សែទាក់ទងជាមួយ សំអ៊ុន ដែលត្រូវអង្គការចាប់ខ្លួន។ ទន្ទឹមនឹងនេះ អង្គការស្រុកបានបញ្ជូនខ្ញុំ ហើយឲ្យចូលក្នុងកងចល័តដើរធ្វើការតាមសហករណ៍ដកចេញពីជំរំរួម ឲ្យខ្ញុំទៅនៅអាងទឹកសាករតែម្នាក់ឯងក្រោមការឃ្លាំមើលរបស់គណៈស្រុក រួចដកពីសាករឲ្យខ្ញុំទៅនៅការដ្ឋានធ្វើស្រែភ្នំធិបតី ជាប់ជាមួយគណៈស្រុកមួយទៀត រហូតដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៧ អង្គការចាប់ខ្លួនខ្ញុំតែម្តង។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាព J០០១២៣។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ថង វ៉ាត់ ពិតប៉ុយ៉ាងណានោះទេ។**



កងចល័តកំពុងជីកប្រឡាយក្នុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»

## កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិដីក្រហម

ចាន់ ណារិទ្ធិ



នៅព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៨៤នាក់ ក្នុងនោះមានស្រី៥៤នាក់ រស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(ធី គីមហុង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានធ្វើការចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៨៤នាក់ ក្នុងនោះមានស្រី៥៤នាក់ រស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ជាកិច្ចចាប់ផ្តើមកម្មពិធី លោក ឃិន វ៉ី គឺជាមេភូមិដីក្រហម ថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងដែលបាននាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ មកចែកជូនដល់យុវជន និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិដីក្រហមនេះ។ លោក ឃិន វ៉ី បន្តថា សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ»

នេះគឺជាប្រវត្តិសម្តេចយាយ បានអមព្រះរាជដំណើរសម្តេចតាឆ្លងកាត់ពីប្រទេសចិន មកវៀតណាម និងបន្តមកទស្សនកិច្ចប្រទេសកម្ពុជា និងជួបជាមួយប្រជានុរាស្ត្ររបស់ព្រះអង្គដែលបានចូលរួមក្នុងចលនាតស៊ូនៃរណសិរ្សរួបរួមជាតិកម្ពុជា នៅឆ្នាំ១៩៧៣ ដែលឆ្លងកាត់ឧបសគ្គ និងគ្រោះថ្នាក់ដល់អាយុជីវិត។

កិច្ចបន្ទាប់លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានថ្លែងអរគុណលោក យិន វ៉ា មេភូមិដីក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមកចូលរួមក្នុងកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងថ្ងៃនេះ។ មុនចែកជូនសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» លោក ឡុង ដានីបានសង្ខេបអំពីប្រវត្តិមជ្ឈមណ្ឌលផ្សះផ្សាវាលវែងដែលមានទីតាំងស្ថិតនៅក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ និងបានបើកដំណើរការនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ព្រមទាំងគោលបំណងនៃការបង្កើតមជ្ឈមណ្ឌលផ្សះផ្សាវាលវែងនេះ។ ក្នុងឱកាសនោះលោក ឡុង ដានី បានស្នើសុំយុវជនស្ម័គ្រចិត្តចំនួន៤រូបដើម្បីឡើងអានសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ គោលបំណងនៃការស្នើឲ្យយុវជនឡើងអានសៀវភៅនេះគឺ៖ ១) ចង់ឲ្យយុវជន និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមយល់ដឹងខ្លះៗអំពីខ្លឹមសារក្នុងសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលជាព្រះរាជដំណើររបស់ហ្លួងម៉ែ និងសម្តេចព្រះបរមរតនៈកោដ្ឋយាងមកប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៣។ ២) បង្ហាញពីភាពទន់ភ្លន់ និងសេចក្តីថ្លៃថ្នូររបស់ហ្លួងម៉ែ ចំពោះព្រះរាជតម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនរបស់ហ្លួងម៉ែ ក្នុងព្រះរាជដំណើរពីទីក្រុងប៉េកាំងមកទីក្រុងហាណូយ បន្តព្រះរាជដំណើរដោយរថយន្តតាមផ្លូវលំហូជីមិញចូលមកកាន់ប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៧៣។ ៣) ចង់ឲ្យយុវជនឈ្វេងយល់ពីរបៀបសរសេរ និងសារសំខាន់នៃកំណត់ហេតុផ្ទាល់ខ្លួន។ ជាចុងក្រោយ លោក ឡុង ដានី ក៏សូមអរគុណដល់លោក យិន វ៉ា និងលោកតា លោកយាយ អ៊ំពូមីងទាំងអស់ ហើយសូមជូនពរឲ្យមានសុខភាពល្អ និងជោគជ័យរាល់កិច្ចការងារ។

ចុងបញ្ចប់នៃពិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក៏មានចំណាប់អារម្មណ៍ពីយុវជន និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដូចខាងក្រោម៖

**ហ៊ុយ រណេត** មានអាយុ៦០ឆ្នាំ មានប្រសាសន៍ថា ខ្ញុំមានអារម្មណ៍សប្បាយចិត្ត និងរីករាយជាខ្លាំងដែលបានចូលរួមស្តាប់នូវរឿងរ៉ាវប្រវត្តិសាស្ត្ររបស់ហ្លួងម៉ែ។ ទោះក្នុងពេលនោះខ្ញុំនៅក្មេងមិនបានដឹងនូវរឿងរ៉ាវច្រើនក៏ដោយ ប៉ុន្តែនៅពេលនេះខ្ញុំចង់ស្តាប់ និងចង់តាមដានហេតុការណ៍ដែលសម្តេចម៉ែបានឆ្លងកាត់ និងជួបប្រទះក្នុងកំឡុងពេលនោះបន្តទៀត។

**កុង វ៉េត** មានអាយុ៤៣ឆ្នាំ មានប្រសាសន៍ថា ខ្ញុំមានក្តីរំភើប និងសប្បាយចិត្តពេលដែលបានដឹងនូវរឿងរ៉ាវប្រវត្តិសាស្ត្ររបស់ហ្លួងម៉ែ ដែលព្រះអង្គមានគោលបំណងចង់ផ្សព្វផ្សាយអំពីប្រវត្តិ-សាស្ត្រប្រទេសកម្ពុជា និងផ្តល់ចំណេះដឹងដល់សិស្សានុសិស្សឲ្យបានយល់កាន់តែច្បាស់ពីប្រវត្តិ-សាស្ត្រប្រទេសជាតិខ្លួនដែលបានឆ្លងកាត់កន្លងមក។

**សុន ចាន់** គឺជាគ្រូបង្រៀននៅសាលាបឋមសិក្សាគិរីសន្តិភាព រៀបរាប់ថា ក្នុងនាមខ្ញុំជាក្មេងជំនាន់ក្រោយ ខ្ញុំសប្បាយចិត្តខ្លាំងដែលមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ មកចែកជូនដល់អ្នកភូមិរបស់ខ្ញុំ។ ខ្ញុំបានអានសៀវភៅនេះហើយ ខ្ញុំទទួលបានចំណេះដឹងបន្ថែម ដូចជា ព្រះរាជដំណើររបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ និង

សម្តេចព្រះ នរោត្តម សីហនុ ចេញពីទីក្រុងប៉េកាំងប្រទេសចិនមកកាន់ទីក្រុងហាណូយប្រទេសវៀតណាម មកទស្សនកិច្ចជាប្រវត្តិសាស្ត្រក្នុងតំបន់រំដោះនៃប្រទេសកម្ពុជាឆ្នាំ១៩៧៣ ។



នៅព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៨៨ នាក់ ក្នុងនោះមានស្រី៥៨នាក់ រស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(ធី គីមហុង/មជ្ឈមណ្ឌលឯកសារកម្ពុជា)









# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ ស្រុកកំពង់សៀម បន្តទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

លី ដេវីត



ពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យ ហ្វូងម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៧០០នាក់មកពីភូមិទាំង៨នៃឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យ ហ្វូងម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៧០០នាក់មកពីភូមិទាំង៨នៃឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

ការចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ធ្វើឡើងតបតាមការស្នើសុំរបស់លោក លន់ លាងហេង មេឃុំគគរ ដើម្បីឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងឃុំគគរ បានអានសៀវភៅប្រវត្តិសាស្ត្រដ៏មានសារសំខាន់នេះ។ ឃុំគគរ ស្ថិតនៅតាម







ពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន៧០០នាក់មកពីភូមិទាំង៨នៃឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ដងទន្លេមេគង្គ និងមានចម្ងាយប្រមាណ២០គីឡូម៉ែត្រពីទីរួមខេត្តកំពង់ចាម។ ឃុំគគរ គឺជាអតីតសមរភូមិប្រទាញប្រទង់រវាងកងទ័ពរំដោះខ្មែរក្រហម និងកងទ័ព លន់ នល់។

នៅឆ្នាំ១៩៧៣ ប្រជាជនរស់នៅក្នុងឃុំគគរត្រូវបានដាក់ឲ្យស្ថិតនៅក្នុងស្ថានភាពវឹកវរ ដែលបណ្តាលឲ្យមានការរត់ភៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីស្វែងរកទីតាំងសុវត្ថិភាព។ ក្នុងគ្រាដែលមានការប្រយុទ្ធគ្នា អ្នកភូមិមួយចំនួនរត់ភៀសខ្លួនឆ្លងទន្លេទៅកាន់ដីហែរដែលជាតំបន់រំដោះខ្មែរក្រហម ខណៈពេលដែលអ្នកភូមិមួយចំនួនទៀតរត់ចូលទីរួមខេត្តកំពង់ចាមគ្រប់គ្រងដោយ លន់ នល់។ ការប្រទាញប្រទង់នេះបានបញ្ចប់ នៅពេលដែលកងទ័ពរំដោះខ្មែរក្រហមវាយយកឈ្នះទៅលើកងទ័ព លន់ នល់ និងត្រៀមវាយចូលទីរួមខេត្តកំពង់ចាមនៅពាក់កណ្តាលឆ្នាំ១៩៧៣។

លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ពន្យល់បន្ថែមអំពីសារសំខាន់ និងការឆ្លុះបញ្ចាំងអំពីបរិបទប្រវត្តិសាស្ត្រកម្ពុជាក្នុងសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរដែលជាឯកសារប្រវត្តិសាស្ត្រគ្មានពីរទេ និងរឿងរ៉ាវកើតឡើងនៅតាមមូលដ្ឋានទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» គឺជាព្រះរាជសំណេរដើម និងមិនកែសម្រួល ដែលបង្ហាញអំពីព្រះរាជដំណើររបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ អមព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ យាងមកកាន់តំបន់រំដោះរណសិរ្សរួមជាតិកម្ពុជា នៅឆ្នាំ១៩៧៣។



ពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បោះពុម្ពដោយព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន៧០០នាក់មកពីភូមិទាំង៨នៃឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

តមក លោក លន់ លាងហេង មេឃុំគគរ ថ្លែងអំណរគុណដល់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបានចំណាយពេលវេលាចុះចែកសៀវភៅប្រវត្តិសាស្ត្រដ៏មានសារសំខាន់នេះ ជូនប្រជាពលរដ្ឋរស់នៅឃុំរបស់គាត់។ លោកមេឃុំ លន់ លាងហេង បន្តថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងឃុំគគរនៅតែចងចាំអំពីទុក្ខវេទនា និងការលំបាកដែលធ្លាប់ឆ្លងកាត់ក្នុងពេលសង្គ្រាម និងរបបខ្មែរក្រហម។ សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នឹងជួយរំឭកអំពីប្រវត្តិសាស្ត្រកម្ពុជាចេញពីព្រះរាជកំណត់ហេតុរបស់ ហ្វូងម៉ែ។

នៅក្នុងឱកាសនោះ លោក ភិន ដន អាយុ ៧៦ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម លើកឡើងនូវរឿងរ៉ាវរបស់ខ្លួនអំឡុងពេលដែលកងទ័ព លន់ នល់ បើកការវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហមថា នៅពេលបើកមើលរូបភាពក្នុងសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ធ្វើឲ្យខ្ញុំនឹកឃើញគ្រាដែលខ្ញុំ និងគ្រួសាររត់ភៀសខ្លួនចេញពីការទម្លាក់គ្រាប់នៅក្នុងឃុំគគរ នៅឆ្នាំ១៩៧៣។ បន្ទាប់មក ផ្ទះរបស់ខ្ញុំ និងអ្នកភូមិផ្សេងទៀត ត្រូវភ្លើងឆេះគ្មានសល់ឡើយ។ ពេលនោះគឺពិតជាលំបាកខ្លាំងណាស់ ដោយសារតែមានសង្គ្រាមគ្រប់ទីកន្លែង។ ដោយសារតែមើលមិនសូវច្បាស់ ខ្ញុំនឹងយកសៀវភៅនេះទៅឲ្យចៅរបស់ខ្ញុំអានឲ្យខ្ញុំស្តាប់ ដើម្បីអាចដឹងអំពីរឿងរ៉ាវនាពេលនោះបន្ថែមទៀត។

**ឌីន ហ្វាទីម៉ាស** អាយុ៦៣ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិកំពង់ក្របី ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម មានប្រសាសន៍ថា បន្ទាប់ពីខ្ញុំអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ធ្វើឲ្យខ្ញុំដឹងពីព្រឹត្តិការណ៍ដែលកើតឡើងក្នុងពេលសង្គ្រាម និងនឹកឃើញពីជីវិតរស់នៅក្នុងសម័យនោះ។ សៀវភៅនេះបានរំឭកខ្ញុំពីការរត់គេចខ្លួនពីការផ្ទុះឡើងនូវការប្រយុទ្ធគ្នា នៅឆ្នាំ១៩៧៣។ ភូមិសាស្ត្រដែលខ្ញុំរស់នៅសព្វថ្ងៃក៏ជាសមរភូមិក្តៅនៅពេលនោះដែរ។ ខ្ញុំអរគុណក្រុមការងារព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ដែលបានចែកសៀវភៅដ៏មានតម្លៃឲ្យខ្ញុំ។

# ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុ

## របស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៤៨នាក់ នៅភូមិឈើទាលជ្រុំ

ម៉ឿន ស្រីណុច និង ផ្សាំ ស្រីនីត



នៅព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៤៨ក្បាល ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនចំនួន ៤៨នាក់ ក្នុងនោះស្រី ២៨នាក់ រស់នៅភូមិឈើទាលជ្រុំ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(ធី គីមហុង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៤៨ក្បាល ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនចំនួន ៤៨នាក់ ក្នុងនោះស្រី ២៨នាក់ រស់នៅភូមិឈើទាលជ្រុំ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ជាកិច្ចចាប់ផ្តើមនៃកម្មវិធី លោក ព្រុំ នួន មេភូមិឈើទាលជ្រុំ បានឡើងថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដែលបានមកសួរសុខទុក្ខប្រជាពលរដ្ឋក្នុងភូមិឈើទាលជ្រុំ និងនាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុ







នៅព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៨៤ក្បាល ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនចំនួន ៨៤នាក់ ក្នុងនោះស្រី ២៨នាក់ រស់នៅភូមិឈើទាលជ្រុំ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(ធី គីមហុង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះរាជមាតាជាតិខ្មែរ មកចែកជូនប្រជាពលរដ្ឋក្នុងភូមិរបស់លោក។ លោក ព្រុំ នួន បានផ្តាំផ្ញើកូនក្មួយសិស្សានុសិស្សត្រូវព្យាយាមស្តាប់ ស្រាវជ្រាវ អានសៀវភៅនេះឲ្យចប់ ព្រោះអាចជាជំនួយដល់ការប្រឡងសញ្ញាបត្រទុតិយភូមិនៅឆ្នាំខាងមុខ។

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានឡើងណែនាំខ្លួន និងក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ព្រមទាំងសម្តែងការអរគុណដល់លោក ព្រុំ នួន និងប្រជាពលរដ្ឋដែលបានចូលរួមក្នុងកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះរាជមាតាជាតិខ្មែរនៅថ្ងៃនេះ។ មុនពេលចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» លោក ឡុង ដានីបានធ្វើការបង្ហាញអំពីទីតាំងមជ្ឈ-មណ្ឌលផ្សះផ្សាវាលវែង ស្ថិតនៅក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដែលចាប់បើកដំណើរការនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណងដូចខាងក្រោម ៖

១) ផ្សព្វផ្សាយពីប្រវត្តិសាស្ត្រសង្គ្រាម ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៧០-១៩៩០ ដល់ក្មេងៗជំនាន់ក្រោយឲ្យបានដឹងអំពីប្រវត្តិសាស្ត្រនៅក្នុងប្រទេសកម្ពុជា។

២) ពង្រឹងសន្តិភាពតាមរយៈការអប់រំដល់ក្មេងៗជំនាន់ក្រោយឲ្យបានដឹងពីផលវិបាកពេលប្រទេសជាតិមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ព្រមទាំងវិធីសាស្ត្រទប់ស្កាត់កុំឲ្យអំពើនេះកើតឡើងម្តងទៀត។

៣) ជំរុញឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចែករំលែកបទពិសោធន៍ និងរឿងរ៉ាវជីវិតដែលធ្លាប់ឆ្លងកាត់នៅក្នុងសម័យសង្គ្រាម និងរបបខ្មែរក្រហមដល់យុវជន។

៤) ជួយសម្របសម្រួលលើគម្រោង «ការ

លើកកម្ពស់សិទ្ធិ និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

តមកលោក ឡុង ដានី បានស្នើឲ្យយុវជនចំនួន ៤នាក់ឡើងអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះរាជមាតាជាតិខ្មែរ ដើម្បីឲ្យប្រជាពលរដ្ឋយល់ដឹងខ្លះៗអំពីព្រះរាជដំណើររបស់ហ្លួងម៉ែ និងសម្ដេចតា យាងមកប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៣។ ខ្លឹមសារក្នុងសៀវភៅកំណត់ហេតុនេះ បានបង្ហាញពីភាពទន់ភ្លន់ និងសេចក្ដីថ្លៃថ្នូររបស់ហ្លួងម៉ែ ព្រមទាំងព្រះរាជតម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនរបស់ហ្លួងម៉ែក្នុងព្រះរាជដំណើរពីទីក្រុងប៉េកាំងមកទីក្រុងហាណូយ បន្តព្រះរាជដំណើរដោយរថយន្តតាមផ្លូវលំហូជីមិញ ចូលមកកាន់ប្រទេសកម្ពុជា។ គោលបំណងក្នុងការចែកសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» នេះ ក៏ចង់ឲ្យយុវជនឈ្វេងយល់ពីរបៀបសរសេរ និងសារសំខាន់នៃកំណត់ហេតុផ្ទាល់ខ្លួនដែរ។

នៅព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន៤៤ក្បាល ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនចំនួន ៤៤នាក់ ក្នុងនោះស្រី ២៤នាក់ រស់នៅភូមិឈើទាលជ្រុំ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
( ធី គីម ហុង/មជ្ឈមណ្ឌលឯកសារកម្ពុជា )



ក្រោយចប់វិធីចែកសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះរាជមាតាជាតិខ្មែរ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឡើងមានមតិយោបល់ដូចខាងក្រោម ៖

**វ៉ែត រី** អាយុ ៥៩ឆ្នាំ មានប្រសាសន៍ថា «ខ្ញុំពិតជារំភើប និងសប្បាយចិត្តជាខ្លាំងដែលមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចុះមកបង្ហាញអំពីប្រវត្តិសាស្ត្រ និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះរាជមាតាជាតិខ្មែរ ដល់រូបខ្ញុំ និងអ្នកភូមិទាំងមូល ពិសេសក្មេងៗជំនាន់ក្រោយឲ្យយល់ដឹងអំពីប្រវត្តិសាស្ត្រ និងចងចាំអំពីដំណើរទស្សនកិច្ចរបស់ហ្លួងម៉ែ មកកាន់តំបន់រំដោះនៃប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៧៣»។

**អែម ឆើត** អាយុ៥៩ឆ្នាំ មានប្រសាសន៍ថា ខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលបានទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះរាជមាតាជាតិខ្មែរ ពីក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ ពេលខ្ញុំស្ដាប់ក្មួយៗអានកំណត់ហេតុរបស់សម្ដេចម៉ែរួចមក ខ្ញុំបានទទួលចំណេះដឹងច្រើនអំពីដំណើរយាងរបស់សម្ដេចទាំងទ្វេមកប្រទេសកម្ពុជា និងសង្គ្រាមក្នុងឆ្នាំ១៩៧៣ ។

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង យុវជននៅសង្កាត់កូនក្រៀល និង សង្កាត់បុស្សូវ

មេក ទិន



ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បាន ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនជំនាន់ក្រោយចំនួន៥០០នាក់ នៅសង្កាត់កូនក្រៀល និងសង្កាត់បុស្សូវ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង យុវជនជំនាន់ក្រោយចំនួន៥០០នាក់ នៅសង្កាត់កូនក្រៀល និងសង្កាត់បុស្សូវ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

ជាកិច្ចចាប់ផ្តើមលោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើបទបង្ហាញសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់ចៅសង្កាត់ រួមទាំងប្រជាជនដែលបានមកចូលរួមទាំង អំពីខ្លឹមសារ

សំខាន់ៗ ក្នុងព្រះរាជដំណើរទស្សនកិច្ចរបស់សម្តេចម៉ែ មកកាន់តំបន់រំដោះឆ្នាំ១៩៧៣។ ទ្រង់បានយាងទៅជួបមេដឹកនាំសំខាន់ៗជាច្រើនរូប ដូចជា ខៀវ សំផន ហូ នឹម ហូ យន់។ បន្ទាប់មក ក៏មានការបង្ហាញពីរូបភាពសម្តេចម៉ែ នៅក្នុងតំបន់តស៊ូ នៅតាមទំព័រនីមួយៗក្នុងសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ ឆ្លៀតឱកាសនោះ បណ្ឌិត លី សុខឃាង ស្នើទៅសិស្ស ប៊ិក បញ្ញា ភេទស្រី អាយុ១៨ឆ្នាំ គឺជាយុវជនស្ម័គ្រចិត្ត មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ឡើងអានសំណេរក្នុងសៀវភៅ ចាប់ផ្តើមពីព្រះរាជដំណើរទស្សនកិច្ចរយៈពេល១០ថ្ងៃ ត្រូវនឹងថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៣ ជូនអ៊ំពូមីងបានស្តាប់។

នៅផ្នែកចុងក្រោយនៃវេទិកានេះ ក៏មានការបង្ហាញនូវចំណាប់អារម្មណ៍ ក៏ដូចជាការយល់ឃើញរបស់ប្រជាជនដែលបានចូលរួមដូចខាងក្រោម ៖

**ហេង បូធី** ភេទប្រុស អាយុ៥៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិអូរខ្ទៅ ក្រុងសំរោង បានលើកឡើងថា «ខ្ញុំពិតជាមានការកោតសសើរដល់ទ្រង់ជាខ្លាំង ព្រោះមិនធ្លាប់មានរាជវង្ស ឬព្រះមហាក្សត្រីអង្គណាមួយ អាចសរសេរ កត់ត្រាអំពីប្រវត្តិសាស្ត្ររបស់ទ្រង់ដែលបានយាងទស្សនកិច្ចពីតំបន់មួយទៅកាន់តំបន់មួយនៅក្នុងទឹកដីតំបន់រំដោះបានទេ។ ទោះបីជាមានឧបសគ្គរាំរាំងលំបាកយ៉ាងណា ក៏ទ្រង់នៅតែមានស្មារតីចងចាំក្នុងការកត់ត្រាអំពីព្រឹត្តការណ៍



ដែលបានកើតឡើងដើម្បីឲ្យកូនចៅបានដឹង បានយល់រឿងហេតុដែលបានកើតឡើងលើទ្រង់ទាំងពីរក្នុងកំឡុងពេលយាងចូលតំបន់រំដោះ។

**ថន សាលួត** ភេទស្រី អាយុ៦២ឆ្នាំ បានរៀបរាប់ពីចំណាប់អារម្មណ៍របស់ខ្លួនថា «ខ្ញុំពិតជាមានការពេញចិត្តជាខ្លាំងពីទឹកចិត្តរបស់សម្តេចម៉ែ ដែលបានសរសេរសៀវភៅកំណត់ហេតុរបស់ទ្រង់ចែកជូនកូនចៅបានឈ្វេងយល់ និងបានដឹងពីការតស៊ូរបស់ទ្រង់ជាមួយសម្តេចឪក្នុងការយាងចូលមកតំបន់តស៊ូ ដើម្បីទាមទារសុខសន្តិភាពជូនរាស្ត្ររបស់ទ្រង់ និងឲ្យមានការរស់នៅប្រកបដោយភាពសុខសាន្ត។ លើសពីនេះទៅទៀតខ្ញុំបានដឹងថា ទ្រង់ក៏មានប្រវត្តិតស៊ូកម្សត់ដែលខិតខំតស៊ូក្នុងព្រៃអស់រយៈពេលជាយូរ។ ទ្រង់ពិតជាជួបការលំបាកខ្លាំងនៅក្នុងព្រៃដូចប្រជាជនខ្មែរដែរ។ តទៅថ្ងៃមុខ សៀវភៅនេះក៏អាចក្លាយជាបណ្ណាល័យសម្រាប់កូនចៅខ្ញុំរៀនសូត្របន្ថែម។

**ឆួក សឿន** ភេទប្រុស អាយុ៤២ឆ្នាំ គឺជាក្រុមប្រឹក្សាសង្កាត់កូនក្រៀល បានបង្ហាញនូវចំណាប់អារម្មណ៍ថា «ខ្ញុំពិតជាសប្បាយចិត្តជាខ្លាំងនៅពេលដែលបានទទួលសៀវភៅដ៏មានតម្លៃនេះ ព្រោះខ្លឹមសារ



ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បាន ចុះចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនជំនាន់ក្រោយចំនួន៥០០នាក់ នៅសង្កាត់កូនក្រៀល និងសង្កាត់បុស្បូវ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)









ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បាន ចុះចែក សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនជំនាន់ក្រោយចំនួន៥០០នាក់ នៅសង្កាត់កូនក្រៀល និងសង្កាត់បុស្សស្បូវ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងសៀវភៅ បានឆ្លុះបញ្ចាំងឲ្យឃើញពីប្រវត្តិសាស្ត្រជាក់ស្តែងរបស់ខ្មែរយើង ហើយប្រសិនបើសៀវភៅនេះ បានចែកជូនទៅដល់សិស្សានុសិស្សឲ្យបានទូលំទូលាយ គឺកាន់តែល្អប្រសើរ ឡើងថែមទៀត ដើម្បីឲ្យយុវជនជំនាន់ក្រោយកាន់តែយល់ដឹងបន្ថែមពីប្រវត្តិសាស្ត្រដ៏សម្បូរបែបរបស់ជាតិសាសន៍ខ្លួន។ ក្រោយពីខ្ញុំបានឃើញសៀវភៅ ព្រមទាំងរូបភាពទាំងនេះ ធ្វើឲ្យខ្ញុំនឹកឃើញទៅដល់ប្រទេសខ្មែរដែលមិនគួរណាមកជួបរបបផ្តាច់ការខ្មែរក្រហមបែបនេះទេ»។

**ស្វួន ធឿន** ភេទប្រុស អាយុ៤៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិអូរព្រាល សង្កាត់បុស្សស្បូវ ក្រុងសំរោង ខេត្តឧត្តរមានជ័យ រៀនរាប់ពីការយល់ឃើញផ្ទាល់ខ្លួនថា ខ្ញុំចាប់អារម្មណ៍ខ្លាំងជាមួយការសរសេររៀបរាប់ពីប្រវត្តិរបស់ទ្រង់ដែលបានធ្វើដំណើរយាងចូលមកកាន់តំបន់រំដោះក្នុងឆ្នាំ១៩៧៣ ដែលបានបង្ហាញពីភក្តីភាពរបស់ទ្រង់ចំពោះសម្តេចឪ ទោះបីជានៅក្នុងស្ថានភាពបែបណាក៏ទ្រង់តស៊ូទ្រាំលំបាកជាមួយសម្តេចតា ដែលជាបិតាជាតិខ្មែរដែរ។

**ជុំ សាខន** ភេទប្រុស អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិអូរប៉ុស្ស៊ី ក្រុងសំរោង បង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនថា បន្ទាប់ពីទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ខ្ញុំចាប់អារម្មណ៍ជាងគេនោះ គ្រង់ខ្លឹមសារឆ្នាំ១៩៧៣ ដែលទ្រង់បានសរសេរពីដំណើរទស្សនកិច្ចរបស់ទ្រង់ ចូលមកកាន់ដំបន់រំដោះដោយមិនខ្លាចញញើតអ្វីទាល់តែសោះ នេះបញ្ជាក់ឲ្យឃើញពីភាពអង់អាចរបស់ទ្រង់ស័ក្តិសមជាព្រះមហាក្សត្រីខ្មែរ។

**ទូច សារឿន** ភេទប្រុស អាយុ៧១ឆ្នាំ បច្ចុប្បន្នរស់នៅភូមិរំដួលដើងភ្នំ ក្រុងសំរោង បានបង្ហាញពីការយល់ឃើញរបស់ខ្លួនថា នៅក្នុងខ្លឹមសារ និងសំណេររបស់ទ្រង់ ខ្ញុំចងចាំថា ទ្រង់បានធ្វើដំណើរទៅដល់ភ្នំគូលែន ហើយយាងចេញពីភ្នំគូលែនទៅស្រែណូយ ត្រង់នេះហើយបានជាខ្ញុំមានការគោរពដឹងគុណដ៏ខ្ពង់ខ្ពស់ពីសម្តេចឪ និងសម្តេចម៉ែ ព្រោះប្រវត្តិសម្តេចឪពិតជាមានភាពស្រស់ស្អាតបរិសុទ្ធ។ ទ្រង់ទាំងទ្វេពិតជាមានចិត្តស្នេហាជាតិមាតុភូមិខ្មែរយ៉ាងពិតប្រាកដ។ ជាពិសេស ខ្ញុំចាប់អារម្មណ៍រូបភាពមួយចំនួនដែលមាននៅក្នុងសៀវភៅ ដូចជារូបសម្តេចម៉ែ និងសម្តេចឪ កាលពីវ័យក្មេង ពិតជាស្រស់សង្ហារ និងស្រស់ស្អាតរកអ្វីប្រៀបផ្ទឹមពុំបាន។

# ដំណើរទស្សនកិច្ចសិក្សាស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង

## ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុសិស្សវិទ្យាល័យ ហ៊ុន សែន ស្តន់

**សាំង ចាន់ធូ**



នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំឡើងដំណើរទស្សនកិច្ចសិក្សាស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុសិស្សចំនួន៥០នាក់មកពីវិទ្យាល័យ ហ៊ុន សែន ស្តន់ៗ
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំឡើងដំណើរទស្សនកិច្ចសិក្សាស្តីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុសិស្សចំនួន៥០នាក់មកពីវិទ្យាល័យ ហ៊ុនសែនស្តន់ៗ ដំណើរទស្សនកិច្ចសិក្សាធ្វើឡើងក្នុងគោលបំណងជំរុញដល់ការយល់ដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការចុះទៅកាន់ទីតាំងសម្លាប់ប្រជាជនក្នុងរបបខ្មែរក្រហម ទីតាំងទំនប់ខ្មែរក្រហម និងការស្តាប់សក្ខីកម្មរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមៗ ដំណើរ

ទស្សនកិច្ចសិក្សានេះបាននាំសិស្សានុសិស្សទាំងអស់ទៅកាន់ទីតាំងចំនួន៣ ដូចខាងក្រោម ៖

**ទីតាំងទី១) គឺចេតិយតម្កល់អដ្ឋិធាតុជនរងគ្រោះ** ដែលត្រូវបានសម្លាប់ក្នុងរបបខ្មែរក្រហម នៅវត្តសុគន្ធារាម ហៅ វត្តស្គន់។ ការចុះទៅកាន់ចេតិយតម្កល់អដ្ឋិធាតុជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅវត្តស្គន់ គឺបានផ្តោតលើប្រធានបទដែលត្រូវលើកពិភាក្សាអំពីការចងចាំពីជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ លោក ថេត ប៊ុនលីម គណៈកម្មការវត្តស្គន់ និយាយប្រាប់អំពីរឿងរ៉ាវទាក់ទងនឹងប្រជាជនត្រូវបានសម្លាប់ជុំវិញវត្តស្គន់ និងការប្រមូលឆ្អឹងដើម្បីតម្កល់ទុកទីកន្លែងមួយ ហើយក្រោយមកត្រូវបានយកមកដាក់នៅក្នុងចេតិយនេះ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រដ្ឋអំណាច អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ប្រជាជន និងសិស្សានុសិស្ស ចូលរួមប្រារព្ធទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ ប៉ុល ពត ដោយបានរៀបចំពិធីបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហមនៅចេតិយតម្កល់អដ្ឋិធាតុជនរងគ្រោះ ដើម្បីរំឭកដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម និងបង្កើនស្មារតីចងចាំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានៅក្នុងកម្រិតមូលដ្ឋាន។



នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំឡើងដំណើរទស្សនកិច្ចសិក្សាស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុសិស្សចំនួន៥០នាក់មកពីវិទ្យាល័យ ហ៊ុន សែន ស្គន់។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

**ទីតាំងទី២) គឺការចុះទៅកាន់ទំនប់ ៥កុម្ភៈ** ដែលជាទំនប់តំបន់៤២ ក្នុងរបបខ្មែរក្រហម។ ទំនប់៥កុម្ភៈ ត្រូវបានចាប់ផ្តើមកសាងនៅឆ្នាំ១៩៧៥ ដែលប្រជាជនថ្មី (១៧ មេសា) ត្រូវបានយកទៅលើកទំនប់នេះ។ ប្រជាជនថ្មីជាច្រើនត្រូវទទួលរងការលត់ដំ និងការយកទៅសម្លាប់ចោលនៅចម្ការស្វាយចន្ទីដែលមានចម្ងាយមិនឆ្ងាយប៉ុន្មានពីការដ្ឋានទំនប់នោះឡើយ។ ចាប់ពីឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨ ក្នុងអំឡុងពេលការគ្រប់គ្រងរបស់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី ប្រជាជននៅតំបន់៤២





រាប់ពាន់នាក់ ត្រូវបានប្រមូលផ្តុំ និងបញ្ជូនមកលើកទំនប់៥កុម្ភៈ។ ប្រជាជនដែលត្រូវបានបញ្ជូនមកការដ្ឋានទំនប់៥កុម្ភៈនេះ ទទួលរងការបង្ខំឲ្យធ្វើការងារគ្មានពេលសម្រាក ការហូបចុកមិនគ្រប់គ្រាន់, ការធ្លាក់ខ្លួនឈឺគ្មានថ្នាំព្យាបាល និងការចាប់យកទៅសម្លាប់ជាបន្តបន្ទាប់។

**ទីតាំងទី៣) គឺភ្នំហាន់ជ័យ** ដែលជាទីកន្លែងមានប្រជាជនរត់ភៀសខ្លួនចូលក្នុងព្រៃនៅភ្នំហាន់ជ័យ និងបង្កើតកម្លាំងតស៊ូប្រឆាំងនឹងការគ្រប់គ្រងរបស់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី។ ចន្លោះពីឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៨ ពេលកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី ចូលមកគ្រប់គ្រង, ការកាប់សម្លាប់កើតឡើងកាន់តែខ្លាំងឡើងៗ ក្នុងគ្រាមិនដឹងថាតើពេលណាត្រូវបានខ្មែរក្រហមមកពីភូមិភាគនិរតីចាប់យកទៅសម្លាប់ មានប្រជាជនមួយចំនួនបានរត់គេចខ្លួនចូលទៅក្នុងព្រៃនៅលើភ្នំហាន់ជ័យ។ ការរត់គេចខ្លួនរបស់ប្រជាជននាពេលនោះ គឺបង្ហាញអំពីការតស៊ូប្រឆាំងនឹងការធ្វើបាប និងការកាប់សម្លាប់ទៅលើប្រជាជនពីសំណាក់ខ្មែរក្រហមមកពីភូមិភាគនិរតី។ ក្រុមប្រជាជនដែលបានរត់គេចខ្លួនចូលក្នុងព្រៃនៅពេលនោះ ត្រូវបានខ្មែរក្រហមចោទប្រកាន់ថា ចោរព្រៃ ឬខ្មែរស។

ជាចុងក្រោយនៃដំណើរទស្សនកិច្ចសិក្សានេះ សិស្សានុសិស្សចូលរួមទាំងអស់ទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ម្នាក់មួយក្បាល ដើម្បីយកទៅសិក្សាឈ្វេងយល់ និងប្រើប្រាស់ជាឯកសារប្រវត្តិសាស្ត្ររបស់ខ្លួន។







នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំឡើងដំណើរទស្សនកិច្ចសិក្សាស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ដល់សិស្សានុសិស្សចំនួន៥០នាក់ មកពីវិទ្យាល័យហ៊ុន សែន ស្គន់។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំកម្មវិធីពិនិត្យសុខភាពបឋម និងវេទិកាពិគ្រោះយោបល់ផ្នែកសុខភាព

## ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ១២០ នៅខេត្តកំពង់ចាម

ស៊ាង ចិន្តា



ចន្លោះពីថ្ងៃទី៨ ដល់ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំកម្មវិធីពិនិត្យសុខភាពបឋម និងវេទិកាពិគ្រោះយោបល់ផ្នែកសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសរុបចំនួន១២០ ក្នុងនោះមានប្រុស៤៨នាក់ និងស្រី៧២នាក់ មកពីស្រុកចំនួន៣នៃខេត្តកំពង់ចាម គឺស្រុកជើងព្រៃ ស្រុកព្រៃឈរ និងស្រុកស្រីសន្ធរ។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ចន្លោះពីថ្ងៃទី៨ដល់ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំកម្មវិធីពិនិត្យសុខភាពបឋម និងវេទិកាពិគ្រោះយោបល់ផ្នែកសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសរុបចំនួន១២០ ក្នុងនោះមានប្រុស៤៨នាក់ និងស្រី៧២នាក់មកពីស្រុកចំនួន៣នៃខេត្តកំពង់ចាម គឺស្រុកជើងព្រៃ ស្រុកព្រៃឈរ និងស្រុកស្រីសន្ធរ។ វេទិកាដែលផ្តល់ការពិនិត្យសុខភាពបឋម និងពិគ្រោះយោបល់ផ្នែកសុខភាពនេះប្រព្រឹត្តទៅដោយមានការចូលរួមពីវេជ្ជបណ្ឌិត ឡាវ ហាវ៉ាន, ក្រុមនិស្សិតពេទ្យស្ម័គ្រចិត្ត គីម សុខសុធី, ម៉ាន់ សុឃីម និង ចន្ថា សិលារដ្ឋ ព្រម ទាំងក្រុមការងារគម្រោង«ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។

នៅក្នុងឆ្នាំ២០២៣នេះ អ្នកស្ម័គ្រចិត្តកម្ពុជានៃ

មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រចាំខេត្តកំពង់ចាម ចុះជួបសួរសុខទុក្ខ និងស្តាប់បទពិសោធន៍របស់អ្នករស់រានមានជីវិតសរុបចំនួន៤០៩នាក់ដែលរស់នៅស្រុកទាំង៥ក្នុងខេត្តកំពង់ចាម រួមមាន ស្រុកកំពង់សៀម, ស្រុកកោះសូទិន, ស្រុកស្រីសន្ធរ, ស្រុកជើងព្រៃ និងស្រុកព្រៃឈរ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបាននិយាយចែករំលែកអំពីស្ថានភាពសុខភាពបច្ចុប្បន្នរបស់ខ្លួន និងនិយាយប្រាប់អំពីបទពិសោធន៍ និងការបាត់បង់ក្នុងរបបខ្មែរក្រហម។

**សែម ស៊ីថា** អ្នកស្ម័គ្រចិត្តកម្ពុជា ដែលបានចុះជួបជាមួយអ្នករស់រានមានជីវិតក្នុងរបបខ្មែរក្រហមនៅស្រុកស្រីសន្ធរ បញ្ជាក់ថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅតែចងចាំមិនភ្លេចអំពីបទពិសោធន៍ដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។ វេទិកាដែលផ្តល់ការពិនិត្យសុខភាពបឋម និងពិគ្រោះយោបល់ផ្នែកសុខភាពនេះ គឺពិតជាសំខាន់សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលអាចដឹងអំពីស្ថានភាពសុខភាព និងក្រើនរំឭកអំពីការថែទាំសុខភាពរបស់ខ្លួន។

**ម៉ាន់ សុឃីម** និស្សិតពេទ្យស្ម័គ្រចិត្ត បានលើកឡើងថា «ក្រុមនិស្សិតពេទ្យស្ម័គ្រចិត្ត និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះពិនិត្យសុខភាពបឋម និងពិគ្រោះយោបល់ផ្នែកសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានអាយុចន្លោះពី ៥០-៨០ឆ្នាំ នៅស្រុកជើងព្រៃ ស្រុកព្រៃឈរ និងស្រុកស្រីសន្ធរ នៃខេត្តកំពង់ចាម»។ សុឃីម បន្តថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីស្រុកជើងព្រៃ និងស្រុកព្រៃឈរ ដែលមានអាយុចន្លោះពី៥០-៦០ឆ្នាំ ទទួលបានការពិនិត្យសុខភាពបឋម រួមមាន ការវាស់សម្ពាធឈាម វាស់កម្រិតជាតិស្ករក្នុងឈាម វាស់ជីពចរ វាស់ចង្វាក់បេះដូងដោយម៉ាស៊ីនECG និងវាស់អុកស៊ីសែនក្នុងឈាម។ ក្រោយពីការពិនិត្យសុខភាពបឋម គួបផ្សំនឹងការសាកសួរព័ត៌មានបន្ថែម យើងសង្កេតឃើញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនមានបញ្ហាសុខភាពទាក់ទងនឹងជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម ជំងឺក្រពះពោះវៀនរ៉ាំរ៉ៃ និងប្រហែល៥%ទៀតមានជំងឺថប់អារម្មណ៍។

ចំណែកឯអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកស្រីសន្ធរ ដែលមានអាយុចាប់ពី៦០-៨០ឆ្នាំ ទទួលបានការពិនិត្យសុខភាពបឋមដោយក្រុមនិស្សិតពេទ្យស្ម័គ្រចិត្ត។ មិនខុសពីស្រុកជើងព្រៃ និងព្រៃឈរ, អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកស្រីសន្ធរ មានបញ្ហាសុខភាពទាក់ទងការខ្វះជាតិស្ករច្រើនជាងមានជំងឺទឹកនោមផ្អែម។ ជាការសង្កេតឃើញ ពួកគាត់ភាគច្រើននៅមានការលំបាកច្រើន ដោយសារតែកង្វះខាតថវិកា ហើយភូមិដែលពួកគាត់រស់នៅគឺស្ថិតនៅឆ្ងាយពីកន្លែងផ្តល់សេវាពិនិត្យសុខភាព។ បន្ថែមលើនេះទៀត អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកស្រីសន្ធរ មិនមានការយល់ដឹងអំពីការថែទាំសុខភាព ដែលតម្រូវឲ្យលោកវេជ្ជបណ្ឌិត និងក្រុមនិស្សិតពេទ្យស្ម័គ្រចិត្តយើងពន្យល់គាត់អំពីការថែទាំសុខភាព និងការពិគ្រោះយោបល់ផ្នែកសុខភាពបន្ថែមទៀត។

កម្មវិធីនេះ មិនត្រឹមតែផ្តល់ការពិនិត្យសុខភាពបឋម និងការពិគ្រោះយោបល់ផ្នែកសុខភាពនោះទេ ប៉ុន្តែថែមទាំងផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនិយាយចែករំលែកនូវរឿងរ៉ាវជីវិតដែលខ្លួនចងចាំមិនភ្លេច និងគ្រាលំបាកនៅក្នុងរបបខ្មែរក្រហមរៀងៗខ្លួន។ ខាងក្រោមនេះ គឺជាសក្ខីកម្មរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ៖

**ឆាម បូទិន** អាយុ៦១ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មកពីភូមិអណ្តូងក្រាំង ឃុំស្រមរ ស្រុកជើងព្រៃ បង្ហាញអារម្មណ៍សប្បាយចិត្ត បន្ទាប់ពីទទួលបានការពិនិត្យសុខភាពបឋម និងចែករំលែករឿងរ៉ាវជីវិតក្នុងរបបខ្មែរក្រហមថា «នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានជម្លៀសមករស់នៅភូមិទី៧ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាមវិញ។ ខ្ញុំត្រូវបានចាត់ចូលក្នុងកងចល័តកុមារជំទង់។ កងចល័តកុមារជំទង់ចែកចេញជា២កង គឺកងកុមារមូលដ្ឋានចាស់ និងកងកុមារថ្មី។ ខ្ញុំត្រូវបានបញ្ជូនទៅលើកភ្លឺស្រែ និងរកបន្លែដាក់រោងបាយសហករណ៍។ ខ្ញុំត្រូវធ្វើការពីម៉ោង៦ព្រឹករហូតម៉ោង១១ព្រឹក និងធ្វើការបន្តពី







ចន្លោះពីថ្ងៃទី៨ ដល់ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំកម្មវិធីពិនិត្យសុខភាពបឋម និងវេទិកាពិគ្រោះយោបល់ផ្នែកសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសរុបចំនួន១២០ ក្នុងនោះមានប្រុស៤៨នាក់ និងស្រី៧២នាក់ មកពីស្រុកចំនួន៣នៃខេត្តកំពង់ចាម គឺស្រុកជើងព្រៃ ស្រុកព្រៃឈរ និងស្រុកស្រីសន្ធរ។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ម៉ោង១រសៀលដល់ម៉ោង៥ល្ងាច។ ប្រសិនបើខ្ញុំធ្វើការមិនរួចរាល់តាមផែនការទេ គឺខ្ញុំត្រូវធ្វើបន្តទាល់តែរួចទើបបានឈប់។ ចំណែកការហូបចុក គឺមិនគ្រប់គ្រាន់ទេ។ ខ្ញុំមានការលំបាកនៅខែវស្សា ព្រោះទឹកលិចកន្លែងស្នាក់នៅ។ មានតែទីទួលមួយប៉ុណ្ណោះដែលទឹកលិចមិនដល់។ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅវាយកណ្តុរ និងយាមស្រូវ។ អ្វីដែលខ្ញុំរន្ធត់ខ្លាំងនោះគឺ នៅចុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩ ខ្ញុំឃើញមនុស្សជាច្រើនត្រូវបានចាប់យកមកវាយសម្លាប់ចោល។ ហេតុការណ៍ដែលធ្វើឲ្យខ្ញុំកាន់តែរន្ធត់នោះគឺ កុមារផ្សេងទៀតដែលធ្វើការជាមួយខ្ញុំក្នុងកងកុមារជិទង់ ក៏ត្រូវបានយកទៅវាយសម្លាប់ចោលជាមួយឪពុកម្តាយដែលជាប្រជាជនថ្មីដែរ។ នៅពេលនោះ បងប្រុសរបស់ខ្ញុំក៏រងគ្រោះដែរ។ ខ្ញុំនៅតែចងចាំបងប្រុសរបស់ខ្ញុំ។ ខ្ញុំអាចរស់រានមានជីវិត បន្ទាប់ពីប្រទេសជាតិត្រូវបានរំដោះពីរបបខ្មែរក្រហម។ ខ្ញុំរីករាយក្នុងការរស់នៅជាមួយសន្តិភាពនាពេលបច្ចុប្បន្ន និងមិនចង់ឲ្យរបបនេះវិលត្រឡប់មកវិញម្តងទៀតទេ»។

**ជាវណ្ណា** អាយុ៧៦ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិបុស្សីស្រុក ឃុំបុស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម និយាយអំពីបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមថា «នៅពីក្មេង ខ្ញុំទៅរៀនសូត្ររហូតចប់បាក់ឌុប។ នៅឆ្នាំ១៩៧០ ក៏មានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ។ បន្ទាប់មក ខ្ញុំត្រូវបានជ្រើសរើសឲ្យចូលក្រុមកម៉្មង់ដូសិស្ស ប៉ុន្តែត្រូវបានឪពុករបស់ខ្ញុំមិនអនុញ្ញាតឲ្យខ្ញុំទៅធ្វើកុម៉្មង់ដូទេ ទើបក្រោយមកខ្ញុំឈប់រៀន និងមកនៅផ្ទះវិញ។ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាគ្រូបង្រៀនកុមារ។ ខ្ញុំបង្រៀនកុមារថ្នាក់ទី២ និងថ្នាក់ទី៣។ ការបង្រៀនរបស់ខ្ញុំ ចាប់ផ្តើមពីម៉ោង៧ព្រឹក ដល់ម៉ោង១១ព្រឹក ចំណែកឯពេលរសៀលគឺជាម៉ោងអនុវត្តដែលខ្ញុំត្រូវដឹកនាំកុមារទាំងអស់ទៅធ្វើពលកម្ម ដូចជា កាប់ពោត និងដឹកដំឡូង។ ខ្ញុំសូមបញ្ជាក់ថា មុនពេលមករៀន កុមារទាំងអស់ត្រូវងើបនៅម៉ោង៤ទៀបភ្លឺ ទៅកើបអាចម៍គោ។ អ្វីដែលខ្ញុំបង្រៀន គឺលេខ និងអក្សរខ្មែរ។ ខ្ញុំក៏ធ្លាប់ត្រូវបានបញ្ជូនឲ្យទៅរៀនវគ្គគរុកោសល្យដែរ។ ខ្ញុំគឺជា

ក្រុមលួងឆ្លងនាក់ក្នុងភូមិ និងមានរបបហូបគ្រប់គ្រាន់ៗ ទោះបីយ៉ាងណា ខ្ញុំបានបាត់បង់កូនម្នាក់ និងអ៊ុំមួយចំនួនក្នុងរបបខ្មែរក្រហមៗ អ្វីដែលខ្ញុំចង់ឲ្យក្មេងជំនាន់ក្រោយដឹងពីរបបខ្មែរក្រហមនោះគឺ គ្មានការអប់រំត្រឹមត្រូវនោះទេនៅពេលនោះ ហើយប្រជាជនត្រូវទទួលរងការលំបាក និងជិះជាន់កម្លាំងពលកម្ម»ៗ

**ទ៉ា គីមរៀន** អាយុ៦២ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិត្រពាំងបីដើម ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ចែករំលែកការចងចាំអំពីដំណើរជីវិតរបស់ខ្លួនក្នុងពេលសង្គ្រាម និងរបបខ្មែរក្រហមថា «កាលពីកុមារ ខ្ញុំមិនបានរៀនសូត្រទេពីព្រោះខ្ញុំពេញវ័យ នៅពេលដែលសង្គ្រាមផ្ទុះឡើងៗ នៅឆ្នាំ១៩៧៣ ពេលដែលសង្គ្រាមបានផ្ទុះឡើងខ្លាំង ខ្ញុំត្រូវបានដាក់ឲ្យចូលធ្វើការនៅកងចល័តនៅក្នុងតំបន់រំដោះម្តុំព្រៃស្រឡាចៗ នៅពេលនោះ មិនមានប្រជាជនរស់នៅជិតផ្លូវជាតិនោះឡើយៗ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានបញ្ជូនទៅលើកដីនៅតំបន់បឹងធំ និងការដ្ឋានមួយចំនួនទៀតនៅក្នុងស្រុកព្រៃឈរៗ នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការងារនៅចម្ការកៅស៊ូនៅតំបន់ស្វាយមាស ម្តុំស្រុកចំការលើ ខេត្តកំពង់ចាមៗ នៅចម្ការកៅស៊ូ ខ្ញុំត្រូវបានបង្រៀនឲ្យចៀរជ័រកៅស៊ូ និងដាំដំណាំជាច្រើនមុខទៀតៗ នៅក្នុងឆ្នាំ១៩៧៧ នៅពេលកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមក មានមនុស្សជាច្រើនត្រូវបានស្រាវជ្រាវ និងយកទៅសម្លាប់ចោលៗ ពេលខ្លះកម្មាភិបាលខ្មែរក្រហមមកពីនិរតីបានចុះមកចាប់ប្រជាជនទៅសម្លាប់ចោលនៅក្នុងចម្ការកៅស៊ូជ្រៅៗៗ ខ្ញុំបានរួចផុតជីវិតពីការចុះចាប់សម្លាប់នាពេលនោះ និងវិលត្រឡប់មករស់នៅភូមិកំណើតវិញ»ៗ

**ឈឹម ឈិន** អាយុ៧៧ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅភូមិប្ញស្សីស្រុក ឃុំប្ញស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម រំឭកអំពីការចងចាំពីរបបខ្មែរក្រហមថា «នៅពីក្មេង ខ្ញុំទៅរៀនសូត្ររហូតដល់ថ្នាក់ទី១ៗ នៅឆ្នាំ១៩៧៥ ខ្ញុំធ្វើជាគ្រូបង្រៀនកុមារនៅថ្នាក់ទី៥ៗ ក្នុងមួយថ្នាក់គឺមានកុមារសរុបចំនួន២៥-៣០នាក់ៗ នៅព្រឹកព្រលឹម ខ្ញុំត្រូវដឹកនាំកុមារទាំងអស់ទៅកើបអាចម៍គោតាមផ្ទះអ្នកភូមិៗ ខ្ញុំបង្រៀនកុមារអំពីលេខ និងអក្សរ ចាប់ពីម៉ោង៧ដល់ម៉ោង១១ព្រឹកៗ នៅពេលរសៀល គឺជាពេលចេញទៅឃ្វាលគោលៗ បទពិសោធន៍ដែលខ្ញុំចាំមិនភ្លេចនៅរបបខ្មែរក្រហម គឺការហូបតែបបររាវ»ៗ



ចន្លោះពីថ្ងៃទី៨ ដល់ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំកម្មវិធីពិនិត្យសុខភាពបឋម និងវេទិកាពិគ្រោះយោបល់ផ្នែកសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសរុបចំនួន១២០ ក្នុងនោះមានប្រុស៤៨នាក់ និងស្រី៧២នាក់ មកពីស្រុកចំនួន៣នៃខេត្តកំពង់ចាម គឺស្រុកជើងព្រៃ ស្រុកព្រៃឈរ និងស្រុកស្រីសន្ធរៗ
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំក្រញ៉ូងរៀបរាប់ពីរឿងរ៉ាវជីវិត

## ក្នុងរបបខ្មែរក្រហម បន្ទាប់ពីទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណាត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

ថុន ស្រីពេជ្រ



នៅក្នុងឱកាសខួបលើកទី៧០ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិខ្មែរ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» កំណាត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០៨នាក់ ក្នុងនោះមានស្រីចំនួន១៨០នាក់ រស់នៅឃុំក្រញ៉ូង ស្រុកកំចាយមារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឱកាសខួបលើកទី៧០ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិខ្មែរ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណាត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០៨នាក់ ក្នុងនោះមានស្រីចំនួន១៨០នាក់ រស់នៅឃុំក្រញ៉ូង ស្រុកកំចាយមារ ខេត្តព្រៃវែង។ គោលបំណងនៃកម្មវិធីចែកសៀវភៅនេះ គឺដើម្បីថែរក្សាប្រវត្តិសាស្ត្រ បង្កើនការចងចាំពីប្រវត្តិសាស្ត្រ និង ចូលរួមទប់ស្កាត់ការវិលត្រឡប់

មកវិញនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ស្ថិតនៅក្នុងបរិវេណវត្តចម្ការបេក និង វត្តកំចាយមារ លោក ខៀវ សុខុម ប្រធានឃុំក្រញ៉ូង បានឡើងមានមតិស្វាគមន៍ និងសំណេះសំណាលទៅកាន់អ្នកចូលរួមទាំងអស់គ្នា ព្រមទាំងថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបាននាំយកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ មកចែកជូនដល់ប្រជាជនក្នុងស្រុកកំចាយមារ។ ដោយសារតែកម្មវិធីត្រូវបានរៀបចំឡើងនៅក្នុងខែវិច្ឆិកា ដែលមានថ្ងៃទី៩ ខែវិច្ឆិកា គឺជាថ្ងៃនៃបុណ្យឯករាជ្យជាតិខ្មែរ លោកមេឃុំបានរំឭកឈ្មោះរបស់សម្តេចព្រះ នរោត្តម សីហនុ ដែលខិតខំប្រឹងប្រែងទាមទារឯករាជ្យពីបារាំងមកវិញ។ បន្ទាប់មកលោកមេឃុំ ក៏បានរំឭកពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលបានសម្លាប់ប្រជាជននៅក្នុងស្រុកកំចាយមារអស់ជាច្រើននាក់ ព្រមទាំងលើកឡើងអំពីអ្នករស់រានមានជីវិតរហូតមកដល់សព្វថ្ងៃនេះមានជំងឺបាក់ស្បាត និងភាគច្រើនជាអ្នកមិនសូវចេះអក្សរដោយសារតែនៅក្នុងរបបខ្មែរក្រហមពុំមានសាលារៀន។

## បទបង្ហាញខ្លីស្តីពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមុន និងក្នុងអំឡុងពេលនៃរបបខ្មែរក្រហម

ផ្សារភ្ជាប់ទៅនឹងសម្តីរបស់ប្រធានឃុំ ខៀវ សុខុម ដែលរំឭកឡើងវិញអំពីប្រវត្តិសាស្ត្រជាតិខ្មែរក្រហម លោក ផេង ពង្ស៉ីរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងក៏បានរៀបរាប់ពីប្រវត្តិរបស់សម្តេចព្រះ នរោត្តម សីហនុ ទាក់ទងនឹងការទាមទារឯករាជ្យពីបារាំងមកវិញដែរ។ លោក ផេង ពង្ស៉ីរ៉ាស៊ី បានបន្តថា នៅពេលនោះ សម្តេចព្រះ នរោត្តម សីហនុ បានបង្កើតកងជីវពលនារីក្លាហាន ដើរជាជួរ និងស្ពាយកាំភ្លើងឈើម្នាក់មួយដើម ពីភូមិមួយទៅភូមិមួយ ដើម្បីបន្ទាចដល់បារាំង។ នៅពេលនោះ ក៏មានចលនាខ្មែរឥស្សរៈកើតឡើងដែរ។ សម្តេចព្រះ នរោត្តម សីហនុ បានទាមទារឯករាជ្យ





នៅក្នុងឱកាសខួបលើកទី៧០ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិខ្មែរ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិ-សាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០៤នាក់ ក្នុងនោះមានស្រីចំនួន១៨០នាក់ រស់នៅឃុំក្រញ៉ូង ស្រុកកំចាយមារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីបារាំងមកវិញ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ បន្ទាប់ពីបានបកស្រាយអំពីប្រវត្តិសាស្ត្រសម័យបារាំងខាងលើ លោក ផេង ពង្ស៉ីរ៉ាស៊ី បានធ្វើបទបង្ហាញខ្លីទាក់ទងនឹងចំណុចមួយចំនួនដូចខាងក្រោម ៖

១) ព្រឹត្តិការណ៍ក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលប្រទេសកម្ពុជាបានជួបប្រទះនូវបញ្ហាលំបាកមួយចំនួនរួមមាន ប្រជាជនទាំងអស់ត្រូវបាត់បង់មេដឹកនាំជាទីស្រឡាញ់គឺ សម្តេចព្រះ នរោត្តម សីហនុ។ ប្រទេសកម្ពុជាត្រូវបានបែងចែកទឹកដីធ្វើឲ្យមានសង្គ្រាមប្រទាញប្រទង់គ្នារវាងកងទ័ពរំដោះខ្មែរក្រហម និងកងទ័ព លន់ នល់។ ប្រជាជនកម្ពុជា

កាប់សម្លាប់ និងបង្អួរឃ្លានគ្នា ដោយការធ្វើសង្គ្រាមជារៀងរាល់ថ្ងៃ ក្រោយថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០។

២) ការវិលត្រឡប់មកកម្ពុជាវិញរបស់សម្តេចព្រះនរោត្តម សីហនុ នៅខែមីនា ឆ្នាំ១៩៧៣ ដើម្បីរឹតចំណងសាមគ្គីភាពជាមួយប្រជាជន និងដើម្បីបង្ហាញទៅកាន់ពិភពលោកថា ព្រះអង្គបានបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ដោយមិនមានចិនជាខ្នងបង្អែក។ នៅគ្រានោះហើយ ដែលសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ បានកត់ត្រាកំណត់ហេតុប្រចាំថ្ងៃរបស់ទ្រង់អំឡុងពេលយាងចូលប្រទេសកម្ពុជារយៈពេលជាងមួយខែ រហូតដល់ថ្ងៃដែលព្រះអង្គយាងត្រឡប់ទៅកាន់ទីក្រុងប៉េកាំងវិញ។ សំណេររបស់ទ្រង់ ត្រូវបានបកប្រែពីភាសាបារាំងមកភាសាអង់គ្លេសដោយ លោក ឯកអគ្គរាជទូតបណ្ឌិត ហ្ជូលីយ៉ូ ដែលជ្រេស និងបកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរដោយក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា រួចហើយបោះពុម្ពចែកផ្សាយដល់បងប្អូនប្រជាជនកម្ពុជានៅទូទាំងប្រទេស។

នៅឱកាសនោះ លោក ផេង ពង្សរ៉ាស៊ី បានបង្ហាញអំពីការលាលែងពីតំណែងរបស់សម្តេចព្រះនរោត្តម សីហនុ ចេញពីប្រមុខរដ្ឋ នៅឆ្នាំ១៩៧៦។ លោក ផេង ពង្សរ៉ាស៊ី បន្ថែមថា សម្តេច សីហនុ ពុំជាប់ពាក់ព័ន្ធជាមួយនឹងការដឹកនាំប្រទេសនៅរបបខ្មែរក្រហមឡើយ នៅក្រោយឆ្នាំ១៩៧៦ដូចជាការសម្លាប់ប្រជាជន ការធ្វើទារុណកម្ម ការហូបចុកមិនគ្រប់គ្រាន់ និងការប្រើឲ្យប្រជាជនធ្វើការហួសកម្លាំងជាដើម។

## ការឯកភាពចំពោះការធ្វើបទបង្ហាញ

បន្ទាប់ពីការធ្វើបទបង្ហាញរបស់លោក ផេង ពង្សរ៉ាស៊ី បានបញ្ចប់ លោកមេឃុំបានសួរទៅកាន់អ្នកចូលរួមយ៉ាងដូច្នេះថា តើអ្នកទាំងអស់គ្នាឯកភាពចំពោះការធ្វើបទបង្ហាញរបស់លោក ផេង ពង្សរ៉ាស៊ី ដែរឬទេ? អ្នកចូលរួមកម្មវិធីទាំងអស់សម្តែងនូវការឯកភាពចំពោះការលើកឡើងខាងលើ។ ជាមួយគ្នានេះ ឆាន ម៉េត ភេទប្រុស អាយុ៧៦ឆ្នាំ និយាយថា លោក ផេង ពង្សរ៉ាស៊ី បានខកខានទាមអំពីប្រវត្តិសាស្ត្រខាងលើ ដូចទៅនឹងអ្វីដែលខ្ញុំបានដឹងកន្លងមក ដូចជាការបង្កើតចលនាខ្មែរឥស្សរៈ ដែលប្រទេសកម្ពុជាបានរើបម្រះចេញពីអាណានិគមនិយមបារាំង។ កាលនោះព្រះអង្គបានបង្កើតឲ្យមានកងជីវពលនារីក្លាហាននៅតាមមូលដ្ឋានដើម្បីបង្ហាញថា ខ្មែរខ្លាំងនិងក្លាក់វពុកៗ ចូលមកដល់សម័យសង្គ្រាមឆ្នាំ១៩៧០ និងសម័យ ប៉ុល ពត ប្រជាជនខ្មែរបានឆ្លងកាត់នូវបទពិសោធន៍ដ៏ល្វីងជូរចត់ និងកាប់សម្លាប់យ៉ាងឃោរឃៅ ។

## អំណានសៀវភៅសាក្សីប្រវត្តិសាស្ត្រ

តមក ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ឲ្យអ្នកចូលរួមម្នាក់មួយក្បាល។ អ្នកចូលរួមត្រូវបានផ្តល់ពេលវេលាចំនួន១៥នាទីក្នុងការ អានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ ខណៈនោះ លោក ឈាង ណាក់ មានអាយុ៦៥ឆ្នាំ រស់នៅភូមិស្នួល ឃុំក្រញ៉ូង ស្រុកកំចាយមារ ខេត្តព្រៃវែង ឡើងសួរអំពីថ្ងៃខែឆ្នាំដែលទ្រង់យាងត្រឡប់មកប្រទេសកម្ពុជា។ ភ្លាមៗនោះលោកគ្រូ ផេង ពង្សរ៉ាស៊ី ក៏បានឡើងបញ្ជាក់ពីពេលវេលានៃដំណើរទស្សនកិច្ចរបស់ទ្រង់ទាំងទ្វេ គឺចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៣ ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៣ ដែលមានរយៈពេល៣៩ថ្ងៃ។

## ការឡើងចាប់អារម្មណ៍ និងការចែករំលែកពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម

បន្ទាប់ពីអ្នកចូលរួមអាន សៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ចប់ លោក ផេង ពង្សរ៉ាស៊ី បានលើកទឹកចិត្តអ្នកចូលរួមស្ម័គ្រ ឡើងរៀបរាប់អំពីចំណាប់អារម្មណ៍ចំពោះការទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ក៏ដូចជាការចែករំលែក

ពីបទពិសោធន៍ផ្ទាល់ខ្លួនឆ្លងកាត់សម័យកាលខ្មែរក្រហម ៖

ខ្ញុំឈ្មោះ **ខេន គង់** ភេទស្រី អាយុ៧១ឆ្នាំ រស់នៅភូមិស្នួល ឃុំក្រញ៉ូង ស្រុកចាយមារ ខេត្តព្រៃវែង។ បន្ទាប់ពីមានព្រឹត្តិការណ៍ សោ ភឹម បះបោរ។ ខ្ញុំបានព្រួស្នូរកាំភ្លើងវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពខ្មែរក្រហមគ្នាឯង ធ្វើឲ្យខ្ញុំមិនបានដេកពួនឡើយ។ ក្រោយមក ក្រុមខ្មែរក្រហមដែលនិយាយរដឹនបានកៀងខ្ញុំឲ្យរត់ចូលក្នុងព្រៃ។ មួយខែក្រោយមក ទើបខ្ញុំដឹងថាប្រទេសត្រូវបានរំដោះចេញពីរបបខ្មែរក្រហមហើយ។ ថ្ងៃនេះ ខ្ញុំពិតជាមានការសប្បាយរីករាយណាស់ ព្រោះទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ ខ្ញុំនឹងយកសៀវភៅនេះឲ្យចៅរបស់ខ្ញុំអានបន្ត។ ចៅរបស់ខ្ញុំតែងតែសួរនាំខ្ញុំពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម។ ខ្ញុំអាចមើលអក្សរនៅក្នុងសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» បានខ្លះ។ ខ្ញុំសូមអរព្រះគុណដល់ហ្លួងម៉ែ ដែលបានសរសេរកំណត់ហេតុរបស់ទ្រង់ និងយកមកចែករំលែកដល់ប្រជាជនទាំងអស់គ្នា។ ខ្ញុំសូមថ្វាយព្រះពរឲ្យហ្លួងម៉ែ មានសុខភាពល្អ និងព្រះជន្មាយុយឺនយូរ។

ខ្ញុំឈ្មោះ **ថន បឿន** ភេទស្រី អាយុ៨១ឆ្នាំ រស់នៅភូមិចំការចេក២ ឃុំក្រញ៉ូង ស្រុកកំចាយមារ ខេត្តព្រៃវែង។ ខ្ញុំសប្បាយចិត្តនៅពេលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ទោះបីជាខ្ញុំមិនចេះអក្សរក្តី ប៉ុន្តែខ្ញុំនឹងយកទៅឲ្យចៅៗអានឲ្យស្តាប់ និងមើលរូបភាពរបស់សម្តេចព្រះនរោត្តម សីហនុ និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នៅក្នុងសៀវភៅនេះ។ ក្រោយពីបានស្តាប់ការពន្យល់របស់លោក ដេង ពង្សរ៉ាស៊ីរួចមក ធ្វើឲ្យខ្ញុំនឹករឭកពីការឈឺចាប់ និងការធ្វើបាបរបស់ខ្មែរក្រហមមកលើខ្ញុំ។ កាលនោះ ខ្ញុំពិបាកខ្លាំងណាស់ ព្រោះខ្មែរក្រហមបានជម្លៀសខ្ញុំទៅខេត្តកំពង់ធំ។ ពេលនោះកូនៗរបស់ខ្ញុំនៅតូចៗណាស់។ នៅពេលដែលខ្ញុំនឹកឃើញពីប្រវត្តិជូរចត់នេះម្តងៗ ធ្វើឲ្យខ្ញុំខឹង និងស្អប់ខ្មែរក្រហមជាខ្លាំង។ ខ្ញុំមិនចង់ឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញម្តងទៀតទេ។ នៅក្នុងរបប ខ្មែរក្រហម ខ្ញុំបានបាត់បង់បងប្អូនប្រុសចំនួន ២នាក់ ម្នាក់ឈ្មោះ អ៊ឹម និងម្នាក់ទៀត ឈ្មោះ អ៊ុន។ ខ្មែរក្រហមបានចាប់បងប្អូនរបស់ខ្ញុំយកទៅសម្លាប់ ដោយសារតែបងប្អូនរបស់ខ្ញុំធ្វើជាប្រធានភូមិពីសង្គម







នៅក្នុងឱកាសខួបលើកទី៧០ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិខ្មែរ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០៨នាក់ ក្នុងនោះមានស្រីចំនួន ១៨០នាក់ រស់នៅឃុំក្រញ៉ូង ស្រុកកំចាយមារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាស់ៗ ខ្ញុំសូមអរព្រះគុណសម្តេចម៉ែដែលបានផ្តល់ជាសៀវភៅនេះសម្រាប់ឲ្យកូនចៅបានអានៗ ខ្ញុំសូមថ្វាយព្រះពរសម្តេចម៉ែឲ្យមានព្រះជន្មាយុយឺនយូរ និងទទួលបានសេចក្តីសុខជារៀងរហូតៗ

ខ្ញុំឈ្មោះ **ឆាន ម៉េត** ភេទស្រី មានអាយុ៧៦ឆ្នាំ រស់នៅភូមិចម្ការចេក២ ឃុំក្រញ៉ូង ស្រុកកំចាយមារ ខេត្តព្រៃវែងៗ នៅសម័យសង្គ្រាម មានយន្តហោះទម្លាក់គ្រាប់បែកបណ្តាលឲ្យឆាបឆេះផ្ទះរបស់ប្រជាជន ហើយសម្តេច សីហនុបានទៅសាងសង់ផ្ទះឲ្យប្រជាជនឡើងវិញៗ នៅពេលដែល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ខ្ញុំមានអាយុ២៣ឆ្នាំៗ ក្រោយមកខ្ញុំបានឮសម្តេចព្រះ នរោត្តម សីហនុ ប្រកាសឲ្យកូនចៅរត់ចូលព្រៃម៉ាគី ហើយទន្ទឹមនោះក៏ស្រាប់តែលេចចលនាខ្មែរក្រហមឡើងៗ ចូលមកដល់របបខ្មែរក្រហម ខ្ញុំបានរត់គេចខ្លួនអំឡុងពេលដែលខ្មែរក្រហមដេញចាប់ប្រធានកងនៅតាមមូលដ្ឋានៗ ក្រោយមកខ្មែរក្រហមកៀងខ្ញុំឲ្យចូលទៅក្នុងព្រៃ និងរស់នៅលំបាកវេទនាៗ ក្រោយពេលកងទ័ពវៀតណាមចូលមកខ្ញុំក៏វិលត្រឡប់មកភូមិវិញៗ



នៅក្នុងឱកាសខួបលើកទី៧០ឆ្នាំ នៃទិវាបុណ្យឯករាជ្យជាតិខ្មែរ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង រៀបចំកម្មវិធីចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ២០៤នាក់ ក្នុងនោះមានស្រីចំនួន ១៨០នាក់ រស់នៅឃុំក្រញ៉ូង ស្រុកកំចាយមារ ខេត្តព្រៃវែងៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀនស្តីអំពី «របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទំនាក់ទំនងការបរទេស» សម្រាប់សិស្សវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន មេមត់

សុភក្ត្រ ភាណា



នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាថ្នាក់រៀន ស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ និង ទំនាក់ទំនងការបរទេស ដោយមានសិស្សានុសិស្ស ចំនួន៤៥នាក់ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន មេមត់ មកចូលរួម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង ទំនាក់ទំនងការបរទេស ដោយមានសិស្សានុសិស្ស ចំនួន៤៥នាក់ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន មេមត់ មកចូលរួម។

គោលបំណងនៃវេទិកាថ្នាក់រៀនថ្ងៃនេះ គឺផ្តល់ឲ្យសិស្សានុសិស្សនូវការយល់ដឹងទូលំទូលាយ លើបរិបទប្រវត្តិសាស្ត្រ និងទំនាក់ទំនងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្លឹមសារដែលលើកយកមកបង្ហាញក្នុងថ្ងៃនេះ គឺផ្តោតទៅលើទំនាក់ទំនងការបរទេសទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

អ្នកស្រី សុភក្ត្រ ភាណា គឺជាគ្រូឧទ្ទេស បានផ្តល់នូវព័ត៌មានដោយសង្ខេប លើការប្រាស្រ័យទាក់ទងផ្លូវទូតរបស់ប្រទេសកម្ពុជា ជាមួយប្រទេសជិតខាង,



នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាថ្នាក់រៀន ស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ និង ទំនាក់ទំនងការបរទេស សម្រាប់សិស្សានុសិស្ស ចំនួន៨៥នាក់ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ស្ថាប័នអន្តរជាតិ និងប្រទេសមានឥទ្ធិពលដទៃទៀត នៅក្រោមការដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្លឹមសារមេរៀន ត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ តាមរយៈព័ត៌មានប្រវត្តិសាស្ត្រ, ឧទាហរណ៍ និងរូបភាពជំនួយនានា។

បន្ទាប់មកអ្នកស្រី សុភ័ក្ត្រ ភាណា បានបង្កើតសកម្មភាពសិក្សា ពិភាក្សា ដល់សិស្សានុសិស្ស តាមរយៈការចែករំលែកចំណេះដឹង និងការយល់ឃើញរបស់ខ្លួន ព្រមទាំងលើកទឹកចិត្តឲ្យសិស្សចោទសួរជាសំណួរ, ចែករំលែកមតិយោបល់ និងចូលរួមជជែកវែកញែកៗ វិធីសាស្ត្រជំរុញនូវការសិក្សាយ៉ាងសកម្មនេះ ញ៉ាំងឲ្យសិស្ស កែប្រែទម្លាប់ពីអ្នកត្រង់ត្រាប់ស្តាប់ពីគ្រូ ទៅជាអ្នកចូលរួមចំណែកយ៉ាងសកម្មនៅក្នុងដំណើរការរៀនសូត្រវិញ។

នៅចុងបញ្ចប់នៃថ្នាក់រៀន សិស្សានុសិស្សទទួលបានចំណេះដឹងច្រើនជាងមុន ពាក់ព័ន្ធនឹងប្រវត្តិ-សាស្ត្រ និងទំនាក់ទំនងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ សិស្សានុ-សិស្ស អាចវិភាគ និងវាយតម្លៃអំពីឥទ្ធិពលនៃការចូលរួមពីអន្តរជាតិ ទៅលើស្ថានភាពនយោបាយ និងសង្គមនៃប្រទេសកម្ពុជា ហើយវេទិកាថ្នាក់រៀននេះក៏បានផ្តល់ឲ្យសិស្សានុសិស្សនូវការយល់ឃើញទូលំទូលាយជាងមុន លើបរិបទប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ថែមទៀតផង។

# នួន យាង ៖ កងចល័តនៅឃុំព្រៃកណ្ដៀង

ភា វស្នី



នួន យាង អាយុ៦៦ឆ្នាំ រស់នៅភូមិចាន់ ឃុំព្រៃកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ នួន យាង ភេទស្រី អាយុ៦៦ឆ្នាំ កើតនៅភូមិចាន់ ឃុំព្រៃកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ សុខ នួន និងម្ដាយឈ្មោះ ស៊ុម ឡុង និងមានបងប្អូនចំនួន៤នាក់ គឺស្រី២នាក់ និងប្រុស២នាក់។ ជំនាន់មុន គ្រួសាររបស់ខ្ញុំប្រកបរបបធ្វើស្រែ ហើយឪពុកធ្វើជាជំទប់ទី១ឃុំព្រៃកណ្ដៀង។

កាលពីក្មេងខ្ញុំចូលរៀនបានត្រឹមថ្នាក់ទី២នៅសាលាវត្តពោធិ៍សិរី ហៅវត្តភូមិចាន់។ នៅអាយុ១៧ឆ្នាំ គ្រួសារខ្ញុំភៀសខ្លួនទៅតាមទាហានវៀតយា (វៀតណាមខាងជើង) ទៅរស់នៅភូមិវាលអូ ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង ព្រោះនៅភូមិចាន់មានការទម្លាក់គ្រាប់បែក និងប្រយុទ្ធគ្នាញឹកញាប់។ ក្រោយមក ប្រធានសហករណ៍ចែកដីឲ្យគ្រួសាររបស់ខ្ញុំ ហើយយើងធ្វើស្រែបានផលល្អណាស់។ ផលស្រូវដែលគ្រួសារខ្ញុំប្រមូលបាន គ្រួសាររបស់ខ្ញុំបានចែកទៅឲ្យខាងកងទ័ពរំដោះខ្លះ និងទុកខ្លួនឯងខ្លះ។ ពេលគ្រួសាររបស់ខ្ញុំទៅរស់នៅភូមិវាលអូ នៅពេលដំបូងៗ គឺមានជីវភាពលំបាកខ្លះដែរ ព្រោះមានតែទិន្នផលស្រូវ ប៉ុន្តែមិនមានប្រាក់សម្រាប់ទិញម្ហូបអាហារ។ បន្ទាប់ពីឪពុករបស់ខ្ញុំធ្វើកណ្ដៀវលក់ ទើបជីវភាពគ្រួសាររបស់ខ្ញុំបានប្រសើរជាងមុន។ ពេលរស់នៅភូមិវាលអូ បានមួយរយៈ ឪពុករបស់ខ្ញុំបានធ្លាក់ខ្លួនឈឺស្លាប់ ដោយសារជំងឺបុសដូងប្រមុះ និងមិនមានថ្នាំព្យាបាល។ ក្រោយពេលឪពុកខ្ញុំស្លាប់ ខ្ញុំនិងម្ដាយបានទៅរស់នៅជាមួយបង នួន ឡុង និងគ្រួសាររបស់គាត់ ហើយបានជួយធ្វើស្រែគាត់ដើម្បីចិញ្ចឹមជីវិត។

មុនពេលកងទ័ពរំដោះខ្មែរក្រហមទទួលជ័យជម្នះលើរបប លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំបានត្រឡប់មករស់នៅភូមិចាន់វិញ និងប្រកបរបបធ្វើស្រែធម្មតា។ ក្រោយមកខ្ញុំបានជួយសែងកងទ័ពបដិវត្តន៍ខ្មែរក្រហមដែលរងរបួស និងស្លាប់ពេលវាយប្រយុទ្ធតទល់នឹងកងទ័ពវៀតណាមនៅសមរភូមិពាមរក៍។ ខ្ញុំទៅសែងកងទ័ពដែលរបួស និងស្លាប់ពីខាងភូមិព្រៃកំពែង យកទៅភូមិព្រៃអង្កុញ។

បន្ទាប់មកអង្គការបានរៀបការឲ្យខ្ញុំ ដែលថ្ងៃរៀបការរបស់ខ្ញុំនោះ អង្គការក៏បានរៀបការឲ្យមិត្តនារីនិងបុរសចំនួន១២គូផ្សេងទៀត។ ប្ដីរបស់ខ្ញុំ

ឈ្មោះ អឿ តូច រស់នៅភូមិស្គន់ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ប៉ុន្តែគាត់ចូលធ្វើជាកងទ័ពបដិវត្តន៍ខ្មែរក្រហម ហើយមករស់នៅជាមួយឪពុកម្ដាយធម៌ឈ្មោះ យួន លៀង នៅខេត្តព្រៃវែង។ ការរៀបការរបស់ខ្ញុំមានរយៈពេលមួយព្រឹក និងមានការហូបអាហារជុំគ្នាបន្តិចបន្តួច។ ពេលចូលមករស់នៅភូមិចាន់ដំបូង អង្គការចែករបបអង្ករឲ្យម្នាក់កន្លះគីឡូ ប៉ុន្តែដោយសារបងស្រីរបស់ខ្ញុំឈ្មោះ នួន សយ ធ្វើការនៅកងបុកស្រូវ ទើបអាចលួចអង្ករខ្លះយកមកហូបបន្ថែម។ ក្រោយមក ខ្ញុំបានចូលធ្វើការនៅក្នុងកងចល័តឃុំព្រៃកណ្ដៀង និងត្រូវបានចាត់តាំងឲ្យដើរស្ទូង ដក ច្រូតកាត់ និងលើកប្រព័ន្ធប្រឡាយនៅក្នុងឃុំព្រៃកណ្ដៀង។ ខ្ញុំធ្វើការនៅកងចល័តមិនបានយូរប៉ុន្មានទេ ព្រោះខ្ញុំសន្លប់ជាញឹកញាប់ ទើបបងស្រីរបស់ខ្ញុំឈ្មោះ នួន សយ យកមកភូមិចាន់វិញ។ ក្រោយមក ខ្ញុំបានចូលធ្វើការនៅក្នុងកងបុកស្រូវនៅក្នុងភូមិ ក្រោមការគ្រប់គ្រងរបស់ឈ្មោះ ញៀវ គាត់ដែលត្រូវជាបងប្អូនជីដូនមួយខ្ញុំ។ ខ្ញុំមិនសូវធ្វើការប៉ុន្មានទេ ព្រោះអាការជំងឺរបស់ខ្ញុំរើ ឡើងស្ទើររាល់ថ្ងៃ ហើយពេលខ្លះ ខ្ញុំត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យតំបន់ ស្ថិតនៅភូមិស្ដៅ។ នៅសម័យខ្មែរក្រហម ប្រធានកងតែងតែធ្វើការទិតៀនខ្ញុំ ព្រោះខ្ញុំមានជំងឺនិងមិនសូវបានធ្វើការ ប៉ុន្តែសំណាងល្អ បងរបស់ខ្ញុំឈ្មោះ នួន សយ ធ្វើជាប្រធានសហករណ៍បានជួយខ្ញុំ។

ក្រោយពេលរបបខ្មែរក្រហមដួលរលំ នៅដើមឆ្នាំ១៩៧៩ ខ្ញុំប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមកូនប្រុស២នាក់។ នៅឆ្នាំ១៩៨០ ប្ដីរបស់ខ្ញុំបានចូលធ្វើកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងមិនដែលត្រឡប់មកផ្ទះវិញទេ។ ក្រោយមកខ្ញុំបានទទួលដំណឹងថា ប្ដីរបស់ខ្ញុំមានប្រពន្ធមួយទៀតនៅស្រុកកំណើតរបស់គាត់។ រំលងមកមិនបានប៉ុន្មាន កូនប្រុសរបស់ខ្ញុំឈ្មោះ ទូច ឈន់ កើតពិសហើយស្លាប់។ ខ្ញុំរស់នៅធ្វើស្រែចូលគ្នាជាមួយបងស្រីរបស់ខ្ញុំឈ្មោះ នួន សយ និងប្ដីរបស់គាត់ឈ្មោះ ព្រំ រ៉ន។ សព្វថ្ងៃ ខ្ញុំរស់នៅតែពីរនាក់កូនប្រុសរបស់ខ្ញុំឈ្មោះ ទូច ទន់។



វាលស្រែ និងផ្លូវលំនៅឃុំព្រៃកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សុខ រី ៖ ប្រធានក្រុមដឹកនាំប្រជាជនក្នុងភូមិធ្វើការនៅក្នុងរបបខ្មែរក្រហម

ភា រស្មី



សុខ រី ភេទប្រុស អាយុ៧៦ឆ្នាំ រស់នៅភូមិចាន់ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សុខ រី ភេទប្រុស អាយុ៧៦ឆ្នាំ កើតនៅភូមិចាន់ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ សព្វថ្ងៃខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ សុខ ឈួន និងម្តាយឈ្មោះ ឡុង ស៊ុំ ព្រមទាំងមានបងប្អូន៥នាក់ គឺស្រី២នាក់ និងប្រុស៣នាក់ ប៉ុន្តែសព្វថ្ងៃបងប្អូនរបស់ខ្ញុំ នៅរស់តែ៣នាក់ តែប៉ុណ្ណោះ។ កាលពីសង្គមចាស់គ្រួសាររបស់ខ្ញុំមានជីវភាពមធ្យម និងមានអាហារហូបគ្រប់គ្រាន់ ព្រោះមានដីសម្រាប់ធ្វើស្រែ ប៉ុន្តែឪពុកម្តាយរបស់ខ្ញុំមិនមានប្រាក់បញ្ជូនកូនឲ្យរៀនបានខ្ពង់ខ្ពស់ឡើយ។

ខ្ញុំចាប់ផ្តើមចូលរៀនដំបូងនៅថ្នាក់ទី១២ សង្គមចាស់ជាមួយព្រះសង្ឃនៅក្នុងវត្តពោធិ៍សិរីហៅ វត្តភូមិចាន់។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ ក៏ឈប់រៀន ហើយទៅជួយធ្វើស្រែឪពុកម្តាយវិញ។ នៅឆ្នាំ១៩៦៦ ខ្ញុំបានរៀបការជាមួយប្រពន្ធទី១របស់ខ្ញុំនៅភូមិតាធាវ ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ពេលរស់នៅភូមិតាធាវ គ្រួសាររបស់ខ្ញុំប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត ប៉ុន្តែជីវភាពគ្រួសាររបស់ខ្ញុំនៅតែមានការខ្វះខាតដដែល។ ទន្ទឹមនឹងនោះ ក៏មានយន្តហោះមកទម្លាក់គ្រាប់បែកណាប៉ាល់នៅក្នុងភូមិ ព្រោះសង្ស័យថា មានកងទ័ពរំដោះខ្មែរក្រហមលាក់ខ្លួន។

ខ្ញុំចាំបានថាថ្ងៃមួយនៅពេលដែលខ្ញុំនៅវាលស្រែ ស្រាប់តែមានយន្តហោះមកទម្លាក់គ្រាប់ណាប៉ាល់បណ្តាលឲ្យឆេះ។ ឃើញស្ថានភាពមិនស្រួល ខ្ញុំបានរត់ចូលក្នុងត្រង់សេក្បែរនោះ ប៉ុន្តែឈ្មោះ ឆែម ដែលលាក់ខ្លួនក្នុងត្រង់សេស្ថិតនៅចម្ងាយប្រមាណ១០០ម៉ែត្រពីខ្ញុំ ត្រូវបានសាំងក្នុងគ្រាប់ណាប៉ាល់ហូរចូលក្នុងត្រង់សេបណ្តាលឲ្យឆេះស្លាប់។ ក្រោយហេតុការណ៍នោះ គ្រួសាររបស់ខ្ញុំបានភៀសខ្លួនទៅរស់នៅទ័ពស្តេច ស្ថិតនៅក្នុងឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែងដើម្បីគេចពីសមរភូមិប្រយុទ្ធ។ តួនាទីរបស់ខ្ញុំពេលទៅនៅទ័ពស្តេច គឺធ្វើជាប្រធានក្រុមដឹកនាំប្រជាជនធ្វើការ ហើយជាញឹកក្រុមរបស់ខ្ញុំបានជួយសែងកងទ័ពរំដោះខ្មែរក្រហមដែលរងរបួសឬស្លាប់ពេលប្រយុទ្ធគ្នានៅសមរភូមិពាមរក៍ យកទៅដាក់នៅភូមិក្បែរនោះ។ នៅពេលនោះ ប្រពន្ធ

របស់ខ្ញុំតែងតែដាំបាយ ប្រកស្មុគស្មឹកគ្រោត ឬយកស្រូវអង្ករដែលធ្វើបានទៅចែកឲ្យកងទ័ពរំដោះខ្មែរក្រហមនៅសមរភូមិ។

នៅឆ្នាំ១៩៧៥ ខ្ញុំបានសុំអង្គការមករស់នៅក្នុងភូមិចាន់វិញ ប៉ុន្តែពេលមកដល់ បងប្រុសរបស់ខ្ញុំដែលជាប្រធានសហករណ៍មិនឲ្យខ្ញុំនៅឡើយ ព្រោះខ្ញុំដឹកនាំក្រុមគ្រួសារផ្សេងទៀតមកច្រើនពេក។ ដូច្នេះក្រុមរបស់ខ្ញុំ ដែលមានសមាជិកប្រមាណ៣០គ្រួសារបានទៅរស់នៅភូមិដូង ឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង។ នៅភូមិដូងខ្ញុំបន្តធ្វើជាប្រធានក្រុមដដែលដើម្បីដឹកនាំប្រជាជនធ្វើស្រែ ហើយភាគច្រើន គឺធ្វើស្រែប្រាំង។ ពេលខ្ញុំធ្វើជាប្រធានកង ខ្ញុំត្រូវបានថ្នាក់លើធ្វើការទិតៀនច្រើនដងដោយសារខ្ញុំប្រាប់ប្រជាជនឲ្យកុហកអង្គការពេលធ្វើប្រវត្តិរូប ដោយដាក់ថា មិនមានសមាជិកគ្រួសារធ្វើទាហានឬគ្រូបង្រៀនឡើយ ជាពិសេសឲ្យប្រជាជនលាក់មាសទុកនៅពេលដែលអង្គការសួររក។ សំណាងល្អ ខ្ញុំមានទំនាក់ទំនងល្អជាមួយប្រធានកងធំឈ្មោះ ឆុន ហៅ ស្រាំង ទើបខ្ញុំបានរួចខ្លួនពីការទិតៀន។ នៅក្នុងសម័យខ្មែរក្រហម ខ្ញុំធ្លាប់ឈឺគ្រុនញាក់ពីរដង និងបានទៅសម្រាកនៅពេទ្យភូមិស្តៅដែលជាពេទ្យតំបន់២៤។ អំឡុងពេលព្យាបាល ខ្ញុំបានជួបឈ្មោះ ពីង ដែលជាប្រធានពេទ្យ ទើបខ្ញុំទទួលបានថ្នាំចាក់ល្អៗ និងឆាប់បានជាសះស្បើយត្រឡប់មកផ្ទះវិញ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំភ្លាមៗ នៅឆ្នាំ១៩៧៩ ខ្ញុំបានបបួលអ្នកភូមិ៥នាក់ ទៅរកដំឡូងនៅទួលជ្រៃ។ មូលហេតុដែលខ្ញុំដឹងថានៅទួលជ្រៃមានដំឡូង ពីព្រោះខ្ញុំធ្លាប់ទៅទីនោះ និងឃើញមានដំឡូងច្រើន។ ពេលទៅដល់ ស្រាប់តែខ្ញុំឃើញមានឈាមនៅមាត់រណ្ដៅ ហើយដើមឈើដែលដុះក្បែររណ្ដៅក៏សឹកសម្បកអស់ដែរ ព្រោះឈ្លបខ្មែរក្រហមចោកមនុស្សខ្ទប់នឹងដើមឈើនោះ។ ពេលឃើញទិដ្ឋភាពបែបនោះ យើងនាំគ្នាត្រឡប់មកផ្ទះវិញ ហើយខ្ញុំលែងហ៊ានទៅទីនោះ។ មួយថ្ងៃក្រោយមក ខ្ញុំបានត្រឡប់មកភូមិចាន់ដើម្បីពឹងពាក់បងប្អូននៅក្នុងភូមិឲ្យយករទេះចំនួន៣គ្រឿងទៅដឹកផ្ទះរបស់ខ្ញុំ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានត្រឡប់មករស់នៅភូមិចាន់វិញ រហូតដល់បច្ចុប្បន្ន។ បន្ទាប់ពីប្រទេសកម្ពុជា ត្រូវបានរំដោះបានរយៈពេល៨ឆ្នាំ ប្រពន្ធរបស់ខ្ញុំក៏ស្លាប់ ហើយក្រោយមកខ្ញុំបានរៀបការជាមួយប្រពន្ធមួយទៀតឈ្មោះ ទូច យ៉ា ប៉ុន្តែមិនមានកូនទេ។



ផ្លូវនៅក្នុងឃុំព្រៃកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ុច ហាំ ៖ ប្រជាជនក្នុងភូមិរើសអើង ព្រោះខ្ញុំមានប្តីធ្វើជាទាហាន លន់ នល់

ភា រស្មី



អ៊ុច ហាំ អាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រៃអន្ទុញ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ុច ហាំ ភេទស្រី អាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រៃអន្ទុញ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ ហែម អ៊ុច និងម្តាយឈ្មោះ លឹម ហម ព្រមទាំងមានបងប្អូនចំនួន៦នាក់ គឺស្រី៣នាក់ និងប្រុស៣នាក់។ ឪពុកម្តាយរបស់ខ្ញុំបានស្លាប់ចោលខ្ញុំតាំងពីខ្ញុំនៅក្មេង ហើយខ្ញុំត្រូវរស់នៅជាមួយបងស្រីរបស់ខ្ញុំម្នាក់ទៀត ដោយប្រកបរបរធ្វើស្រែ។ នៅអាយុ១៥ឆ្នាំ ខ្ញុំបានចូលរៀនថ្នាក់អក្ខរកម្មនៅផ្ទះម្តាយមីង រហូតចេះអានអក្សរបានបន្តិចបន្តួច។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពេលមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីតំណែងប្រមុខរដ្ឋ ហើយរដ្ឋាភិបាលថ្មីចាប់ផ្តើមជ្រើសរើស និងប្រមូលកម្លាំងយុវជននៅក្នុងភូមិរបស់ខ្ញុំ ដើម្បីហ្វឹកហាត់ក្បួនទ័ព។ អំឡុងពេលនោះខ្ញុំមាននាទីជាប្រធានខ គ្រប់គ្រងមនុស្ស២០នាក់។ ក្រុមរបស់ខ្ញុំបានហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយោធា ដូចជា ហាត់ចោលគាំបិត វាយដោយដៃ បោកចំបាប់ បាញ់លូនក្រាប ហើយគ្រូបង្វឹកគឺជាជនជាតិវៀតណាម និងមានជនជាតិខ្មែរចាំបកប្រែ។

នៅឆ្នាំ១៩៧១ បងស្រីរបស់ខ្ញុំបានរៀបការឲ្យខ្ញុំជាមួយបងប្អូនសាច់ញាតិឆ្ងាយម្នាក់ឈ្មោះ ប៉ុល ម៉ែន ធ្វើទាហាននៅខេត្តរតនគិរី។ ជិតដល់ថ្ងៃរៀបការ ឪពុកក្មេករបស់ខ្ញុំបានទៅតាមកូនប្រុសរបស់គាត់ឲ្យមករៀបការ ប៉ុន្តែ ម៉ែន មិននៅបន្ទាយទេ ព្រោះត្រូវបានអង្គភាពបញ្ជូនទៅប្រទេសវៀតណាម។ ថ្ងៃរៀបការរបស់ខ្ញុំគឺមិនមានកូនកម្លោះទេ ដូច្នេះយើងបានកាត់កម្មវិធីមួយចំនួនចេញគឺយកតែកម្មវិធីទទួលភ្ញៀវប៉ុណ្ណោះ។ ញាតិនៅក្នុងភូមិបាននិយាយចំអកដាក់ខ្ញុំថា ខ្ញុំរៀបការជាមួយស្បែកជើង ប៉ុន្តែខ្ញុំមិនខឹងអ្នកទាំងនោះទេ។ ជាច្រើនខែក្រោយមក ទើបប្តីរបស់ខ្ញុំបានត្រឡប់មកផ្ទះវិញ ហើយឪពុកម្តាយរបស់ខ្ញុំបានរៀបចំសែនឲ្យខ្ញុំ និង ប្តី ម្តងទៀត

ដើម្បីកុំឲ្យខុសមេបា។

បន្ទាប់ពីសែនព្រេនបានមួយថ្ងៃ ខ្ញុំនិងប្ដីរបស់ខ្ញុំបានចេញទៅខេត្តកំពង់ធំជាប្រញាប់ ព្រោះភូមិដែលខ្ញុំរស់នៅមានក្រុមយុវជនរត់ចូលព្រៃទៅចូលជាមួយចលនាបដិវត្តន៍ខ្មែរក្រហម ហើយបងប្អូនប្ដីរបស់ខ្ញុំជាច្រើននាក់ក៏បានទៅចូលរួមជាមួយបដិវត្តន៍ដែរ។ ខ្ញុំបានធ្វើដំណើរតាមប្ដីរបស់ខ្ញុំពីកន្លែងមួយទៅកន្លែងមួយទៀត រួមជាមួយប្រពន្ធទាហានផ្សេងទៀត។ ខ្ញុំត្រូវដេកនៅតាមវត្តអារាម ក្នុងព្រៃ រោងម៉ាស៊ីន និងពេលខ្លះសុំផ្ទះអ្នកភូមិដើម្បីស្នាក់នៅ។ ខ្ញុំនៅចាំកន្លែងដែលខ្ញុំរស់នៅជាមួយប្ដីរបស់ខ្ញុំមួយចំនួនដូចជា នៅរោងម៉ាស៊ីនតាំងគោក វត្តពពេជ្រស្ថិតនៅក្នុងភូមិពពេជ្រ ភូមិបឹង និងនៅវត្តតាំងក្រសាំង។ ក្រោយមក ដោយសារកងទ័ពលន់ នល់ វាយចាញ់កងទ័ពបដិវត្តន៍ខ្មែរក្រហមជាបន្តបន្ទាប់ ទើបឈ្មោះ សារី ពាក់ស័ក្តិ២ បានជូនប្រពន្ធៗទាហានទាំងអស់មកទីក្រុងភ្នំពេញតាមឧទ្ធម្ភាគចក្រវិញ។ ខ្ញុំស្នាក់នៅភ្នំពេញបានរយៈពេល៤ថ្ងៃ ក៏ធ្វើដំណើរត្រឡប់មកផ្ទះនៅស្រុកកំណើតនៅខេត្តព្រៃវែងវិញ។ ចាប់តាំងពីពេលនោះមក ខ្ញុំបែកពីប្ដីរហូត។

ពេលមកដល់ផ្ទះ ទើបខ្ញុំដឹងថាខ្ញុំមានទម្ងន់៣ខែហើយ។ ពេលនោះ ខ្ញុំបានមករស់នៅជាមួយបងស្រីរបស់ខ្ញុំ។ ពេលដែលខ្ញុំរស់នៅជាមួយបងស្រីរបស់ខ្ញុំដំបូង ញាតិជិតខាងតែងតែនិយាយបញ្ចិតបញ្ចៀងថាខ្ញុំមានសាហាយជាមួយបងថ្លៃរបស់ខ្ញុំ ព្រោះឃើញខ្ញុំត្រឡប់មកផ្ទះតែម្នាក់ឯង។ ការរស់នៅរបស់ខ្ញុំមិនសូវទទួលបានការស្វាគមន៍ពីអ្នកភូមិប៉ុន្មានទេ ព្រោះខ្ញុំគឺជាប្រពន្ធរបស់ទាហានលន់ នល់។ ប្រជាជនមូលដ្ឋានជាច្រើននាក់បានរើសអើងខ្ញុំ ហើយពេលចែករបបស្រូវ ក៏ខ្ញុំទទួលបានតិចជាងប្រជាជនផ្សេងដែរ។ ខ្ញុំខិតខំធ្វើការខ្លាំងណាស់ ព្រោះខ្លាចអង្គការយកខ្ញុំទៅសម្លាប់ចោល។ អង្គការមានគម្រោងយកខ្ញុំទៅរៀនសូត្រចំនួន៣លើក ប៉ុន្តែសំណាងល្អខ្ញុំបានរួចខ្លួន។ ការងារដែលខ្ញុំធ្វើនៅក្នុងសម័យខ្មែរក្រហម រួមមានស្ទូង ដក ច្រូតស្រូវ លើកប្រព័ន្ធប្រឡាយ ប្រព័ន្ធភ្លឺស្រែ ធ្វើប្រហុក កាប់ព្រៃដាំពោត និងបេះផ្លែពោត។ ការងារដែលលំបាកជាងគេសម្រាប់ខ្ញុំ គឺលើកប្រឡាយនៅកោះជ័យ។ ការងារនេះធ្វើឲ្យខ្ញុំឈឺស្បូន ដោយសារធ្វើការងារធ្ងន់ធ្ងរបន្ទាប់ពីខ្ញុំឆ្លងទន្លេរួច។ ខ្ញុំបានឲ្យគ្រូខ្មែរអុជពោះរបស់ខ្ញុំ ដើម្បីកាត់បន្ថយការឈឺចាប់។

នៅចុងឆ្នាំ១៩៧៩ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានរៀបការម្ដងទៀតជាមួយឈ្មោះ វ៉ា ពិន និងសព្វថ្ងៃមានកូនចំនួន៦នាក់ គឺស្រី៤នាក់ និងប្រុស២នាក់។ នៅពេលដែលខ្ញុំសម្រាលកូនម្ដងៗ ខ្ញុំត្រូវអុចពោះរបស់ខ្ញុំ ដែលជាហេតុធ្វើឲ្យមានស្នាមរហូតមក។ សព្វថ្ងៃនេះខ្ញុំរស់នៅជាមួយកូនប្រុសរបស់ខ្ញុំដែលកើតនៅក្នុងរបបខ្មែរក្រហម។ ប្ដីទីមួយរបស់ខ្ញុំបានបាត់ដំណឹង បន្ទាប់ពីខ្ញុំបែកពីគាត់ពេលនៅខេត្តកំពង់ធំ ចំណែកប្ដីទីពីររបស់ខ្ញុំបានស្លាប់ចោលខ្ញុំជាង១០ឆ្នាំហើយ។



គោយន្តនៅផ្ទះរបស់ អ៊ុច ហាំ នៅភូមិព្រៃអង្គុញ ឃុំព្រៃកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)













# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!















# មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំវេទិកា «ជួបជុំ ពិនិត្យ និងពិគ្រោះពីបញ្ហាសុខភាព»

## ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកព្រៃកប្បាស ខេត្តតាកែវ

**ងឹម សុខគា និង ចាន់ ទិន**







ពីថ្ងៃទី១៣ ដល់ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំវេទិកា «ជួបជុំពិនិត្យ និងពិគ្រោះពីបញ្ហាសុខភាព» ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន១១៩ នាក់ នៅស្រុកព្រៃកប្បាស់ជាមួយ វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់ គឺជាគ្រូពេទ្យបង្គោល ក្រុមនិស្សិតពេទ្យស្ម័គ្រចិត្ត ព្រមទាំងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី១៣ ដល់ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំវេទិកា «ជួបជុំ ពិនិត្យ និងពិគ្រោះពីបញ្ហាសុខភាព» ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១១៩ នាក់ ស្ថិតនៅស្រុកព្រៃកប្បាស់ជាមួយ វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់ គឺជាគ្រូពេទ្យបង្គោល ក្រុមនិស្សិតពេទ្យស្ម័គ្រចិត្តព្រមទាំងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ វេទិកានេះក៏មានការចូលរួមពីលោកអភិបាលនៃគណៈអភិបាលស្រុកព្រៃកប្បាស លោកប្រធានក្រុមប្រឹក្សាស្រុកព្រៃកប្បាស និងសមាជិក ស.ស.យ.ក ស្រុកព្រៃកប្បាស់ផងដែរ។

លោកអភិបាលនៃគណៈអភិបាលស្រុកព្រៃកប្បាស អ៊ិត សារ និងលោកប្រធានក្រុមប្រឹក្សាស្រុកព្រៃកប្បាស បានធ្វើជាវាគ្មិននៅក្នុងជំនួបអ្នករស់រានមានជីវិតទាំង១១៩ នាក់ មកពីឃុំស្មោ និងឃុំក្តាញ់ ក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ។

គោលបំណងនៃជំនួបនេះ គឺ ១) ពិភាក្សាបញ្ហាសុខភាពជាមួយវេជ្ជបណ្ឌិត ដើម្បីពិគ្រោះយោបល់អំពីជំងឺប្រចាំកាយដែលកើតឡើងរយៈពេលយូរមកហើយ ២) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថែទាំសុខភាព តាមរយៈការពិនិត្យ



សុខភាពឲ្យបានញឹកញាប់ និង ៣) បង្ហាញប្រាប់អំពីប្រសិទ្ធភាពក្នុងការថែទាំសុខភាព។

នៅក្នុងវេទិកាជួបជុំ «ជួបជុំ ពិនិត្យ និងពិគ្រោះពីបញ្ហាសុខភាព» មានបែងចែកកាលវិភាគដូចខាងក្រោម៖

ជាកិច្ចចាប់ផ្តើមដំបូង នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ អ្នកស្រី គឹម សុវណ្ណដានី អ្នកសម្របសម្រួលគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការសំណេះសំណាល និងសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រមទាំងបញ្ហាសុខភាពប្រចាំថ្ងៃរបស់ពួកគាត់។ លើសពីនោះ អ្នកស្រី គឹម សុវណ្ណដានី ក៏បានបង្ហាញពីសកម្មភាពការងារដែលធ្វើជាបន្តបន្ទាប់។ តមក ក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន៣នាក់ ចាប់ផ្តើមវាស់សម្ពាធឈាម និងវាស់ចង្វាក់បេះដូងជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៤២នាក់ មកពីភូមិវាល, ភូមិក្បៀម, ភូមិក្រាំងវិច, ភូមិសម្តេចពាន់ និងភូមិអន្ត ស្ថិតនៅក្នុងឃុំក្តាញ់ ស្រុកព្រៃកប្បាស់ ខេត្តតាកែវ។





ពីថ្ងៃទី១៣ ដល់ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំវេទិកា «ជួបជុំ ពិនិត្យ និងពិគ្រោះពីបញ្ហាសុខភាព» ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន១១៩នាក់ នៅស្រុកព្រៃកប្បាស់ជាមួយ វេជ្ជបណ្ឌិត ឡាវ ហារ៉ាន់ គឺជាគ្រូពេទ្យបង្គោល ក្រុមនិស្សិតពេទ្យស្ម័គ្រចិត្ត ព្រមទាំងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃបន្ទាប់ គឺថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ លោកអភិបាលនៃគណៈអភិបាលស្រុកព្រៃកប្បាស អ៊ិត

សារ លោកប្រធានក្រុមប្រឹក្សាស្រុក និងសមាជិក ស.ស.យ.ក បានធ្វើការសំណេះសំណាលជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមកចូលរួមវេទិកា «ជួបជុំ ពិនិត្យ និងពិគ្រោះពីបញ្ហាសុខភាព»។ លោកអ៊ិត សារ សម្តែងសេចក្តីត្រេកអរ និងថ្លែងអំណរអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានរៀបចំវេទិកានេះឡើងដើម្បីធ្វើឲ្យប្រជាជនក្នុងភូមិរបស់លោក ទទួលបានសេវាពិនិត្យសុខភាព ដោយមិនចំណាយពេលយូរ។ លើសពីនេះទៅទៀត លោកក៏បានបញ្ជូនក្រុមយុវជនស្ម័គ្រចិត្ត ស.ស.យ.ក ដើម្បីជួយសម្រួលសម្រួលក្នុងវេទិកាឲ្យមានភាពរលូនផងដែរ។ តមក គឺជាការចាប់ផ្តើមពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន៣៥នាក់ មកពីភូមិត្រពាំងរាំង និងភូមិក្រាំង ដោយវេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់ គឺជាគ្រូពេទ្យបង្គោលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅថ្ងៃចុងក្រោយ គឺថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ មានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៤៧ មកពីភូមិទន្លេ, ភូមិស្នោ និង ភូមិរកា បានមកទទួលសេវាពិនិត្យសុខភាពពីវេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់ គឺជាគ្រូពេទ្យបង្គោលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ឆ្លងតាមការពិនិត្យសុខភាពរួចមក វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់ បានសន្និដ្ឋានជារួមថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺនៅតែប្រឈមជំងឺលើសឈាម និងទឹកនោមផ្អែម។ ចំពោះបញ្ហាឈឺសន្លាក់ចង្កេះ ភាគច្រើនកើតមានលើមនុស្សស្រី ដោយសារអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានវ័យចំណាស់ប្រឈមនឹងការអស់រដូវ។ ប៉ុន្តែអ្វីដែលវេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់ សង្កេតឃើញខុសពីអ្នករស់រានមានជីវិតដទៃនៅតាមខេត្តផ្សេងៗ បន្ទាប់ពីលោកបានចុះទៅពិនិត្យសុខភាពអ្នកជំងឺរួច គឺមានអ្នកជំងឺ៣ទៅ៤នាក់ មានបញ្ហាពិការភ្នែកដោយការព្យាបាលភ្នែករបស់អ្នកជំងឺមានភាពយឺតយ៉ាវ។ លោកពិតជាសោកស្តាយ ព្រោះអ្នកជំងឺមិនបានទៅពិភាក្សាជាមួយគ្រូពេទ្យដែលមានស្រាប់នៅក្នុងខេត្តរបស់ខ្លួន។ ម្យ៉ាងទៀត វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់ សង្កេតឃើញអ្នកមានជំងឺលើសឈាមចំនួន៣នាក់ ដែលមិនសូវមានការយល់ដឹងពីការថែទាំសុខភាព បានបន្តឲ្យគាត់ពិការដល់សព្វថ្ងៃ។

ចំពោះបញ្ហាផ្លូវចិត្ត វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់ សង្កេតឃើញថា នៅពេលលោកសួរនាំអ្នកជំងឺទាក់ទងទៅនឹងរឿងរ៉ាវពីរបបខ្មែរក្រហម និងរឿងរ៉ាវសព្វថ្ងៃ ធ្វើឲ្យអ្នកទាំងនេះមានការប៉ះពាល់អារម្មណ៍ច្រើនជាងអ្នកជំងឺនៅខេត្តផ្សេងៗ។ មិនមែនមានន័យថា អ្នកមានជំងឺផ្លូវចិត្តនេះមានច្រើនជាងជំងឺលើសឈាម និងជំងឺទឹកនោមផ្អែមនោះទេ ប៉ុន្តែជំងឺផ្លូវចិត្តនេះគឺមានច្រើនអាចរហូតដល់៥ទៅ៦នាក់ឯណោះ។ រីឯអ្នកជំងឺមានបញ្ហាផ្លូវចិត្តដដែល ដែលគាត់កំពុងតែព្យាបាលដោយថ្នាំ អ្នកជំងឺខ្លះកំពុងបញ្ឈប់ការព្យាបាល បណ្តាលឲ្យអ្នកជំងឺទាំងនោះធ្វើទុក្ខឡើងវិញ និងអ្នកខ្លះទៀត មិនទាន់បានព្យាបាលនៅឡើយ។ វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់បន្ថែមថា វេទិកាសួរសុខទុក្ខ និងពិនិត្យសុខភាពដល់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហមនៅតែសំខាន់ពីព្រោះអ៊ំពូមីងយាយតា មួយចំនួនធំ មិនទាន់មានការយល់ដឹងពីការថែទាំសុខភាពនៅឡើយ។ តាមការស្ទាបស្ទង់មតិ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រហែលជា៧០ទៅ៨០ភាគរយនៃចំនួនសរុបដែលលោកបានពិគ្រោះជំងឺ គឺនៅតែមិនមានការយល់ដឹងច្រើនលើការថែទាំសុខភាព។



ពីថ្ងៃទី១៣ ដល់ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំវេទិកា «ជួបជុំពិនិត្យ និងពិគ្រោះពីបញ្ហាសុខភាព» ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន១១៩ នាក់ នៅស្រុកព្រៃកប្បាស់ជាមួយវេជ្ជបណ្ឌិត ឡាវ ហាវ៉ាន់ គឺជាគ្រូពេទ្យបង្គោល ក្រុមនិស្សិតពេទ្យស្ម័គ្រចិត្ត ព្រមទាំងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម

ទូច វណ្ណេត







នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាសម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម ដោយមានការចូលរួមពីយុវជន-យុវនារីស្ម័គ្រចិត្តសរុបចំនួន១៣៣នាក់។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាសម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម ដោយមានការចូលរួមពីយុវជន-យុវនារីស្ម័គ្រចិត្តសរុបចំនួន១៣៣នាក់។ វេទិកាអ្នកស្ម័គ្រចិត្តកម្ពុជានេះ ធ្វើឡើងក្នុងគោលបំណងបង្កើនចំណេះដឹងប្រវត្តិសាស្ត្រ និងរបៀបសរសេរសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទៅកាន់អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨។ វេទិកានេះក៏រួមបញ្ចូលការចុះទស្សនកិច្ចទៅកាន់ស្តូបរំឭកសម្រាប់សហគមន៍គគរ ដែលជាកន្លែងដែលអ្នកស្ម័គ្រចិត្តអាចជួបនិងស្តាប់អំពីបទពិសោធន៍ជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ជាការចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចាប់ផ្តើមបើកវេទិកាដោយបានរំឭកអំពីសារសំខាន់នៃការចងចាំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលប្រជាជនកម្ពុជាធ្លាប់ឆ្លងកាត់រាល់ទុក្ខវេទនា ការបែកបាក់គ្រួសារ និងការបាត់បង់ជីវិត។ នៅក្នុងឱកាសនោះ លោក ស៊ាង ចិន្តា ក៏ធ្វើបទបង្ហាញទាក់ទងនឹងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងអត្តប្រយោជន៍នៃការងារស្ម័គ្រចិត្ត អំឡុងពេលដែលយុវជន-យុវនារីស្ម័គ្រចិត្តទាំងអស់ចុះអនុវត្តការងារនាពេលដ៏ខ្លីខាងមុខនេះ។ អ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តកំពង់ចាម មានចំនួនសរុបជិត៥០០នាក់ គឺចាប់ពីជំនាន់ទី១ ដល់ជំនាន់ទី៧ ដែលបានចុះសួរសុខទុក្ខ

ស្តាប់ និងសរសេរសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសរុបចំនួន៣០០០នាក់។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងខេត្តកំពង់ចាមនៅតែចងចាំមិនភ្លេចរាល់ទុក្ខលំបាក និងការបាត់បង់សមាជិកគ្រួសាររបស់ខ្លួនក្នុងរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនរងផលប៉ះពាល់សុខភាពរាងកាយ និងផ្លូវចិត្ត។

ជាកិច្ចបន្ត លោក សាំង ចាន់ធូ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពង់ចាម និងជាប្រធានក្រុមអ្នកស្ម័គ្រកម្ពុជា ប្រចាំខេត្តកំពង់ចាមបានបង្ហាញពីរបៀបបញ្ចូនឯកសារ, បទសម្ភាសន៍ក្នុងតារាងការងារ ដូចអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់មុនៗធ្លាប់ធ្វើកន្លងមក, និងលក្ខខណ្ឌតិកៈនៃអ្នកស្ម័គ្រចិត្តកម្ពុជាដែលត្រូវបំពេញដូចខាងក្រោម៖

១) សម្ភាសន៍ និងការសរសេរសង្ខេបសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានអាយុចាប់ពី៥៥ឆ្នាំឡើងទៅ

២) ថតសំឡេងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

៣) ថតរូបអ្នកផ្តល់បទសម្ភាសន៍ និងទេសភាពផ្សេងៗនៅតាមភូមិរបស់អ្នកស្ម័គ្រចិត្តកម្ពុជា

ជាកិច្ចបន្ត លោក លី ដេវីត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលបន្ទុកផ្នែកប្រព័ន្ធផ្សព្វផ្សាយ ដែលជាអតីតអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ បានចែករំលែកនូវបទពិសោធន៍ និងបច្ចេកទេសនៅក្នុងការផ្តិតយករូបភាព និងការផលិតវីដេអូឯកសារផ្សេងៗ រួមទាំងបង្ហាញអំពីវីដេអូចំណាប់អារម្មណ៍ និងការយល់ឃើញរបស់អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី១ និងជំនាន់ទី៣។

ជាកិច្ចបញ្ចប់នៃវេទិកាអ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម គឺការចុះទៅទស្សនកិច្ចវត្តរកាគយ និងសម្រាកហូបអាហារថ្ងៃត្រង់ និងបន្ទាប់មកបន្តចុះទៅកាន់ស្តូបរំឭកសម្រាប់សហគមន៍នៅឃុំគគរ។ លោក តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ ជួបសន្ទនាផ្ទាល់ជាមួយអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ ដោយបាននិយាយប្រាប់អំពីគោលបំណងនៃការសាងសង់ស្តូបរំឭកសម្រាប់សហគមន៍នេះ គឺដើម្បីជាទីតាំងរំឭកដល់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម និងជាទីតាំងសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរអាចនិយាយប្រាប់អំបទពិសោធន៍របស់ខ្លួនទៅកាន់យុវជន-យុវនារី ជំនាន់ក្រោយឲ្យដឹងអំពីប្រវត្តិរឿងរ៉ាវនៅទីនេះ។







នៅ ទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាសម្រាប់អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ ប្រចាំខេត្តកំពង់ចាម ដោយមានការចូលរួមពីយុវជន-យុវនារីស្ម័គ្រចិត្តសរុបចំនួន១៣៣នាក់។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# មជ្ឈមណ្ឌលផ្សះផ្សាវាលវែង រៀបចំវេទិកាថ្នាក់រៀនស្តីអំពី «សារសំខាន់នៃការសិក្សា

## ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ»

ឡុង ដានី








នៅព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាថ្នាក់រៀនស្តីពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ សម្រាប់យុវជនចំនួន១៧ នាក់ ក្នុងនោះស្រី១២នាក់ មកពីស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (ធី គីមហុង/មជ្ឈមណ្ឌលផ្សះផ្សាវាលវែង)

នៅព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាថ្នាក់រៀនស្តីពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ សម្រាប់យុវជនចំនួន១៧ នាក់ ក្នុងនោះស្រី១២នាក់ មកពីស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

វេទិកានេះនឹងផ្តល់ការអប់រំដល់យុវជនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងឈ្វេងយល់អំពីនិយមន័យនៃឧក្រិដ្ឋកម្មឃោរឃៅ និងកត្តាគ្រោះថ្នាក់ជាក់លាក់ដែលនាំឲ្យកើតមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមនាពេលអនាគត។ លើសពីនេះទៀត យុវជនទាំងអស់ត្រូវបានពន្យល់ពីយុទ្ធសាស្ត្រនៃការទប់ស្កាត់អំពើប្រល័យពូជសាសន៍ពីកម្រិតបុគ្គលដល់កម្រិតជាតិ និងលើកទឹកចិត្តឲ្យអ្នកទាំងនោះចែករំលែកចំណេះដឹងរបស់ខ្លួន អំពីប្រវត្តិសាស្ត្រខ្មែរក្រហមជាមួយ

អ្នកដទៃ។ គោលបំណងនៃការរៀបចំវេទិកាថ្នាក់រៀន ក៏ជាការផ្តល់ឱកាសដល់យុវជនក្នុងការចែករំលែក និងបង្ហាញពីចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគេនៅលើអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លើកទឹកចិត្តយុវជនឲ្យគិតពិចារណាលើផលវិបាកអន្តរកាលនៃកេរដំណែលប្រវត្តិសាស្ត្រក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។ ជំរុញការពិភាក្សាអំពីកេរដំណែលនេះនៅក្នុងគ្រួសារ និងសហគមន៍។ ជំរុញការពិភាក្សាអំពីការលើកឡើងនូវយុទ្ធសាស្ត្រមួយចំនួនក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេស។ ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ។

លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង និងក្រុមការងារបានណែនាំខ្លួន និងដឹកនាំយុវជនដើរទស្សនាការិយាល័យមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ បន្ទាប់មកលោក ឡុង ដានី បានប្រាប់យុវជនអំពីប្រវត្តិនៃការបង្កើតមជ្ឈមណ្ឌលផ្សះផ្សាវាលវែង នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ និងគោលបំណងចំនួន៤ដូចខាងក្រោម៖

១) ដើម្បីបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៧០រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។

២) ដើម្បីពង្រឹងដល់ដំណើរការសន្តិភាព និងទប់ស្កាត់ជម្លោះនានាតាមរយៈកម្មវិធីអប់រំ។ កម្មវិធីអប់រំនេះនឹងផ្តល់ឱកាសឲ្យយុវជនជំនាន់ក្រោយដែលភាគច្រើនរស់នៅតាមជនបទបានចូលរួមរៀនសូត្រ។

៣) លើកទឹកចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងការចែករំលែករឿងរ៉ាវ ឬបទពិសោធន៍ផ្ទាល់ខ្លួនដល់ក្មេងៗជំនាន់ក្រោយ។

៤) ប្រមែប្រមូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងបទឧក្រិដ្ឋដែលបានបន្សល់ពីរបបខ្មែរក្រហម។

ជាកិច្ចបន្ត លោក ឡុង ដានី បានធ្វើបទបង្ហាញជាសង្ខេបអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ស្តីពីគោលនយោបាយ ៨ចំណុចរបស់ខ្មែរក្រហមដូចខាងក្រោម៖

១) ការជម្លៀសប្រជាជនដោយបង្ខំ
២) បំបាត់ផ្សារ និងរូបិយប័ណ្ណ
៣) ផ្សឹកព្រះសង្ឃ និងកម្ទេចវត្តអារាម
៤) បិទសាលារៀន
៥) បង្កើតសហករណ៍
៦) បំបែកក្រុមគ្រួសារមិនឲ្យជួបជុំគ្នា
៧) សម្លាប់បញ្ញវន្តមន្ត្រីរដ្ឋការ និងប្រជាជនស្លូតត្រង់
៨) បណ្តេញជនជាតិវៀតណាម និងធ្វើសង្គ្រាមតាមព្រំដែនជាមួយវៀតណាម។

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សង្គមកម្ពុជាទាំងមូលបានទទួលផលប៉ះពាល់ដូចជា៖ ប្រជាជនកម្ពុជាប្រមាណ២លាននាក់ស្លាប់ ដោយសារការសម្លាប់ អត់អាហារ ធ្វើការហួសកម្លាំង និងឈឺគ្មានការព្យាបាល។ បន្សល់ទុកស្ត្រីមេម៉ាយ និងក្មេងកំព្រារាប់ពាន់នាក់នៅក្នុងសង្គមកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហម។ ប្រជាជនកម្ពុជាភាគច្រើនមានជំងឺបាក់ស្បាត និងមានប្រជាជនកម្ពុជាមួយចំនួន បានសម្រេចចិត្តធ្វើចំណាកស្រុក និងជាជនភៀសខ្លួន។ របបខ្មែរក្រហមបានបន្សល់ទុកគ្រាប់មីនរាប់លានគ្រាប់។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ភាគច្រើនមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ។ សេដ្ឋកិច្ចប្រទេសកម្ពុជាបានធ្លាក់ដល់កម្រិតសូន្យ។ ពុំមានអ្នកចេះដឹងច្រើន សម្រាប់ជួយអភិវឌ្ឍន៍ប្រទេស។

បន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហម លោក ឡុង ដានី ក៏ធ្វើបទបង្ហាញអំពីដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហមក្នុងសំណុំរឿង០០១ និង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នៅក្នុងសំណុំរឿង០០១ ពាក់ព័ន្ធនឹងការជំនុំជម្រះក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច។ ឌុច គឺជាអតីតប្រធានមន្ទីរសន្តិសុខស-២១ (ដែលប្រជាជនកម្ពុជាទូទៅបានស្គាល់ថាជាគុកទួលស្លែងស្ថិតនៅទីក្រុងភ្នំពេញ)។ នៅ

ឆ្នាំ២០១២ ឌុច ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។

សំណុំរឿង០០២ នៅឆ្នាំ២០១០សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួន៤រូប រួមមាន៖ អៀង សារី នួន ជា ខៀវ សំផន និងអៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ ដោយសារភាពស្មុគស្មាញនៃរឿងក្ដី និងអាយុរបស់ជនជាប់ចោទ ទើបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចបំបែកសំណុំរឿង០០២ជាពីរគឺ សំណុំរឿង០០២ វគ្គ១ និងសំណុំរឿង០០២ វគ្គ២ សម្រាប់ការជំនុំជម្រះពីរផ្សេងគ្នា។ សំណុំរឿង០០២វគ្គ១ដោយសារ អៀងសារី និង អៀង ធីរិទ្ធ មានជំងឺ និងទទួលមរណភាពនៅឆ្នាំ២០១៣ និង២០១៥។ ដូច្នេះ នៅឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្ដន្ទាទោស នួនជា និង ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការសម្លាប់ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងដំណាក់កាលទីពីរនៃការផ្លាស់ប្ដូរទីលំនៅប្រជាជន។ សំណុំរឿង០០២ វគ្គ២ គឺជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និង អំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងនៅតាមសហករណ៍ ការដ្ឋានការងារ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងក្រុមមនុស្សដែលជាក្រុមគោលដៅជាក់លាក់ ដូចជាជនជាតិចាម ជនជាតិវៀតណាម អ្នកកាន់សាសនាព្រះពុទ្ធ និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ នួនជា និង ខៀវ សំផន ត្រូវបានរកឃើញថាបានប្រព្រឹត្តបទឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និង អំពើប្រល័យពូជសាសន៍ ដោយ

នៅព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាថ្នាក់រៀនស្ដីពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ សម្រាប់យុវជនចំនួន១៧ នាក់ ក្នុងនោះស្រី ១២នាក់ មកពីស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (ធី គឹមហុង/មជ្ឈមណ្ឌលផ្សះផ្សាវាលវែង)



បានចូលរួមក្នុងសហឧក្រិដ្ឋកម្មព្រហ្មទណ្ឌរួមជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត។ នៅឆ្នាំ២០១៩ នួន ជា បានស្លាប់ដោយសារជរាភាព។

នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចផ្តន្ទាទោស ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិតបន្ថែមទៀតចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មខាងលើ និងបានបិទបញ្ចប់ការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែម្តង។

ចុងបញ្ចប់នៃកម្មវិធីថ្នាក់រៀនលោក ឡុង ដានី បានធ្វើបទបង្ហាញពីនិយមន័យ បុព្វហេតុ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅដែលមានពីរផ្នែកសំខាន់ៗដូចខាងក្រោម៖ ១) និយមន័យនៃអំពើឧក្រិដ្ឋឃោរឃៅ រួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម និងឧទាហរណ៍ជាក់លាក់មួយចំនួនដែលនាំឲ្យកើតមានឧក្រិដ្ឋកម្មឃោរឃៅទាំងឡាយ។

២) វិធីសាស្ត្រជាក់លាក់ចំនួនពីរក្នុងការចូលរួមទប់ស្កាត់អំពើឃោរឃៅ ឬអំពើប្រល័យពូជសាសន៍ក្នុងកម្រិតបុគ្គល គ្រួសារ ឬសហគមន៍ និងកម្រិតប្រទេសជាតិ។ យុវជនត្រូវបានលើកទឹកចិត្តឲ្យអនុវត្តវិធីសាស្ត្រទាំងនេះ ដោយចាប់ផ្តើមពីខ្លួនឯង។ បន្ទាប់បញ្ចប់វេទិកាថ្នាក់រៀន យុវជនទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ម្នាក់មួយក្បាល ដើម្បីយកទៅអាន និងឈ្វេងយល់ពីរបៀបសរសេរកំណត់ហេតុផ្ទាល់ខ្លួន។



នៅព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាថ្នាក់រៀនស្តីពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ សម្រាប់យុវជនចំនួន១៧ នាក់ ក្នុងនោះស្រី១២នាក់ មកពីស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (ធី គីមហុង/មជ្ឈមណ្ឌលផ្សះផ្សាវាលវែង)

# មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា» សម្រាប់សិស្សវិទ្យាល័យភ្នំមាស

*ឌីម សុខគា*







ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍សម្រាប់សិស្សានុសិស្សចំនួន៣០នាក់ ក្នុងនោះស្រី២៥នាក់ និងគ្រូដឹកនាំចំនួន២នាក់ មកពីវិទ្យាល័យភ្នំមាស ស្រុកព្រៃកប្បាសខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ជាមួយសិស្សានុសិស្សចំនួន៣០នាក់ ក្នុងនោះមានសិស្សស្រី២៥នាក់ និងគ្រូដឹកនាំចំនួន២នាក់ មកពីវិទ្យាល័យភ្នំមាស ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ជាកិច្ចចាប់ផ្តើមដំបូងនៃវេទិកាគឺសិស្សានុសិស្សដើរទស្សនាពិព័រណ៍រូបភាពស្តីពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម រួមទាំងផ្ទាំងពិព័រណ៍នៅខាងក្រៅ និងខាងក្នុងការិយាល័យ។ បន្ទាប់មកសិស្សទាំងអស់បានចូលទៅកាន់បន្ទប់ថ្នាក់រៀន រួចគ្រូឧទ្ទេសតម្រូវឲ្យសិស្សបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹងស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងចំណេះដឹងស្តីពីវិធីសាស្ត្រទប់ស្កាត់អំពើហិង្សា។

បន្ទាប់មកលោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានណែនាំខ្លួន និងក្រុម

ការផ្សារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ តមកទៀត លោក ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញខ្លីពីគោលការណ៍ទាំង៨ចំណុចរបស់ខ្មែរក្រហម ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាឈ្វេងយល់បន្ថែមទៀតបន្ទាប់ពីខ្លួនទទួលបានការបង្រៀនពីគ្រូបង្រៀនក្នុងថ្នាក់រួចមក។ គោលការណ៍ទាំង៨របស់ខ្មែរក្រហម រួមមាន ៖ ការជម្លៀសដោយបង្ខំ, លុបបំបាត់ចោលទាំងស្រុងនូវសេដ្ឋកិច្ចទីផ្សារសេរី, លុបបំបាត់ចោលនូវការចាយលុយ, ផ្សឹកព្រះសង្ឃ និងបំបិទសាសនា, កំចាត់សត្រូវវណ្ណៈ ដែលសំដៅទៅលើទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ, បង្កើតជាសហករណ៍ និងការដ្ឋានការងារនៅទូទាំងប្រទេស, បណ្តេញជនជាតិវៀតណាមឲ្យអស់ពីប្រទេសកម្ពុជា និងដាក់ពង្រាយកងទ័ពនៅតាមព្រំដែនជាពិសេសព្រំដែនវៀតណាម។

លោក ផេង ពង្សរ៉ាស៊ី ក៏បានពន្យល់ពីនិយមន័យកត្តាគ្រោះថ្នាក់ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍។ ក្រោយបទបង្ហាញចប់ សិស្សានុសិស្សអាចចោទសួរជាសំណួរដែលឆ្ងល់ និងអាចបញ្ចេញជាមតិយោបល់បាន។ រាល់សំណួរទាំងអស់ លោក ផេង ពង្សរ៉ាស៊ី បានស្រាយគ្រប់ចម្ងល់របស់សិស្សទាំងអស់។ បន្ទាប់ពីបញ្ចប់វេទិកាថ្នាក់រៀននៅក្នុងថ្ងៃនេះ សិស្សទាំងអស់បានបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹងក្រោយវេទិកា។ លើកនេះ សិស្សបានចំណាយពេលវេលាច្រើនជាង២០នាទី ដើម្បីបំពេញឲ្យគ្រប់សំណួរ។ កម្រងសំណួរនេះ ក៏មិនខុសពីកម្រងសំណួរនៅមុនពេលធ្វើវេទិកាដែរ ប៉ុន្តែ លោក ផេង ពង្សរ៉ាស៊ី បានថែមសំណួរមួយចំនួនដែលចង់ឲ្យសិស្សវាយតម្លៃលើចំណេះដឹងខ្លួនឯង និងវាយតម្លៃចំពោះការអនុវត្តកម្មវិធីវេទិកាថ្នាក់រៀន។

នៅពេលរសៀល បន្ទាប់ពីទទួលទានអាហារថ្ងៃត្រង់រួច សិស្សទាំងអស់បានធ្វើដំណើរឆ្ពោះទៅកាន់ទីតាំងផ្ទះផ្សាមួយក្នុងភូមិត្រពាំងស្វាយ ក្នុងឃុំតាភេម។ នៅទីនោះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសាងសង់ចេតិយរឹងមាំមួយដើម្បីផ្តល់ដល់អ្នករស់រានមានជីវិតនៅក្នុងឃុំតាភេមទាំងអស់ នូវទីកន្លែងសម្រាប់ដាក់អដ្ឋិធាតុសាច់ញាតិក្រុមគ្រួសារដែលបានស្លាប់ក្នុងរបបខ្មែរក្រហម។

ស្ថិតក្នុងទីតាំងចេតិយ លោក សួស រ៉ា បានជួបជាមួយសិស្ស និងបាននិយាយពីប្រវត្តិគាត់ធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម។ សិស្សបានសួរសំណួរមួយចំនួនទាក់ទងនឹងដំណើរជីវិតគាត់ ពិការភាពរបស់គាត់ និងអារម្មណ៍របស់គាត់ក្នុងពេលនេះ បើប្រៀបធៀបជីវិតនាពេលបច្ចុប្បន្នទៅនឹងជីវិតរស់នៅក្នុងរបបខ្មែរក្រហម។ បន្តមកទៀតសិស្សទាំងអស់បានធ្វើដំណើរទៅកាន់ទីតាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់ ដែលមានលោកតា យ៉ិន សឿន បានជួបជាមួយសិស្ស ដោយឈរនៅចំពីមុខស្តូបតម្កល់អដ្ឋិធាតុ និងបានរៀបរាប់អំពីប្រវត្តិផ្ទាល់ខ្លួន កាលក្នុងឆ្នាំ១៩៧០ និងក្នុងរបបខ្មែរក្រហម ព្រមទាំងបានប្រាប់សិស្សពីការថែរក្សាឆ្អឹងដែលកំពុងដាក់តម្កល់នៅក្នុងស្តូបនាពេលនេះ។

តមកទៀត លោកតា យ៉ិន សឿន បានបង្ហាញទៅកាន់សិស្សានុសិស្សអំពីទីកន្លែងធ្វើទារុណកម្ម និងសួរចម្លើយក្នុងមន្ទីរក្រាំងតាចាន់។ កំឡុងពេលខ្មែរក្រហមសួរចម្លើយ និងសម្លាប់បានចាក់មេក្រូ ដើម្បីកុំឲ្យឮសំឡេងស្រែក។ ខ្មែរក្រហមសម្លាប់មនុស្សភាគច្រើននៅម៉ោង៨រសៀល។ នៅពេលសម្លាប់ ខ្មែរក្រហមបានប្រើដំបងវាយពីក្រោយ កាំបិទចាក់ និងធាងត្នោតអារក។ ក្នុងចន្លោះឆ្នាំ១៩៧៣-១៩៧៩ មានមនុស្សស្លាប់ចំនួន១០០៤៥នាក់ នៅគុកក្រាំងតាចាន់ និងមានរណ្តៅសាកសព៦២រណ្តៅ។ ជនរងគ្រោះទាំងនោះស្លាប់ដោយសារការសម្លាប់ ការធ្វើទារុណកម្ម និងការបង្អត់អាហារ។ ដើមឡើយ ក្រាំងតាចាន់ជាទីទួលស្ងាត់មានព្រៃស្តុកក្រាស់ និងគ្មានផ្ទះប្រជាជននៅជុំវិញឡើយ។

នៅចុងបញ្ចប់កម្មវិធី សិស្សានុសិស្សបានបង្ហាញនូវចំណាប់អារម្មណ៍ និងមតិយោបល់ដូចខាងក្រោម ៖

**ថៃ សុខត្តិធារិទ្ធ** អាយុ១៧ឆ្នាំ បង្ហាញចំណាប់អារម្មណ៍ថា «ខ្ញុំពិតជាមានអារម្មណ៍ថា សប្បាយចិត្ត

នៅពេលដែលបានចូលរួមក្នុងវេទិកាក្នុងថ្ងៃនេះ ពីព្រោះខ្ញុំទទួលបានចំណេះដឹងថ្មីៗពីប្រវត្តិសាស្ត្រខ្មែរក្រហម។ មួយទៀតខ្ញុំអាចដឹងពីនិយមន័យនៃអំពើប្រល័យពូជសាសន៍និងវិធានការក្នុងការទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍កើតឡើងសារជាថ្មី»។

**ស្រ៊ុន សុម៉ានី** អាយុ១៧ឆ្នាំ បានបង្ហាញចំណាប់អារម្មណ៍ថា «ថ្វីត្បិតខ្ញុំជាក្មេងៗជំនាន់ក្រោយ ទោះបីជាមិនធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ប៉ុន្តែបន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនរួច ជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្ទាល់ ធ្វើឲ្យខ្ញុំមានការក្តុកក្តួលចំពោះអ្នកដែលធ្លាប់ឆ្លងកាត់ និងអ្នករស់រានមានជីវិតទាំងក្នុងសម័យខ្មែរក្រហម»។ ខ្ញុំគិតថាប្រជាជនយើងមិនគួររើសអើងគ្នា គឺត្រូវចេះស្រឡាញ់គ្នា គោរពគ្នាទៅវិញទៅមក ហើយត្រូវចេះឲ្យតម្លៃគ្នា មិនថាពូជសាសន៍ឬសាសនាណាក៏ដោយ គឺមានសិទ្ធិស្មើៗគ្នា ជាពិសេស ត្រូវចេះសាមគ្គីគ្នាជាធ្លុងមួយដើម្បីកុំឲ្យបែកបាក់គ្នា ត្រូវចេះណែនាំគ្នាប្រព្រឹត្តតែអំពើល្អ មិនប្រកាន់បក្ខពួក និងឲ្យតម្លៃគ្នាទៅវិញទៅមក នេះហើយជារបៀបនៃការទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងម្តងទៀត»។

**យ៉ា រ៉ាទុធ** អាយុ១៨ឆ្នាំ បង្ហាញចំណាប់អារម្មណ៍ថា «ខ្ញុំឃើញថា ការបង្កើតវេទិកាថ្នាក់រៀនពីប្រវត្តិ-សាស្ត្រខ្មែរក្រហមពិតជាល្អ ព្រោះវាបានជួយបណ្តុះបណ្តាលគំនិតឲ្យយើងបានដឹងពីប្រវត្តិសាស្ត្ររបស់ខ្មែរបានច្រើន។ វាពិតជាកម្រនឹងមានឱកាសបានស្តាប់មើលឯកសារវីដេអូ និងរូបភាពពិតៗក្នុងមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ ដើម្បីចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍ យើងត្រូវដោះស្រាយបញ្ហាដោយសន្តិវិធី និងដឹងពីមូលហេតុ, បង្រៀនប្រជាជនឲ្យចេះស្រឡាញ់គ្នា និងមិនមានការរើសអើងគ្នា»។

**ចេង បូរមីណ៍គន្ថា** អាយុ១៧ឆ្នាំ បង្ហាញចំណាប់អារម្មណ៍ថា «ខ្ញុំគិតថាវេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រខ្មែរក្រហមពិតជាសំខាន់ ព្រោះធ្វើឲ្យយើងបានដឹងពីអតីតកាល និងអាចជួយទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងសារជាថ្មី។

**ស៊ឹម សូឡាវិន** អាយុ១៧ឆ្នាំ បង្ហាញចំណាប់អារម្មណ៍ថា «វេទិកាថ្នាក់រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមពិតជាល្អសម្រាប់យុវជនជំនាន់ក្រោយ។ ខ្ញុំសុំស្នើឲ្យយុវជនទាំងអស់គួរតែបានចូលរួមរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំអរគុណដល់ក្រុមការងារយ៉ាងជ្រៀលជ្រៅ។ ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ បើសិនមានវេទិកាបែបនេះដែលអាចឲ្យនាងខ្ញុំចង់ចូលរួមម្តងទៀត ខ្ញុំនឹងចូលរួម»។







នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍សម្រាប់សិស្សានុសិស្សចំនួន៣០នាក់ ក្នុងនោះស្រី២៥នាក់ និងគ្រូដឹកនាំចំនួន២នាក់ មកពីវិទ្យាល័យភ្នំមាស ស្រុកព្រៃកប្បាស ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សានុសិស្សវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

**លី ដេវីត**



នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្ដាហ៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ ចំនួន៥៥នាក់មកពីវិទ្យាល័យ ឈីនលានហាន់ជ័យ ស្ថិតនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )





នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំឡើងវេទិកាថ្នាក់រៀនចុងសប្ដាហ៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ ចំនួន៥៥នាក់ មកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ស្ថិតនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ដើម្បីជំរុញចំណេះដឹងរបស់សិស្សានុសិស្សដែលជាយុវជន-យុវនារីជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម វេទិកាថ្នាក់រៀនចុងសប្ដាហ៍នេះ រួមបញ្ចូលកម្មវិធីសិក្សាបន្ថែមដូចជា៖ បទបង្ហាញស្ដីពីប្រវត្តិសាស្ត្រខ្មែរក្រហម, ការទស្សនាភាពយន្តឯកសារ ការចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងការពិភាក្សាក្រុមទាក់ទងអំពីប្រធានបទ ការបែងចែកប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

## ដំណើរទស្សនកិច្ចមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

ជាកិច្ចចាប់ផ្តើមនៃកម្មវិធី សិស្សានុសិស្សវិទ្យាល័យ ឈើន លាន ហាន់ជ័យ ទាំងអស់បានផ្តើមទស្សនកិច្ចនៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដោយមានការទទួលស្វាគមន៍ពីលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ លោក ស៊ាង ចិន្តា បានធ្វើបទបង្ហាញខ្លីមួយ ទាក់ទងនឹងកិច្ចការទូទៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងជាពិសេសការងារដែលមជ្ឈ-មណ្ឌលឯកសារខេត្តកំពង់ចាមបានធ្វើកន្លងមក។

ជាកិច្ចបន្ទាប់ លោក លី ដេវីត បុគ្គលិកមជ្ឈ-មណ្ឌលឯកសារខេត្តកំពង់ចាម បានដឹកនាំសិស្សានុ-សិស្សវិទ្យាល័យ ឈើន លានហាន់ជ័យ ទស្សនាពិព័រណ៍រូបថតចំនួន១០ផ្ទាំងធំៗ ដែលបង្ហាញអំពីប្រវត្តិមេដឹកនាំខ្មែរក្រហម ការជម្លៀសប្រជាជន ការធ្វើការងារនៅការដ្ឋានទំនប់ និងការវិលត្រឡប់មកវិញរបស់ប្រជាជនកម្ពុជា បន្ទាប់ពីការដួលរលំរបបខ្មែរក្រហមនៅដើមឆ្នាំ១៩៧៩។

បន្ទាប់មកលោក ទូច វណ្ណេត បាននាំសិស្សានុ-សិស្សទស្សនាផ្ទាំងពិព័រណ៍ «ក្តីសុបិនកម្ពុជា» បន្ទប់បណ្ណាល័យ បន្ទប់គម្រោងសូត្រចាម និងបន្ទប់ចាក់បញ្ចាំងខ្សែភាពយន្តនៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។

ជាចុងក្រោយសិស្សានុសិស្សទាំងអស់បានចូលទៅក្នុងបន្ទប់ឯកសាររបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលធ្វើបទបង្ហាញដោយលោក សាំង ចាន់ធូ ក្រោយពីឈ្វេងយល់អំពីឯកសាររួចហើយ សិស្សានុសិស្សទាំងអស់ក៏បានឈ្វេងយល់បន្ថែមទៀតអំពីកិច្ចការងាររបស់អ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម ដែលលោក សាំង ចាន់ធូ បុគ្គលិកទទួលបន្ទុកកិច្ចការអ្នកស្ម័គ្រចិត្របានបង្ហាញដោយផ្ទាល់។

## បទបង្ហាញស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

មុនការធ្វើបទបង្ហាញ លោក ស៊ាង ចិន្តា បានផ្តល់កម្រងសំណួរស្ទាបស្ទង់មតិមុនវេទិកាថ្នាក់រៀនដល់សិស្សានុសិស្សចូលរួមទាំងអស់ដើម្បីវាស់ស្ទង់ចំណេះដឹងពីមុនរបស់ខ្លួន។ ជាកិច្ចបន្ត លោក ស៊ាង ចិន្តា ចាប់ផ្តើមបទបង្ហាញរបស់ខ្លួនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបានផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររួមមាន៖ រដ្ឋប្រហារលន់ នល់ នៅឆ្នាំ១៩៧០, ការផ្ទុះឡើងនូវសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម, ការកាប់សម្លាប់ទៅលើប្រជាជននិងការបែងចែកប្រជាជននៅក្នុងតំបន់របស់ខ្មែរក្រហម ដែលជាប្រធានបទសំខាន់នៃកិច្ចពិភាក្សាក្រុមនៅថ្ងៃនេះ។

នៅចុងបញ្ចប់នៃបទបង្ហាញ លោក ស៊ាង ចិន្តា លើកឡើងអំពីនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងអំពើប្រល័យពូជសាសន៍។ បន្ទាប់ពីបទបង្ហាញបានបញ្ចប់ សិស្សានុសិស្សបានចោទសួរសំណួរជាច្រើនទៅកាន់វាគ្មិន ដើម្បីបកស្រាយ និងស្រាយចម្ងល់ដែលខ្លួនចង់ដឹង។ មុននឹងបញ្ចប់បទបង្ហាញ លោក ស៊ាង ចិន្តា ចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជូនសិស្សានុសិស្សចូលរួមទាំងអស់ដើម្បីយកទៅសិក្សាឈ្វេងយល់ និងប្រើប្រាស់ជាឯកសារប្រវត្តិសាស្ត្រផ្ទាល់ខ្លួន។

## ការសិក្សាអំពីការបែងចែកប្រជាជនរបស់ខ្មែរក្រហម

សិស្សានុសិស្សដែលដែលបានចូលរួមកម្មវិធីនៅថ្ងៃនេះត្រូវបានចែកចេញជា៣ក្រុមធំៗ តាមប្រធានបទ និងរឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៣រូប ដែលរស់នៅក្នុងមូលដ្ឋានស្រុកកោះសូទិន ប៉ុន្តែត្រូវបានខ្មែរក្រហមបែងចែកជាក្រុមប្រជាជនផ្សេងៗគ្នា។

### ក្រុមទី១ សិក្សាពីក្រុមប្រជាជនចាស់ (ប្រជាជន ឆ្នាំ៧០)

ខ្ញុំឈ្មោះ ឡុង គឹមស្រ៊ាង អាយុ៦៨ឆ្នាំ រស់នៅភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្ត

កំពង់ចាមៗ ខ្ញុំមានគ្រួសារឈ្មោះ ថៃ ម៉ុកហេង ហើយមានកូនចំនួន៦នាក់ ប្រុស២នាក់និងស្រី៤នាក់ៗ ឪពុកខ្ញុំឈ្មោះ មាន និងម្ដាយឈ្មោះ ស៊ិន់ ហើយខ្ញុំគឺជាកូនទោលៗ នៅពីក្មេងខ្ញុំរៀននៅសាលាវត្តគ្រួអ៊ួក ដល់ថ្នាក់ទី១០សង្គមចាស់ៗ នៅឆ្នាំ១៩៧០ មានបាតុកម្មកើតឡើងក្រោយរដ្ឋប្រហារទម្លាក់សម្ដេចឪ ប្រជាជននាំគ្នាធ្វើបាតុកម្មដង្ហែទាមទារសម្ដេចឪយាងគ្រងរាជ្យសម្បត្តិវិញៗ ចន្លោះពីឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧២ មានកងទ័ពរំដោះខ្មែរក្រហមចូលមកបណ្ដើរៗហើយ ដោយសុំស្នាក់នៅតាមក្រោមផ្ទះរបស់អ្នកស្រុកៗ នៅឆ្នាំ១៩៧៣ មានយន្តហោះទ្រុងជ្រូក មកទម្លាក់គ្រាប់បែកខ្លាំងទើបខ្ញុំរត់ទៅនៅភូមិមហាលាភៗ នៅឆ្នាំ១៩៧៥ ម្ដាយខ្ញុំបានស្លាប់ដោយសារមានជំងឺ ហើយខ្ញុំក៏វិលត្រឡប់មកស្រុកកំណើតវិញៗ នៅឆ្នាំ១៩៧៦ ខ្ញុំចូលធ្វើការនៅក្នុងកងចល័ត និងកងចុងភៅដែលមានទីតាំងនៅកណ្ដាលភូមិកោះសូទិន និងមានប្រធានកងឈ្មោះមិត្ត ជុនៗ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមឲ្យខ្ញុំធ្វើជាប្រធានកងរយ ដែលមានមនុស្សចំនួន៩៧នាក់ រស់នៅក្នុងឃុំកោះសូទិនទាំងអស់ៗ ខ្ញុំធ្វើការនៅការដ្ឋានផ្ទៃត រួមមាន ស្ទូងស្រូវ រែកដី និងជីកប្រឡាយ រួចហើយខ្ញុំប្ដូរទៅធ្វើការកន្លែងផ្សេងទៀតៗ នៅដើមឆ្នាំ១៩៧៨ ខ្មែរក្រហមឲ្យខ្ញុំស្រង់ឈ្មោះមនុស្សយកទៅរៀនសូត្រចំនួន៣០នាក់ នៅជិតគុកចន្ទុំអណ្ដែត បន្ទាប់មកខ្មែរក្រហមបានរំសាយលែងឲ្យខ្ញុំស្រង់ឈ្មោះទៀតៗ នៅឆ្នាំ១៩៧៩ ខ្ញុំបានរៀបការប្រពន្ធរួមជាមួយសមមិត្ត១២០គូផ្សេងទៀតៗ

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្ដាហ៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ ចំនួន៥៥នាក់មកពីវិទ្យាល័យ ឈីនលាន ហាន់ជ័យ ស្ថិតនៅស្រុកកំពង់សៀម ខេត្តកំពង់ចាមៗ
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )





នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ ចំនួន៥៥នាក់មកពីវិទ្យាល័យ ឈិនលាន ហាន់ជ័យ ស្ថិតនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ( លី ដេវីត/ មជ្ឈមណ្ឌលឯកសារកម្ពុជា )




**ក្រុមទី២ សិក្សាពីក្រុមប្រជាជនកណ្តាល (ប្រជាជន ឆ្នាំ៧៣)**

ខ្ញុំឈ្មោះ អានរី អាយុ៦៩ឆ្នាំរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានស្រុកកំណើតនៅភូមិកោះប្រាក់ ឃុំកោះទន្ទឹម ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ គ្រួសារខ្ញុំឈ្មោះ ហុក ណៃវេង។ ខ្ញុំរៀបការនៅឆ្នាំ១៩៧៥ ហើយមានកូន៥នាក់ គឺស្រី៤នាក់ និងប្រុស១នាក់។ ខ្ញុំមានឪពុកឈ្មោះ អេង អាន និងម្តាយឈ្មោះ ជីរស់ និងមានបងប្អូន៦នាក់ គឺប្រុស៣នាក់ និង ស្រី៣នាក់ ហើយខ្ញុំគឺជាកូនទី២។ កាលពីក្មេងខ្ញុំរៀននៅសាលាបឋមសិក្សាកោះប្រាក់ ខ្ញុំរៀនដល់ថ្នាក់ទី៧ សង្គមចាស់ ហើយខ្ញុំដាក់ពាក្យប្រឡងចូលលីសេ ស្រាប់តែមានបាតុកម្មកើតឡើងក្រោយរដ្ឋប្រហារទម្លាក់សម្តេចឪនៅឆ្នាំ១៩៧០។ នៅឆ្នាំ១៩៧១ ខ្ញុំមិនបានទៅប្រឡងទេ ព្រោះមានការបាញ់គ្នារវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម និងការទម្លាក់គ្រាប់បែកខ្លាំងបណ្តាលឲ្យឆេះផ្ទះសម្បែងនៅទឹកដីកោះប្រាក់។ នៅឆ្នាំ១៩៧២ គ្រួសាររបស់ខ្ញុំរត់ទៅនៅកោះកំពង់ត្រាំ ស្ថិតនៅជាយខេត្តកំពង់ចាម ដែលខាងកងទ័ពរំដោះវាយយកបាន។ នៅឆ្នាំ១៩៧៣ ខ្ញុំបានមករស់នៅកោះសូទិនវិញជាមួយឪពុកធំ។ នៅឆ្នាំ១៩៧៥ អង្គការឲ្យខ្ញុំធ្វើការនៅក្រុមប្រវាស់ដៃរយៈពេល៥ខែទើបចូលធ្វើការនៅសហករណ៍វិញ ហើយខ្ញុំទៅធ្វើការនៅការដ្ឋាននៅឆ្នំត្រា។ នៅឆ្នាំ១៩៧៦ អង្គការឲ្យខ្ញុំថែគោ ភ្ជួររាស់ធ្វើស្រែនៅឆ្នំត្រាលើផ្ទៃដី៥០០ហិចតា។ ខ្ញុំក្រោកពីម៉ោង៤ទៀបភ្លឺទៅប្រជុំជួររួចទឹមគោមកភ្ជួរដី១ហិចតាគោ៥នឹម ពេលភ្ជួររួចនៅម៉ោង១០ព្រឹក ខ្ញុំមកហូបបបរ បន្ទាប់មកយកគោទៅឲ្យស៊ីស្មៅដល់ម៉ោង៤ល្ងាច ទើបដឹកយកមកវិញ។ នៅរដូវប្រាំង អង្គការឲ្យខ្ញុំទៅដឹកអុសនៅពាមជាំង យកមកដាក់រោងបាយរួម។ នៅឆ្នាំ១៩៧៧ កងកម្លាំងខ្មែរក្រហមខាងភាគនិរតីចូលមកចាប់កម្មាភិបាលដែលធ្វើការពីមុនៗមានឈ្មោះ មិត្តយុន និងមិត្ត ស៊ា យកទៅរៀនសូត្រ។ នៅឆ្នាំ១៩៧៩ ខ្ញុំត្រឡប់មកភូមិវិញ។

**ក្រុមទី៣ សិក្សាពីក្រុមប្រជាជនថ្មី (ប្រជាជន ១៧ មេសា)**

ខ្ញុំឈ្មោះ ធីវាសនា អាយុ៦៤ឆ្នាំរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្តីឈ្មោះ ម៉េង អាន និងមានកូនប្រុសស្រីចំនួន៥នាក់។ ឪពុកខ្ញុំឈ្មោះ ធី និង ម្តាយឈ្មោះ

សន។ នៅពីក្មេង ខ្ញុំរៀននៅសាលាបឋមសិក្សាវត្តគ្រួអ៊ុក ត្រឹមថ្នាក់ទី៩ចាស់។ បន្ទាប់មកខ្ញុំរស់នៅជាមួយបងស្រីនៅ ទីរួមខេត្តកំពង់ចាម ចូលរៀននៅសាលាបឋមសិក្សាទួលថ្ម រហូតដល់ថ្នាក់ទី៦ចាស់។ បន្ទាប់ពីរដ្ឋប្រហារ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំឃើញបាតុកម្មបានផ្ទុះឡើង និងក្បួនបាតុករដង្ហែចូលមកដល់ទីរួមខេត្តកំពង់ចាម។ ពីឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧២ ខ្ញុំបន្តរស់នៅជាមួយក្រុមគ្រួសារនៅ ទីរួមខេត្តកំពង់ចាម ប៉ុន្តែបានឈប់រៀនហើយ ពីព្រោះនៅពេលនោះមានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមផ្ទុះឡើងកាន់តែខ្លាំង។ កងទ័ពរំដោះខ្មែរក្រហមបានបើកការវាយប្រហារ និងរំកិលចូលមកទីរួមខេត្តបន្តិចម្តងៗ។ នៅពាក់កណ្តាលឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាម ត្រូវបានឡោមព័ទ្ធទៅដោយកងទ័ពរំដោះខ្មែរក្រហម។ ក្រុមគ្រួសារខ្ញុំនាំគ្នារត់ឡើងម៉ារីនរបស់ទាហាន លន់ នល់ ទាំងយប់មកទីក្រុងភ្នំពេញ ហើយនៅតាមផ្លូវមានការវាយប្រហារពីកងទ័ពរំដោះខ្មែរក្រហម ឈរជើងនៅតាមដងទន្លេមេគង្គ។ ខ្ញុំមកដល់ភ្នំពេញពេលព្រឹក រួចហើយទៅស្នាក់ផ្ទះបងប្អូនខាងបងថ្លៃខ្ញុំនៅ ស្ទឹងមានជ័យ។ ខ្ញុំចូលរៀននៅវិទ្យាល័យ កែ សុងគីម ថ្នាក់ទី៥។ នៅឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហមវាយបែកភ្នំពេញ ហើយខ្មែរក្រហមដេញក្រុមគ្រួសារខ្ញុំចេញពីភ្នំពេញ។ ឪពុកម្តាយខ្ញុំ មកដល់ស្រុកកំណើតមុន ចំណែកខ្ញុំនិងបងស្រីមកតាមក្រោយ ដោយដើរតាមព្រៃកញ្ចៀរយៈពេលកន្លះខែទើបមកដល់ស្រុក។ ខ្ញុំមកស្នាក់នៅជាមួយយាយ ហើយខ្មែរក្រហមឲ្យខ្ញុំធ្វើការរែកដីនៅក្នុងមូលដ្ឋាន។ នៅឆ្នាំ១៩៧៦ អង្គការជម្លៀសគ្រួសារខ្ញុំទៅតាំងគោក ដោយឲ្យជិះស្រឡាងទៅពាមជីកងរួចឡើងឡានទៅតាំងគោក ខេត្តកំពង់-ធំ។ នៅឆ្នាំ១៩៧៧ អង្គការឲ្យខ្ញុំធ្វើការនៅកងចល័តស្រុក រែកដីលើកទំនប់នៅកំពង់ថ្ម។ ខ្ញុំត្រូវដើរពីម៉ោង៥ទៅប្រជុំជួរ ហើយចាប់ផ្តើមធ្វើការដល់ម៉ោង១១ថ្ងៃត្រង់ ទើបឈប់សម្រាកហូបបបរ។ ខ្ញុំបន្តធ្វើការពីម៉ោង១ដល់ម៉ោង៥ល្ងាច ដឹកនាំដោយប្រធានក្រុមឈ្មោះមិត្តសេង។ នៅឆ្នាំ១៩៧៨ អង្គការឲ្យខ្ញុំទៅធ្វើការនៅភ្នំសន្ទុក លើករងដំឡូងក្នុងម្នាក់ឲ្យបានប្រវែង១០០ម៉ែត្រ។ ខ្ញុំបានបន្តធ្វើការនៅការដ្ឋាននេះរហូតដល់ពេលដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមករំដោះប្រជាជនចេញពីការកាប់សម្លាប់របស់ខ្មែរក្រហម។ ខ្ញុំបានរួចផុតពីសេចក្តីស្លាប់នៅពេលនោះហើយវិលត្រឡប់រស់នៅជួបជុំគ្រួសារវិញ។

ក្រោយពីបានចូលរួមវេទិកាថ្នាក់រៀនប្រវត្តិ-សាស្រ្តកម្ពុជាប្រជាធិបតេយ្យរួចមកសិស្សានុសិស្ស



នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ ចំនួន ៥៥នាក់មកពីវិទ្យាល័យ ឈីនលាន ហាន់ជ័យ ស្ថិតនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

បានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

**ស្តើង ចាន់ដាន** រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ រៀបរាប់ថា «ខ្ញុំទទួលបានចំណេះដឹងប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ ទស្សនាផ្ទាំងរូបភាពប្រវត្តិសាស្ត្រ និងសាច់រឿងអ្នកឆ្លងកាត់សម័យខ្មែរក្រហម។ ខ្ញុំពិតជាមានការអាណិតអាសូរដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានឆ្លងកាត់ការលំបាកវេទនា ការធ្វើទារុណកម្ម និងសម្លាប់ប្រជាជនរាប់លាននាក់។ ខ្ញុំដឹងពីមូលហេតុខ្មែរក្រហមជម្លៀសប្រជាជនចេញពីស្រុកកំណើតឲ្យទៅរស់នៅតំបន់ផ្សេងៗ។ ក្នុងនាមជាយុវជនជំនាន់ក្រោយ ខ្ញុំខិតខំរៀនសូត្រនិងចូលរួមទប់ស្កាត់កុំឲ្យរបបនេះវិលមកវិញម្តងទៀត»។

**នេត សីម៉ា** រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ រៀបរាប់ថា នៅពេលដែលខ្ញុំបានចូលរួមកម្មវិធីនៅថ្ងៃនេះ ខ្ញុំទទួលបាននូវចំណេះដឹងថ្មីថែមទៀតពីសម័យខ្មែរក្រហម ដែលពីមុខខ្ញុំបានត្រឹមដឹង និងស្តាប់ពីលោកតាលោកយាយរបស់ខ្ញុំដែលពួកគាត់បាននិយាយប្រាប់ខ្ញុំ និងតាមមេរៀននៅក្នុងសៀវភៅ។ សម្រាប់សាច់រឿងអ៊ំដែលជាប្រជាជនឆ្នាំ១៩៧៣ ក៏ជារឿងថ្មីមួយសម្រាប់នាងខ្ញុំ ដែលពីមុនមកខ្ញុំបានដឹងត្រឹមថា មានប្រជាជនតែ២ប្រភេទ គឺប្រជាជនចាស់ និងប្រជាជនថ្មី ដែលសាច់រឿងនេះពិតជាមានសារសំខាន់ និងជាចំណេះដឹងថ្មីមួយ សម្រាប់នាងខ្ញុំ។

**វ៉អម ប៊ុនរ៉ុង** រៀនថ្នាក់ទី១២ ផ្នែកវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ បានរៀបរាប់ថា ខ្ញុំបានទទួលចំណេះដឹងជាច្រើនពីវេទិកាប្រវត្តិសាស្ត្រខ្មែរក្រហម និង បានចុះទៅទីតាំងប្រវត្តិសាស្ត្រ ដែលអ៊ំពូមីងធ្លាប់ឆ្លងកាត់ការលំបាកវេទនា ការហូបចុកមិនគ្រប់គ្រាន់ ធ្វើការហួសកម្លាំងនៅក្នុងរបបខ្មែរក្រហម។ កាលពីមុនខ្ញុំធ្លាប់បានស្តាប់លោកយាយរបស់ខ្ញុំនិយាយប្រាប់ពីរឿងរ៉ាវពីរបបខ្មែរក្រហមថា ឃោរឃៅ សាហាវព្រៃផ្សៃ ហើយខ្ញុំបានមកមើលឃើញផ្ទាល់ភ្នែកជាចំណេះដឹងថ្មីមួយទៀតសម្រាប់ជីវិតខ្ញុំ។ ក្នុងនាមជាយុវជនជំនាន់ក្រោយ ខ្ញុំខិតខំរៀនសូត្រ និងចូលរួមទប់ស្កាត់កុំឲ្យរបបនេះវិលមកវិញម្តងទៀត»។

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនបុងសប្បាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ ចំនួន ៥៥នាក់មកពីវិទ្យាល័យ ឈីនលាន ហាន់ជ័យ ស្ថិតនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )



# សៀង សៀប ៖ កូនពីរនាក់ស្លាប់នៅក្នុងថ្ងៃតែមួយក្នុងរបបខ្មែរក្រហម

រីម ស្រីស្រស់

នៅវេលាព្រឹក ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ នាងខ្ញុំឈ្មោះ រីម ស្រីស្រស់ គឺជាបុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តតាកែវបានធ្វើដំណើរទៅដល់ផ្ទះអ៊ំស្រីម្នាក់ស្ថិតនៅភូមិកន្ទួត ឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ។ ខ្ញុំសង្កេតឃើញគាត់អង្គុយនៅលើអង្រឹងដែលចងនៅខាងក្រោមផ្ទះម្នាក់ឯងជាមួយ ទឹកមុខស្រងូតស្រងាត់។ ខ្ញុំបានជម្រាបសួរគាត់ពីចម្ងាយ និងបានណែនាំខ្លួនខ្ញុំ។ ឆ្លៀតឱកាសនោះ ខ្ញុំបានសួរនាំគាត់អំពីសុខភាពនិងរឿងរ៉ាវជីវិតរបស់គាត់ដែលបានឆ្លងកាត់របបខ្មែរក្រហម។

អ៊ំស្រីបានរៀបរាប់ប្រាប់ខ្ញុំថា គាត់ឈ្មោះ សៀង សៀប អាយុ៧០ឆ្នាំ។ គាត់មានស្រុកកំណើតនៅឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ គាត់មានកូនចំនួន៩នាក់ គឺកូនប្រុស៨នាក់ និងកូនស្រី១នាក់។ សព្វថ្ងៃគាត់មានបញ្ហាត្រចៀកស្តាប់មិនសូវឮ និងមានជំងឺភ្លេចភ្លាំងច្រើន។ គាត់នៅតែនឹករឭក និងសោកស្តាយកូនរបស់គាត់ដែលស្លាប់នៅក្នុងរបបខ្មែរក្រហម។

កាលពីសង្គមចាស់ គាត់មិនបានរៀនសូត្រទេ ព្រោះគាត់រស់នៅក្នុងគ្រួសារដែលមានជីវភាពខ្វះខាតខ្លាំង។ នៅអាយុ១៦ឆ្នាំ គាត់បានរៀបការជាមួយបុរសម្នាក់ឈ្មោះ សំ អាង។ ប្តីរបស់គាត់មានតួនាទីជាមេឃុំព្រៃសណ្តែក ស្រុកទ្រាំង ខេត្តតាកែវ។ បន្ទាប់ពីរៀបការរួច គាត់កើតបានកូន



អាន គុម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាបន្តបន្ទាប់ចំនួន៣នាក់។ នៅក្នុងរបបខ្មែរក្រហម គាត់និងប្តីរបស់គាត់ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការងារផ្សេងពីគ្នា។ ក្រោយមក គាត់បានទទួលដំណឹងថា ប្តីរបស់គាត់និងសាច់ញាតិក្រុមគ្រួសារប្តីរបស់គាត់ព្រមទាំងអ្នកមានឋានៈតួនាទីពីសង្គមចាស់ផ្សេងទៀត ត្រូវបានខ្មែរក្រហមដឹកតាមរទេះគោយកទៅសម្លាប់ចោលទាំងអស់។

ហេតុការណ៍នោះ បានធ្វើឲ្យគាត់មានការតក់ស្លុត និងភ័យខ្លាចយ៉ាងខ្លាំង។ គាត់បានបន្តរស់នៅលាក់ខ្លួនជាមួយកូនៗទាំង៣នាក់របស់គាត់។ ជារៀងរាល់ថ្ងៃ គាត់ចេញទៅធ្វើការងារតាមសហករណ៍ដទៃទៀតដោយទុកកូនតូចៗទាំង៣នាក់របស់គាត់ចោលនៅឯផ្ទះឆ្ងាយពីការដ្ឋានការងារ។ លុះត្រឡប់មកពីធ្វើការងារពេលល្ងាច គាត់បានវេចខ្ចប់អាហារបន្តិចបន្តួចមកផ្ញើកូនៗរបស់គាត់។ ការងាររបស់គាត់ជារឿយៗផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀត។ គាត់ទៅធ្វើការងារដូចសព្វដង ប៉ុន្តែថ្ងៃមួយគាត់បានជួបរឿងរន្ធត់ និងធ្វើឲ្យគាត់ឈឺចាប់បំផុតនោះគឺ កូនរបស់គាត់ពីរនាក់ក្នុងចំណោមកូនទាំង៣នាក់ បានស្លាប់ត្រឹមរយៈពេលមួយថ្ងៃប៉ុណ្ណោះ។ កូនរបស់គាត់ទាំងពីរនាក់ មានអាយុ២ឆ្នាំ និង៣ឆ្នាំ និងមានរាងកាយស្គមស្គាំង។ កូនរបស់គាត់បានស្លាប់ដោយសារមិនមានអាហារហូបចុកគ្រប់គ្រាន់ និងមិនមានអ្នកមើលថែទាំដិតដល់។ ហេតុការណ៍នេះ នៅតែដក់ជាប់ក្នុងអារម្មណ៍របស់គាត់ និងធ្វើឲ្យគាត់មិនអាចបំភ្លេចបានឡើយ។ គាត់បន្តរស់នៅជាមួយកូនម្នាក់ដែលរួចផុតពីសេចក្តីស្លាប់នៅពេលនោះ។

ក្រោយពីរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩ គាត់បានវិលត្រឡប់មកស្រុកកំណើតនៅឃុំអង្កាញ់វិញ និងបានរៀបការជាមួយបុរសម្នាក់ទៀតឈ្មោះ រឿន។ នៅពេលនោះ គាត់បង្កើតកូនបានចំនួន២នាក់ទៀត។ ប៉ុន្តែប៉ុន្មានឆ្នាំក្រោយមក គាត់និងប្តីក្រោយបានលែងលះគ្នា ហើយគាត់បាននាំកូនៗមករស់នៅភូមិកន្ទួត ឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ រហូតមកដល់សព្វថ្ងៃ។ គាត់នៅតែមានអារម្មណ៍សោកសៅ និងហូរទឹកភ្នែករាល់ពេលដែលរំឭកអំពីរបបខ្មែរក្រហម។

រូបក្របមុខ និង រូបក្របក្រោយៈ
កងទ័ពបដិវត្តន៍ខ្មែរក្រហមរឹបអូសយកនាវាដើងទឹករបស់កង ទ័ព លន់ បន្ទាប់ពីទទួលជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 287, November 2023 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.